ទស្សនាវដ្ដី

# ប្រជាជន

THE PRACHEACHUN MAGAZINE





ឆ្នាំទី១៧ លេខ ២០០ ខែមករា ឆ្នាំ ២០១៨




**និពន្ធនាយក ៖**

**លោក តាក ស៊ុនអ៊ី**

**គណៈកម្មការនិពន្ធ**

១. លោក ខៀវ ណារី
២. លោក អ៊ុម សុន្ទរៈ
៣. លោក វង្ស សាវុធ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន

**លេខានិពន្ធ**

១. លោក ជុំ សម្បត្តិ
២. លោក ម៉ក់ ឈិន

**អ្នកបកប្រែភាសា**

១. លោកស្រី ម៉ែន នារីសោភ័គ

**អ្នកថតរូប**

១. លោក សុផាត វីរៈមុនី

**វិចិត្រករ**

១. លោក ធា សាវុធ

អាស័យដ្ឋាន ៖
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ ៖
០២៣ ២១៩ ០៦៥

**Address :**
**No 203 Preah**
**Norodom Bld.**
**Phnom Penh Cambodia**
**Tel : 023 219 065**





ទិដ្ឋភាពទូទៅនៃមហាសន្និបាត
វិសាមញ្ញតំណាងទូទាំង
ប្រទេសរបស់គណបក្ស.......
៦





ប្រជាជនកម្ពុជាប្រារព្ធពិធីមីទិញ
អបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៩
ទិវាជ័យជម្នះ ៧ មករា ដោយ......
- ក្នុងរយៈពេល៣៩ ឆ្នាំ គណបក្ស.......
៩





ទន្លេរបស់យើង ដើម្បីសន្តិភាព និងការ.....
ជាប្រធានបទនៃកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាង
លើកទី២
១២





ទស្សនកិច្ចរបស់ឯកឧត្តម **លី ខឺឈាង**
កាន់តែជំរុញខ្លាំងក្លាថែមទៀត
កិច្ចសហប្រតិបត្តិការភាពដៃគូជាយុទ្ធសាស្រ្ត
គ្រប់ជ្រុងជ្រោយរវាងប្រទេស.........
១៤





**សម្តេចតេជោ ហ៊ុន សែន** នឹងបន្តធ្វើជានាយករដ្ឋមន្ត្រី
រយៈពេល ២ អាណត្តិទៀត
- គ្រូពេទ្យទាំងអស់ត្រូវធ្វើការងារប្រកបដោយ.....
- អ្នកសារព័ត៌មានមិនត្រូវធ្វើជាចៅក្រមកាត់........
១៦


# ក្របមុខ

## មហាសន្និបាតវិសាមញ្ញ តំណាងទូទាំងប្រទេសរបស់ គណបក្សប្រជាជនកម្ពុជា

*(ថ្ងៃទី១៩-២០-២១ ខែមករា ឆ្នាំ២០១៨)*

# មាតិកា
# Contents


វិចារណកថា ៖ ពង្រឹងផ្លូងមហាសាមគ្គីភាពនៅលើមាគ៌ាជ័យជម្នះរបស់គណបក្សប្រជាជនកម្ពុជា.......... ១
Editorial : Strengthen Strand of Great Solidarity on Victorious Path of the............................
អត្ថបទនយោបាយ ៖ កម្ពុជាកំពុងដើរទៅមុខក្នុងក្របខណ្ឌនៃប្រជាធិបតេយ្យ និងនីតិរដ្ឋ..................... ៣

- សេចក្តីសម្រេចចិត្តនៃមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់ ................................ ០៤
- សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ................................ ១៩
- សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស .................................................................... ២២
- សមិទ្ធផលសំខាន់ៗមួយចំនួននៃវិស័យសេដ្ឋកិច្ច.............................................................. ២៤
- ពង្រឹងយន្តការការងារឲ្យកាន់តែមានប្រសិទ្ធភាព និងស៊ីជម្រៅ ធ្វើឲ្យវិស័យពាណិជ្ជកម្ម................. ២៦
- សមិទ្ធផលដ៏សំខាន់ដែលបានមកពីការពង្រឹងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រង........................... ២៧
- ទឹកដីមាតុភូមិ ៖ ឃុំមង់រៀវ នារដូវរំហើយ..................................................................... ២៩
- កំណាព្យ ៖ ជំនោរហេមន្តរដូវ...................................សំណើច.............................................. ៣១

វិចារណកថា
EDITORIAL

# ពង្រឹងផ្នួងមហាសាមគ្គីភាពនៅលើមាគ៌ាជ័យជម្នះរបស់គណបក្សប្រជាជនកម្ពុជា

# Strengthen Strand of Great Solidarity on Victorious Path of the Cambodian People's Party

មហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្សប្រជាជនកម្ពុជា ដែលបានប្រព្រឹត្តិទៅពីថ្ងៃទី១៩-២១ ខែមករា ឆ្នាំ២០១៨ បានធ្វើការពិភាក្សាប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ តាមរយៈបញ្ញាញាណដ៏ឈ្លាសវៃរបស់សមូហភាពនៃអង្គមហាសន្និបាតទាំងមូល និងបានសម្រេចលើបញ្ហាសំខាន់ៗជាច្រើន ដែលជាផលប្រយោជន៍ជាអាយុជីវិតរបស់ប្រជាជនកម្ពុជា ដែលក្នុងនោះរួមមានរបាយការណ៍ស្តីពីសភាពការណ៍ទូទៅ និងការងារគណបក្សឆ្នាំ២០១៧ និងទិសដៅភារកិច្ចឆ្នាំ២០១៨ សេចក្តីព្រាងកម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា សម្រាប់កសាង និងការពារមាតុភូមិឆ្នាំ២០១៨-២០២៣ ។ មហាសន្និបាតវិសាមញ្ញបានគាំទ្រជាឯកច្ឆន្ទ ចំពោះបេក្ខភាព**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់នីតិកាលទី៦ នៃរដ្ឋសភា និងនីតិកាលបន្តបន្ទាប់ទៀត ។ មហាសន្និបាតក៏បានសម្តែងការគោរពចំពោះតួនាទីជាប្រវត្តិសាស្ត្រដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចតេជោ ហ៊ុន សែន ជាស្នូលនៃគណបក្សប្រជាជនកម្ពុជា និងជាអគ្គមគ្គុទេសក៍ដ៏ឆ្នើមនៃប្រជាជនកម្ពុជា** ដែលបានដឹកនាំប្រទេសឆ្លងកាត់តំណាក់កាលដ៏សែនលំបាកនានាប្រកបដោយគតិបណ្ឌិតភាពឈ្លាសវៃ និងភាពអង់អាចសម្រេចបានជោគជ័យដ៏ត្រចះត្រចង់ជូនជាតិមាតុភូមិ និងប្រជាជន ។ មហាសន្និបាតក៏បានបោះឆ្នោតបំពេញបន្ថែមសមាជិកគណៈកម្មាធិការកណ្តាលគណបក្សចំនួន ៣៤២រូប ទៀត ធ្វើឲ្យចំនួនសរុបកើនដល់ ៨៦៥រូប ។

មហាសន្និបាតវិសាមញ្ញនាពេលនេះ បានប្រព្រឹត្តិទៅក្នុងរយៈពេល១ឆ្នាំនៃការអនុវត្តប្រកបដោយជោគជ័យនូវទិសដៅ និងការងារសំខាន់ៗមួយចំនួនដែលដាក់ចេញដោយសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៤០អណត្តិទី៥ ( ១៧-១៨ ធ្នូ ឆ្នាំ២០១៦ ) និងក្នុងឱកាសដែលប្រជាជនកម្ពុជារីករាយអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៩ ទិវាមហាជ័យជម្នះ ៧ មករា ជាប្រវត្តិសាស្ត្រ ។ មហាសន្និបាតក៏បានដំណើរការឡើងក្នុងបរិយាកាសដែលប្រជាជនកម្ពុជាកំពុងរស់នៅប្រកបដោយសុខសន្តិភាពស្ថិរភាពពេញលេញ ដំណើរការអភិវឌ្ឍន៍សង្គមជាតិលើគ្រប់វិស័យបាននឹងកំពុងរីកចម្រើនក្នុងសន្ទុះដ៏ខ្លាំងក្លា ជាពិសេសដំណើរការអនុវត្តប្រជាធិបតេយ្យ និងនីតិរដ្ឋកំពុងត្រូវបានពង្រឹងយ៉ាងរឹងមាំ ហើយក៏ជាពេលវេលាដែលយើងទាំងអស់គ្នាកំពុងរៀបចំអនុវត្តឲ្យបានជោគជ័យក្នុងដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ផងដែរ ។ ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចតេជោ ហ៊ុន សែន** ជាប្រមុខ ប្រទេសកម្ពុជាយើងទទួលបាននូវជោគជ័យធំៗជាច្រើនគួរឲ្យកត់សម្គាល់ ។ តាមរយៈការអនុវត្តវិធានការច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាព យើងបានធ្វើឲ្យបរាជ័យទាំងស្រុងឧបាយកលបដិវត្តន៍ពណ៌ និងរំលាយចោលអង្គការចាត់តាំងបដិវត្តន៍ពណ៌ ដែលគណបក្សប្រឆាំងបានធ្វើឡើង យ៉ាងគឃ្លើនដោយមានការជ្រោមជ្រែងពីមជ្ឈដ្ឋានអគតិខាងក្រៅប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ដែលផ្ទុយ

The nationwide representatives' extraordinary congress of the Cambodian People's Party held from 19 through to 21 January 2018 discussed with high attention through wise and collective intellects of the whole congress and decided numerous vital issues, including reports of general situation and party work in 2017, and draft of the political platform of the Cambodian People's Party for the construction and defense of motherland for 2018-2013. The congress unanimously supports candidacy of Samdech Akka Moha Sena Padei Techo Hun Sen for the post of Prime Minister of the Kingdom of Cambodia for the sixth legislative term of the National Assembly, and next legislative terms. The congress expressed respect for the historic and supreme role of Samdech Techo Hun Sen as the center of the Cambodian People's Party and the great leader of the people of Cambodia, who have led the country out of the most difficult stages with wisdom and braveness to achieve brilliant success for our nation, motherland, and people. The congress voted to elect 342 new members, making the total number of the Central Committee reaching 865.

The extraordinary congress held in after one-year successful implementation of goals and major tasks set out by the fifth term central committee's 40th plenum (17-18 December 2016), and at a time that the Cambodian people celebrated with joy the 39th anniversary of the 7 January historic victory. The congress proceeded in an environment that the Cambodian people are living in full peace, stability, and the national development are making progress rapidly, especially process of implementing democracy and firmly strengthening rule of law, and a time when we are preparing for successful organization of the fourth legislative term Senate elections to be held on 25 February 2018, and the sixth legislative term of the National Assembly on 29 July 2018.

Under the leadership of the Cambodian People's Party and the Royal Government of Cambodia, headed by Samdech Techo Hun Sen, Cambodia scored major successes. In strictly and effectively implementing legal measures, we have failed entirely the color revolution attempt and dismantled its organization operated by the opposition with supports from external ill-willed circled with an aim to downfall the legal Royal Government. Their actions are contrary to the Constitution, principles of democracy, rule of law, and will of the people.

Based on this development, we have defended firmly every national achievements, national independence foundation and national sovereignty, and guaranteed that Cambodia continues to march forwards on the right path of democracy and liberal pluralism. People's rights and freedom have been ensured in a legal framework. People's national defense foundation has been firmly emboldened guaranteeing the defense of peace, territorial integrity, and national sovereignty. Better security, social order and safety, have created favorable conditions for process of every institution in the country, and ensured people's peaceful life.

Reforms in every front, especially those in the public administration, public finance management, and decentralism and de-concentration, have been driven for highly effective implementation to score numerous results making contributions to raising high living condition of the people, and national progresses. The Cambodian economy rapidly grew maintaining an average growth of 7.7% in the last two decades. People's living condition's gradual improvement reflected through social indicator were the growth of GDP per capita of 1,042 USD in 2013 to about 1,435 USD in 2017. Poverty rate has dropped sharply from 53.5% in 2004 to 13.5% in 2014, and continues to fall further. Gap of people's income has also narrowed.

The Royal Government of Cambodia successfully implemented its foreign policies that is contributing dynamically to elevate role of the Kingdom of Cambodia in the international arena, while actively taking

*ទាំងស្រុងពីរដ្ឋធម្មនុញ្ញ ពីគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ ផ្ទុយពីឆន្ទៈប្រជាជន ។ លើមូលដ្ឋាននេះយើងការពារបានយ៉ាងរឹងមាំរាល់សមិទ្ធផលសង្គមជាតិ ការពារបានខឿនឯករាជ្យជាតិ និងអធិបតេយ្យជាតិ ធានាឲ្យកម្ពុជាបន្តដើរទៅមុខយ៉ាងត្រឹមត្រូវតាមគន្លងនៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ។ សិទ្ធសេរីភាពរបស់ប្រជាជនកាន់តែត្រូវបានពង្រឹងនៅក្នុងក្របខណ្ឌច្បាប់ ។ ខឿនការពារជាតិរបស់ប្រជាជនក៏ត្រូវបានពង្រឹងកាន់តែរឹងមាំ ធានាបាននូវកិច្ចការពារសន្តិភាពបូរណ ភាពទឹកដី និងអធិបតេយ្យជាតិ ។ សភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមមានស្ថានភាពល្អប្រសើរ បង្កលក្ខណៈអំណោយផលដល់ដំណើរការនៃគ្រប់ស្ថាប័នក្នុងសង្គម និងធ្វើឲ្យប្រជាជនរស់នៅប្រកប ដោយភាពសុខសាន្ត ។ កំណែទម្រង់តាមវិស័យនានា ពិសេសការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានជំរុញអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ សម្រេចបាននូវលទ្ធផលជាច្រើន រួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងការរីកចម្រើនរបស់សង្គមជាតិ ។ សេដ្ឋកិច្ចកម្ពុជាក៏មានការរីកចម្រើនយ៉ាងឆាប់រហ័ស ដោយរក្សាបានកំណើនខ្ពស់ជាមធ្យម ៧,៧% ក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនេះ ។ កម្រិតជីវភាពរបស់ប្រជាជនមានភាពល្អប្រសើរជាលំដាប់ដែលឆ្លុះបញ្ចាំងតាមរយៈសូចនាករសង្គមនោះ គឺការកើនឡើងនៃ ផ.ស.ស ក្នុងមនុស្សម្នាក់ពី ១.០៤២ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៣ ដល់ប្រមាណ ១.៤៣៥ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ ។ អត្រាភាពក្រីក្រមានការធ្លាក់ចុះយ៉ាងខ្លាំងពី ៥៣,៥% ក្នុងឆ្នាំ២០០៤ មកត្រឹម ១៣,៥% ក្នុងឆ្នាំ២០១៤ និងបន្តធ្លាក់ចុះថែមទៀត ។ គម្លាតនៃប្រាក់ចំណូលរបស់ប្រជាជនក៏មានការធ្លាក់ចុះជាលំដាប់ ។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានអនុវត្តដោយជោគជ័យនយោបាយការបរទេសដែលរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់តួនាទីនៃព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិ ព្រមទាំងរួមចំណែកយ៉ាងសកម្មក្នុងកិច្ចការការពារ បូរណភាពទឹកដី អធិបតេយ្យ អព្យាក្រឹត្យភាព ទប់ស្កាត់បានការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជាពីសំណាក់បរទេសមួយចំនួន ។*

***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** *ប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានណែនាំដល់គណបក្សគ្រប់ថ្នាក់ និងមន្ត្រីគ្រប់ៗរូបត្រូវខិតខំអនុវត្តឲ្យបានជោគជ័យ នូវភារកិច្ចសំខាន់ៗចំពោះមុខ សំដៅប្តូរផ្តាច់ការពារឲ្យបានដាច់ខាតនូវសន្តិភាព ឯករាជ្យជាតិ អធិបតេយ្យជាតិ ជំរុញការអភិវឌ្ឍប្រទេសឲ្យកាន់តែរីកចម្រើនទៅមុខទៀត ។ ពង្រឹងការអនុវត្តលទ្ធិប្រជាធិបតេយ្យ ការលើកកម្ពស់ សិទ្ធសេរីភាពរបស់ប្រជាជនក្នុងក្របខណ្ឌច្បាប់ និងរដ្ឋធម្មនុញ្ញ ដោយទប់ស្កាត់មិនឲ្យកើតមាននូវបដិវត្តន៍ពណ៌ ដែលឈានទៅដល់ភាពចលាចល និងបង្ករគ្រោះថ្នាក់ដល់ប្រទេសជាតិ ។ អនុវត្តឲ្យបានជោគជ័យនូវការរក្សាសន្តិ សុខ សណ្តាប់ធ្នាប់សង្គម លុបបំបាត់ឲ្យអស់នូវរាល់បាតុភាពអវិជ្ជមាននានាដូចជា បញ្ហាគ្រឿងញៀន បទឧក្រិដ្ឋ នានា ការកាប់បំផ្លាញព្រៃឈើ បទល្មើសនេសាទ ការរំលោភបំពានយកដីធ្លីរដ្ឋ ការធ្វើអាជីវកម្មរ៉ែខុសច្បាប់និងការដាក់កុងត្រូលជជុះ ។ លើកកម្ពស់គុណភាពការផ្តល់សេវាសាធារណៈជូនប្រជាជន ដោយលុបបំបាត់ឲ្យអស់ភាពអសកម្មដែលនាំទៅដល់ការថ្នាំងថ្នាក់របស់ប្រជាជន ។ ព្រមជាមួយនេះត្រូវជំរុញការអនុវត្តគោលនយោបាយគាំពារសង្គម ពិសេសរាល់វិធានការនានាដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញកន្លងទៅ ដើម្បីធ្វើឲ្យប្រជាជនយើងបានរស់នៅក្នុងជីវភាពមួយដែលមានភាពកក់ក្តៅ ។ ការគិតគូរដោះស្រាយបញ្ហាថ្លៃកសិផលជូនប្រជាកសិករ ក៏ត្រូវយកចិត្តទុកដាក់ឲ្យបានម៉ត់ចត់ ។ ជាមួយគ្នានេះ មន្ត្រីគណបក្សគ្រប់ៗរូបត្រូវខិតខំសម្អិតសម្អាងខ្លួនឲ្យក្លាយទៅជាមន្ត្រីល្អ ខិតខំបម្រើប្រជាជន ដោះស្រាយរាល់ការលំបាកជូនប្រជាជនឲ្យបានទាន់ពេលវេលា អនុវត្តន៍ឲ្យបានខ្ជាប់ខ្ជួននូវអភិក្រម «**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**» ដើម្បីបង្កើនជំនឿទុកចិត្តរបស់ប្រជាជនមកលើគណបក្ស ។*

*ជាការពិតណាស់ ឆ្លងកាត់តាមព្រឹត្តិការណ៍មួយចំនួនដែលបានបង្កឡើងដោយគណបក្សប្រឆាំង និងមជ្ឈដ្ឋានអគតិនានាដែលប៉ុនប៉ងនាំយកប្រទេសជាតិឲ្យធ្លាក់ទៅក្នុងកលយុគជាថ្មីម្តងទៀត ប្រជាជនកម្ពុជាយើងកាន់តែមើលឃើញច្បាស់នូវតួនាទីដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាយូរអង្វែងតទៅមុខទៀត ដើម្បីធានាបាននូវសន្តិភាព ស្ថិរភាព ឯកភាពជាតិប្រជាធិបតេយ្យ និងការអភិវឌ្ឍ ។ លើមូលដ្ឋាននេះ អង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក មន្ត្រី និងសមាជិក សមាជិកាគណបក្សគ្រប់ៗរូបត្រូវពង្រឹងឲ្យបាននូវការឯកភាពខ្ពស់ ទាំងខាងទស្សនៈ គោលជំហរ និងសកម្មភាព ដោយក្តាប់ឲ្យជាប់ និងជ្រួតជ្រាបច្បាស់នូវខ្លឹមសារនៃសេចក្តីសម្រេចរបស់មហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្ស ដោយប្រែក្លាយស្មារតីនេះឲ្យទៅជា លទ្ធផលជាក់ស្តែងដើម្បីផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់ប្រទេសជាតិ និងប្រជាជនយើង ។ មន្ត្រីគណបក្សគ្រប់រូបត្រូវខិតខំពង្រឹងឲ្យបានផ្គុងសាមគ្គីភាព សហការគ្នាបំពេញការងារដោយស្មើដៃគ្នា ប្រទាក់ក្រឡាគ្នាជាអង្គតែមួយពីលើដល់ក្រោម ដើម្បីឈានទៅដណ្តើមជោគជ័យនៅក្នុងការបោះឆ្នោតនាពេលខាងមុខនេះ ។/*

ទស្សនាវដ្ដីប្រជាជន

parts in the defense of territorial integrity, sovereignty, and neutrality to prevent foreign interferences into Cambodian internal affairs.

Samdech Akka Moha Sena Padei Techo Hun Sen, president of the Cambodian People's Party, and Prime Minister of the Kingdom of Cambodia, instructed the Party committee and officials at every level to make efforts in successfully implementing major and immediate tasks aimed at resolutely defending peace, national independence, sovereignty, while driving the country's development further. Measures are taken to strengthen implementation of democracy and to elevate rights and freedom of the people in the framework of laws and Constitution to prevent the color revolution from occurring and causing turmoil and disaster for the country. Actions are taken for maintaining security, social order, eliminating negative phenomena, such as drugs, and other crimes – forest, fisheries, claiming state land, illegal mining, off-the-record checkpoints, etc.

The congress adopted measures to raise high quality of public service provision for the people and to end negative actions causing anger among our people. At the same time, further implement social protection policy, especially every measures taken by the Royal Government to ensure our people's better livelihood. The congress also noted that agricultural produces' prices must be of serious consideration. Every party officials must make efforts to make themselves good servants of the people and to resolve people's difficulties in a timely manner, while adhering persistently "the approach to reflect oneself in mirror, take a bath, rub of dirt, take treatment, and have operation" in order to win people's confidence on the Party.

It is true that going through certain events caused by the opposition party and ill-willed circles attempting to bring our nation to a new turmoil, the people of Cambodia see clearly the long-term leading role of the Cambodian People's Party to guarantee peace, stability, national unity, democracy, and development. Based on these developments, the party organizations at every level, sector, their members, must ensure a highly strengthened unity in view, in position, and action, and must hold tight and understand clearly resolutions of the nationwide representatives' extraordinary congress, and make effort to transform them into concrete results for the supreme interest of our country and people. The Party official of every level must make efforts to strengthen strand of great solidarity, to collaborate and fulfil our tasks synchronously, and to intervolve as one from top to bottom to secure victory in the forthcoming elections./.

*THE PRACHEACHUN MAGAZINE*

# កម្ពុជាកំពុងដើរទៅមុខក្នុងក្របខណ្ឌ នៃប្រជាធិបតេយ្យ និងនីតិរដ្ឋ

បច្ចុប្បន្ននេះ ប្រជាជនកម្ពុជាបាននឹងកំពុងរស់នៅក្នុងសុខសន្តិភាព និងភាពសុខដុមរមនានៅក្នុងសង្គម ជាតិមួយដែលកំពុងតែមានដំណើរការអភិវឌ្ឍលើគ្រប់វិស័យ ហើយសមិទ្ធផលធំៗជាច្រើនបានកើតឡើង ដែលទាំងអស់នេះបានឆ្លុះបញ្ចាំងឲ្យឃើញច្បាស់អំពីការដឹកនាំដ៏ត្រឹមត្រូវរបស់គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជានារយៈពេលកន្លងមក ។ ដោយផ្ដើមចេញពីនេះ ប្រជាជនកម្ពុជាបានសម្ដែងការសាទរ ដោយអស់ពីចិត្តពីថ្លើម ចំពោះចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទប់ស្កាត់ឧបាយកល និងសកម្មភាពឧទ្ទាមរបស់ពួកប្រឆាំងដែលបានបង្កើតឲ្យមានបដិវត្តន៍ពណ៌ បង្កអស្ថិរភាពក្នុងសង្គម បំផ្លាញលទ្ធិប្រជាធិបតេយ្យ ប៉ុនប៉ងផ្ដួលរំលំរាជរដ្ឋាភិបាលស្របច្បាប់នាពេលកន្លងមក ។ ប្រជាជនកម្ពុជាបានចូលរួមគាំទ្រចំពោះសកម្មភាព និងការប្ដេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការការពារដាច់ខាតរាល់សមិទ្ធផលរបស់សង្គមជាតិ ការពារឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី ការពារសន្តិភាព និងស្ថិរភាពនយោបាយ ការពាររាល់សមិទ្ធផលរបស់សង្គមជាតិឲ្យបន្តស្ថិតស្ថេរគង់វង្សយូរអង្វែងតរៀងទៅ ។ ដោយសារមានចំណាត់ការផ្លូវច្បាប់ដ៏ត្រឹមត្រូវ និងមានការគាំទ្រយ៉ាងទូលំទូលាយរបស់ប្រជាជន ការគាំទ្រពីកងកម្លាំងប្រដាប់អាវុធ ទើបប្រទេសជាតិយើងត្រូវបានបញ្ចៀសផុតពីគ្រោះមហន្តរាយនៃ បដិវត្តន៍ពណ៌ ហើយបានធ្វើឲ្យរលំរលាយទាំងស្រុងអង្គការចាត់តាំងរបស់ពួកនេះ ។ ការរំលាយគណបក្សសង្គ្រោះជាតិ និងការហាមឃាត់មនុស្សចំនួន ១១៨នាក់ ដែលជាថ្នាក់ដឹកនាំរបស់គណបក្សនេះ មិនឲ្យធ្វើសកម្មភាពនយោបាយរយៈពេល៥ឆ្នាំ តាមអំណាចសាលដីកាស្ថាពររបស់តុលាការកំពូលថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៧ គឺជាការជីកកប់ចលនាជ្រុលនិយមនេះឲ្យវិនាសអន្តរាយទាំងស្រុងពីទឹកដីកម្ពុជា ។

សភាពការណ៍សន្តិសុខ សណ្ដាប់ធ្នាប់ និងសុវត្ថិភាពសង្គម កាន់តែមានភាពល្អប្រសើរ ដែលជាកាលានុវត្តភាពដ៏សំខាន់សម្រាប់ដំណើរការ និងធានាប្រក្រតីភាពនៃគ្រប់ស្ថាប័នក្នុងសង្គម ។ ព្រះរាជាណាចក្រកម្ពុជាបានប្រារព្ធពិធីបុណ្យជាតិធំៗ និងពិធីបុណ្យដទៃទៀត ដោយមានប្រជាជនរាប់លាននាក់ចូលរួម និងការធ្វើដំណើរកំសាន្តទេសចរណ៍ទូទាំងប្រទេស ដោយក្ដីសប្បាយរីករាយ ។ ប្រជាជនកម្ពុជាកាន់តែ និងកំពុងតែមានឱកាសច្រើនឡើងៗក្នុងការស្វែងរកការងារ និងការបង្កើនប្រាក់ចំណូល ព្រមទាំងកំពុងទទួលបាននូវផលប្រយោជន៍ពីគោលនយោបាយជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញក្នុងគោលដៅដោះស្រាយការលំបាកក្ដីកង្វល់ និងបំណងប្រាថ្នារបស់ប្រជាជន ក៏ដូចជាដោះស្រាយបញ្ហាប្រឈមរបស់ជាតិទាំងបញ្ហាសង្គម និងបញ្ហាសេដ្ឋកិច្ច ។ វេទិកាអន្តរជាតិធំៗជាច្រើនត្រូវបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា រួមជាមួយនឹងដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់បរទេសមួយចំនួនមកកាន់កម្ពុជា និងដំណើរទស្សនកិច្ចរបស់ប្រមុខដឹកនាំកម្ពុជាទៅកាន់ប្រទេសជាមិត្ត បង្កើតទំនាក់ទំនងសហប្រតិបត្តិការលើគ្រប់វិស័យជាមួយគ្នា បានផ្ដល់ផលប្រយោជន៍ជាច្រើនសម្រាប់ប្រទេសយើង ។ លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការគោរពសិទ្ធមនុស្ស រួមទាំងសិទ្ធចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ចសង្គម របស់ប្រជាជនកំពុងមានជំហានរីកលូតលាស់យ៉ាងលឿន ព្រមជាមួយនឹងការពង្រឹងយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នីតិរដ្ឋស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជានៅតែរក្សាការប្ដេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីធានាឲ្យការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលនឹងត្រូវរៀបចំធ្វើឡើងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ដំណើរការជាប្រក្រតី ។ គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត កំពុងបំពេញការងាររបស់ខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់ដោយច្បាប់ ។ គណបក្សនយោបាយចំនួន៤ បានចុះឈ្មោះបោះឆ្នោតជ្រើសតាំងព្រឹទ្ធសភានាពេលខាងមុខ ហើយក៏មានគណបក្សជាច្រើនទៀតត្រៀមលក្ខណៈសម្បត្តិរួចស្រេចដើម្បីចូលរួមការប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ប៉ុន្តែពួកប្រឆាំងដែលវិនាសខ្ចាត់ខ្ចាយពីក្នុងប្រទេសរត់ទៅបង្កើតចលនាឧទ្ទាមនៅក្រៅប្រទេស បាននាំគ្នា ឃោសនាភូតកុហកថា ប្រទេសជាតិស្ថិតក្នុងស្ថានភាពច្របូកច្របល់ត្រូវតែពន្យាការបោះឆ្នោត ។ នេះជាការឃោសនាបោកប្រាស់យ៉ាងថោកទាបបំផុត ល្ងង់ខ្លៅបំផុត និងចង្រៃឧត្បាតបំផុត ។ តើអ្នកណាជឿទៅកើត ? នៅពេលដែលប្រជាជនកម្ពុជាកំពុងរស់នៅប្រកបដោយសុខសន្តិភាព ពួកអ្នកឃោសនាដែលជាក្រុមក្បត់ជាតិជាក្រុមរត់ចោលប្រទេសបែរជាទៅប្រកូកប្រកាសឲ្យបរទេសផ្ដាច់ជំនួយ និងឈប់ទិញទំនិញពីកម្ពុជា អំពាវនាវឲ្យបរទេសដាក់ទណ្ឌកម្មមកលើប្រទេសខ្លួនឯងថែមទៀត ហើយថែមទាំងនិយាយបោកប្រាស់ទាំងងងើល ថាប្រទេសជាតិកំពុងវឹកវរ ។ គ្រាន់តែប៉ុណ្ណឹងយើងអាចមើលឃើញច្បាស់ពីឧបាយកលរបស់ពួកនេះ ហើយអាចធ្វើការប្រៀបធៀបបានអំពីសកម្មភាពដែលពួកគេធ្វើកន្លងមក គឺសុទ្ធតែដើម្បីបម្រើឲ្យមហិច្ឆតានយោបាយដ៏កខ្វក់របស់ខ្លួនតែប៉ុណ្ណោះ មិនបានគិតគូរសូម្បីតែបន្តិចនូវផលប្រយោជន៍ជាអាយុជីវិតរបស់ប្រជាជន និងប្រទេសជាតិ ។

**សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជាបានបញ្ជាក់ច្បាស់ហើយថា៖ «**សភាពការណ៍នៅក្នុងប្រទេសកម្ពុជាកំពុងដើរទៅមុខក្នុងក្របខណ្ឌនៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ។ ឆ្នាំថ្មីនេះយើងក៏ត្រូវខិតខំធ្វើយ៉ាងណាឲ្យសេដ្ឋកិច្ចរបស់យើងកាន់តែរឹងមាំ ធ្វើឲ្យសេដ្ឋកិច្ចរបស់យើងកាន់តែលូតលាស់ ធ្វើឲ្យសន្តិសុខសណ្ដាប់ធ្នាប់សង្គមរបស់យើងកាន់តែត្រូវបានធានា ហើយការរៀបចំការបោះឆ្នោតទាំងព្រឹទ្ធសភានៅខែក្រោយ និងការបោះឆ្នោតនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ ត្រូវធ្វើឲ្យបានល្អក្នុងសុខសន្តិភាព តម្លាភាព ប្រជាធិបតេយ្យ ដែលបណ្ដាបក្សនយោបាយនឹងចូលរួមយ៉ាងច្រើន**» ៕

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

**មហាសន្និបាតវិសាមញ្ញ**
**តំណាងទូទាំងប្រទេស**

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

# សេចក្តីសម្រេចចិត្ត
# នៃមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេស
# របស់គណបក្សប្រជាជនកម្ពុជា

មហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្សប្រជាជនកម្ពុជា បានដំណើរការ ពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានគណបក្ស សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានកិត្តិយសគណបក្ស** និងគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល។ តំណាងដែលបានអញ្ជើញចូលរួមមហាសន្និបាត រួមមានសមាជិក សមាជិកានៃគណៈកម្មាធិការកណ្តាល មន្ត្រីគណបក្សជាសមាជិក សមាជិកានៃរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល មន្ត្រីជាន់ខ្ពស់ និងតំណាងនៃគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័នរាជធានីខេត្តក្រុងស្រុកខណ្ឌព្រមទាំងបណ្តាអង្គការមហាជនរបស់គណបក្សដែលមានចំនួនសរុប២.៤០៨រូប។

មហាសន្និបាត សូមសម្តែងគារវភក្តីភាព និងកតញ្ញុតាធម៌ដ៏ជ្រាលជ្រៅបំផុតថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលកំពុងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់នៃប្រជាជាតិខ្មែរ និងសូមថ្វាយព្រះពរ**ព្រះករុណាជាអម្ចាស់** និង **សម្តេចព្រះវររាជមាតា** មានព្រះរាជសុខភាពបរិបូរ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំនាវាកម្ពុជាឆ្ពោះទៅកាន់ត្រើយវឌ្ឍនភាពដ៏រុងរឿងជានិច្ចនិរន្តរ៍។

មហាសន្និបាត បានដំណើរការស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់គណបក្ស ក្នុងស្មារតីឯកភាពខ្ពស់ និងប្រកបដោយលក្ខណៈប្រជាធិបតេយ្យដ៏ទូលំទូលាយ ហើយបានចេញសេចក្តីសម្រេចចិត្ត ដូចតទៅ ៖

**១**. មហាសន្និបាតបានពិភាក្សាយ៉ាងល្អិតល្អន់ និងអនុម័តជាឯកច្ឆ័ន្ទនូវ **"របាយការណ៍នយោបាយ ស្តីពីសភាពការណ៍ទូទៅ និងការងារគណបក្សឆ្នាំ ២០១៧ និងទិសដៅភារកិច្ចឆ្នាំ ២០១៨"** ដោយបានធ្វើការវាយតម្លៃប្រកប ដោយមោទនភាពបំផុតចំពោះការរីកចម្រើនលើគ្រប់វិស័យនៃសង្គមជាតិ នៅលើមាគ៌ាសន្តិភាព ប្រជាធិបតេយ្យ នីតិរដ្ឋ សហប្រតិបត្តិការ និងអភិវឌ្ឍន៍ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥នៃរដ្ឋសភា។

ក្នុងការវាយតម្លៃសភាពការណ៍ទូទៅ មហាសន្និបាតបានកត់សម្គាល់ថា ៖

+ ឧបាយកលបដិវត្តន៍ពណ៌របស់អតីតគណបក្សប្រឆាំង ដែលជ្រោមជ្រែងដោយមជ្ឈដ្ឋានអគតិពីខាងក្រៅ

ប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ត្រូវបានរាំងស្កាត់ទាន់ពេលវេលា តាមរយៈវិធានការច្បាប់ដ៏មុឺងម៉ាត់ និងមានប្រសិទ្ធភាព។ លើមូលដ្ឋាននេះ យើងបានការពារយ៉ាងរឹងមាំនូវឯករាជ្យ និងអធិបតេយ្យជាតិ រក្សាបានសន្តិភាព ស្ថិរភាពនយោបាយ និងឯកភាពជាតិ ព្រមទាំងធានាឲ្យដំណើរការនៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស នៅកម្ពុជាកាន់តែបន្តរីកចម្រើនទៅមុខតាមគន្លងដ៏ត្រឹមត្រូវ។

+ ខឿនការពារជាតិរបស់ប្រជាជន និងខឿនសន្តិសុខជាតិកាន់តែត្រូវបានពង្រឹង ដែលបានធានាដល់កិច្ចការពារបូរណភាពទឹកដី ការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម និងការរស់នៅដ៏សុខសាន្តរបស់ប្រជាជន ព្រមទាំងបង្កលក្ខណៈអំណោយផលដល់ដំណើរការនៃគ្រប់ស្ថាប័នក្នុងសង្គម ទាំងស្ថាប័នសាធារណៈ ស្ថាប័នឯកជន ក៏ដូចអង្គការនានានៃសង្គមស៊ីវិល។

+ ការលើកកម្ពស់អភិបាលកិច្ចល្អនៃស្ថាប័នសាធារណៈនៅគ្រប់ថ្នាក់ ត្រូវបានយកចិត្តទុកដាក់ធ្វើការពង្រឹង និងកែលម្អជាប្រចាំ តាមរយៈការបន្តជំរុញអនុវត្តយ៉ាងសកម្មប្រកបដោយផ្លែផ្កានូវកម្មវិធីកែទម្រង់នានា ដើម្បីបម្រើសំណូមពរនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងតម្រូវការរបស់ប្រជាជន។

+ អាស្រ័យដោយការរក្សាបានសន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខដ៏រឹងមាំ បានធានាឲ្យកម្ពុជាសម្រេចបានលទ្ធផលដ៏ល្អប្រសើរក្នុងដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។ ជាក់ស្តែង ក្នុងរយៈពេលជាងពីរទសវត្សចុងក្រោយនេះ សេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័សដោយបានសម្រេចកំណើនខ្ពស់ប្រកបដោយចីរភាព សមធម៌ បរិយាប័ន្ន និងធន់នឹងវិបត្តិ។ រចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា

កំពុងតែផ្លាស់ប្តូរពីប្រទេសពឹងផ្អែកតែលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកលើវិស័យឧស្សាហកម្ម និងសេវាកម្ម។ ជាពិសេស កម្ពុជាបានសម្រេចនូវបង្គោលចរមួយដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន គឺបានប្រែក្លាយពីប្រទេសមានប្រាក់ចំណូលទាប ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប និងកំពុងបន្តដំណើរឈានទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។ លើមូលដ្ឋានលទ្ធផលដ៏ល្អប្រសើរនេះ បានធ្វើឲ្យប្រជាជនគ្រប់ស្រទាប់នៅទូទាំងប្រទេសកាន់តែមានឱកាសក្នុងការស្វែងរកការងារ និងក្នុងការបង្កើនប្រាក់ចំណូលលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួន។ ព្រមជាមួយនេះរាជរដ្ឋាភិបាលក៏បានដាក់ចេញ និងអនុវត្តដោយប្រសិទ្ធភាពនូវវិធានការគោលនយោបាយយ៉ាងច្រើនជាបន្តបន្ទាប់ សំដៅដោះស្រាយការ លំបាកកង្វល់ និងបំណងប្រាថ្នារបស់ប្រជាជន ក៏ដូចជាការដោះស្រាយបញ្ហាប្រឈមផ្សេងៗរបស់ជាតិ ទាំងបញ្ហាសង្គម ទាំងបញ្ហាសេដ្ឋកិច្ច។

\+ ចំពោះទំនាក់ទំនងអន្តរជាតិ នៅក្នុងស្ថានភាពដែលសភាពការណ៍តំបន់ និងពិភពលោកមានការវិវត្តន៍យ៉ាង ស្មុគស្មាញ កម្ពុជាអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនយោបាយការបរទេសដែលផ្តោតលើការការពារឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី អព្យាក្រឹតភាព និងគោលការណ៍សន្តិសហវិជ្ជមាន ព្រមទាំងការពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដោយផ្អែកលើមូលដ្ឋានស្មើភាព ស្មើសិទ្ធិ គោរពផលប្រយោជន៍គ្នាទៅវិញទៅមក មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងផងគ្នា ហើយបន្តចូលរួមដ៏សកម្មក្នុងចលនានានារបស់តំបន់ និងពិភពលោក ដើម្បីសន្តិភាព ស្ថិរភាព និងវិបុលភាព។ តាមរយៈនេះ កម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដើម្បីពន្លឿនការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនឲ្យបានចប់សព្វគ្រប់ ធ្វើឲ្យតំបន់ព្រំដែនទាំងអស់ជាតំបន់សន្តិភាព ស្ថិរភាព មិត្តភាព សហប្រតិបត្តិការ និងអភិវឌ្ឍន៍។ កម្ពុជា បានពង្រឹងពង្រីកចំណងទាក់ទង និងកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយបណ្តាប្រទេសដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិនានា ដែលបានលើកកម្ពស់កិត្យានុភាពជាតិ និងពង្រីកភាពអនុគ្រោះសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

ប្រការខាងលើនេះបានបង្ហាញឲ្យឃើញច្បាស់នូវជោគជ័យរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់ខ្លួន។

**២**. ដើម្បីបន្តបំពេញបេសកកម្មបម្រើជាតិ និងប្រជាជនឲ្យសម្រេចបានសមិទ្ធផលកាន់តែធំធេងឡើងនោះ មហាសន្និបាតបានអនុម័តជាឯកច្ឆ័ន្ទ និងប្រកាសជូនជនរួមជាតិនូវ **"កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា សម្រាប់ការកសាង និងការពារមាតុភូមិ ឆ្នាំ ២០១៨-២០២៣"** ដោយផ្អែកលើមូលដ្ឋានសមិទ្ធផលនៃសង្គមជាតិដែលសម្រេចបានក្នុងរយៈពេល ៣៩ឆ្នាំ មកនេះ និងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជនកម្ពុជា ព្រមទាំងគោលការណ៍ជាក់ស្តែងក្នុងប្រទេស និងការវិវត្តន៍នៃសភាពការណ៍អន្តរជាតិបច្ចុប្បន្ន។

កម្មវិធីនយោបាយរបស់គណបក្សបានចែងច្បាស់អំពីបណ្តាគោលដៅជាយុទ្ធសាស្ត្រ និងគោលនយោបាយធំៗជាអាទិភាពដែលត្រូវព្យាយាមសម្រេចឲ្យបាន គឺ ៖

- ការការពារយ៉ាងរឹងមាំឯករាជ្យអធិបតេយ្យបូរណភាពទឹកដីនិងសន្តិភាពដើម្បីធានាការអភិវឌ្ឍប្រទេសជាតិនិងភាពសុខដុមរមនារបស់ប្រជាជន
- ការលើកកម្ពស់ជីវភាពរបស់ប្រជាជនគ្រប់រូបទាំងខាងសម្ភារៈ និងស្មារតីឲ្យបានសមរម្យប្រកប ដោយភាពថ្លៃថ្នូរ
- ការការពាររបបរាជានិយម លើកស្ទួយលទ្ធិប្រជាធិបតេយ្យ សិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពច្បាប់
- ការពង្រឹងរដ្ឋបាលសាធារណៈនៅគ្រប់ថ្នាក់ ជារដ្ឋបាលរបស់ប្រជាជន និងបម្រើផលប្រយោជន៍របស់ប្រជាជន
- ការបន្តជំរុញការកែទម្រង់ ស៊ីជម្រៅ និងទូលំទូលាយ ដើម្បីធានាអភិបាលកិច្ចល្អនៅគ្រប់ស្ថាប័នសាធារណៈ
- ការបន្តជំរុញការអភិវឌ្ឍសង្គម សេដ្ឋកិច្ចឲ្យមានការរីកចម្រើនប្រកបដោយចីរភាព សមធម៌ និងបរិយាប័ន្ន
- ការពង្រឹងខឿនការពារជាតិរបស់ប្រជាជន ការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមឲ្យបានរឹងមាំ
- និងការពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយបណ្តាប្រទេស បន្តជំរុញសមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក។

**៣**. ក្នុងគោលដៅលើកកម្ពស់សមត្ថភាពដឹកនាំរបស់គណបក្ស ឲ្យស្របទៅនឹងសំណូមពរនៃសភាពការណ៍ និងភារកិច្ចនាដំណាក់កាលថ្មីនេះ មហាសន្និបាតសម្រេចកែសម្រួលរចនាសម្ព័ន្ធនៃគណៈកម្មាធិការកណ្តាល ពីចំនួន ៥៤៥រូប ដល់ ៨៦៥រូប ដោយបានលុបឈ្មោះសមាជិកគណៈកម្មា-ធិការកណ្តាលដែលទទួលមរណភាព ចំនួន ២២រូប និងបោះឆ្នោតជ្រើសតាំងបន្ថែមសមាជិកគណៈកម្មាធិការកណ្តាល ចំនួន ៣៤២រូប។

**៤**. មហាសន្និបាតបានកំណត់ច្បាស់ថា នៅលើមាគ៌ានៃជ័យជម្នះ និងដំណើរឆ្ពោះទៅមុខទៀត គណបក្សប្រជាជនកម្ពុជាចងចាំ និងចារិកទុកជារៀងរហូតនូវពលិកម្ម ស្មារតីលះបង់ និងការចូលរួមយ៉ាងធំធេងរបស់សមាជិក សមាជិកាគណបក្ស យុទ្ធជន យុទ្ធនារីស្នេហាជាតិ និងជនរួមជាតិនៅគ្រប់ទិសទី ក្នុងបុព្វហេតុដ៏ឧត្តុង្គឧត្តមរបស់ជាតិ ហើយគាំទ្រជាឯកច្ឆ័ន្ទចំពោះបេក្ខភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា និងនីតិកាលបន្តបន្ទាប់ទៀត។ មហាសន្និបាតសម្តែងការគោរពចំពោះ**តួនាទីជាប្រវត្តិសាស្ត្រដ៏ឧត្តុង្គឧត្តមរបស់ សម្តេចតេជោ ហ៊ុន សែន ជាស្នូលនៃគណបក្សប្រជាជនកម្ពុជា** និងជាអគ្គមគ្គុទ្ទេសក៏ដ៏ឆ្នើមនៃប្រជាជនកម្ពុជា ដែលបានដឹកនាំប្រទេសឆ្លងកាត់ដំណាក់កាលដ៏សែនលំបាកនានាប្រកបដោយគតិបណ្ឌិត ភាពឈ្លាសវៃ និងភាពអង់អាច សម្រេចបានជោគជ័យដ៏ត្រចះត្រចង់ជូនជាតិ មាតុភូមិ និងប្រជាជន។

តទៅទំព័រទី ៨

# ទិដ្ឋភាពទូទៅ នៃមហាសន្និបាត វិសាមញ្ញតំណាង ទូទាំងប្រទេស របស់គណបក្ស

ថ្ងៃទី ១៩-២១ ខែមករា ឆ្នាំ២០១៨

































តមកពីទំព័រទី ៥

**៥**. មហាសន្និបាត រក្សាខ្ជាប់នូវគោលជំហរដ៏មុតមាំក្នុងការការពារ និងអភិវឌ្ឍប្រព័ន្ធប្រជាធិបតេយ្យសេរី ពហុបក្សនៅកម្ពុជាឲ្យកាន់តែរឹងមាំ ដែលស្របទៅនឹងសំណូមពរជាក់ស្តែងនៃការរីកចម្រើនរបស់សង្គមជាតិ និងការថែរក្សាសន្តិភាព ព្រមទាំងធានានូវសិទ្ធិសេរីភាពគ្រប់យ៉ាងរបស់ពលរដ្ឋ ដោយផ្អែកលើរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។ ក្នុងស្មារតីនេះ គណបក្សប្រជាជនកម្ពុជាចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បណ្តាគណបក្សនយោបាយ និងគ្រប់មជ្ឈដ្ឋានក្នុងសង្គម ក្នុងការរក្សាបរិយាកាសនយោបាយដ៏ល្អប្រសើរ ដើម្បីធានាឲ្យដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី ៤ នៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៨ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៦ នៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៨ ខាងមុខនេះ ប្រព្រឹត្តទៅដោយជោគជ័យ ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលឆ្លុះបញ្ចាំងទាំងស្រុងនូវឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរ។ គណបក្សប្រជាជនកម្ពុជា ស្វាគមន៍អ្នកចូលរួមសង្កេតការណ៍ជាតិ និងអន្តរជាតិ ក្នុងការបោះឆ្នោតទាំងពីរនេះ។

**៦**. មហាសន្និបាត សូមសម្តែងការគោរព និងដឹងគុណដ៏ជ្រាលជ្រៅបំផុត ចំពោះជនរួមជាតិ នៅគ្រប់ទិសទី ដែលបានផ្តល់ជំនឿជឿជាក់ និងការគាំទ្រដ៏រឹងមាំដល់គណបក្សប្រជាជនកម្ពុជា ក្នុងការដឹកនាំប្រទេសរយៈពេល ៣៩ ឆ្នាំ កន្លងទៅនេះ ធ្វើឲ្យគណបក្សប្រជាជនកម្ពុជា បំពេញបានដោយជោគជ័យនូវភារកិច្ចជាប្រវត្តិសាស្ត្ររបស់ខ្លួនក្នុងការស្តារ កសាង អភិវឌ្ឍន៍លើគ្រប់វិស័យ និងការពារមាតុភូមិ។ ព្រមជាមួយនេះ សូមសម្តែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ចំពោះបណ្តាប្រទេសជាមិត្ត សហគមន៍អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់ការឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លាដល់ប្រជាជនកម្ពុជា ដើម្បីបុព្វហេតុសន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ ហើយកំពុងផ្តល់ការជួយឧបត្ថម្ភបន្តទៀត និងពង្រឹងពង្រីកនូវកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាជាមួយកម្ពុជា។

**៧**. មហាសន្និបាត សូមអំពាវនាវដល់គណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក មន្ត្រី និងសមាជិក សមាជិកាគណបក្សគ្រប់រូប សូមប្រកាន់ខ្ជាប់ស្មារតីថែរក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុងរឹងមាំ ហើយខិតខំអនុវត្តរាល់ទិសដៅ ភារកិច្ចដែលមហាសន្និបាតបានលើកឡើងឲ្យបានសម្រេច ដែលឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជនយើង។ ព្រមជាមួយនេះ មហាសន្និបាត សូមអំពាវនាវដល់ជនរួមជាតិនៅគ្រប់ទិសទី និងមជ្ឈដ្ឋានចម្រើនជឿនលឿនទាំងអស់នៅក្នុងសង្គម បន្តរួមគ្នាពង្រឹងផ្លុងមហាសាមគ្គីជាតិក្រោមដំបូលរដ្ឋធម្មនុញ្ញ និងម្លប់ដ៏ត្រជាក់នៃអង្គព្រះមហាក្សត្រជាទីសក្ការៈដ៏ខ្ពស់ខ្ពស់បំផុតនៃយើង ពុះពារថែរក្សាការពាររាល់សមិទ្ធផលរបស់ជាតិ ជាពិសេស ថែរក្សាសន្តិភាពឲ្យបានរឹងមាំស្ថិតស្ថេរគង់វង្ស ជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឲ្យកាន់តែចម្រើនលូតលាស់ឡើង ហើយចូលរួមដ៏សកម្មធ្វើឲ្យដំណើរការបោះឆ្នោតនាពេលខាងមុខនេះ ប្រព្រឹត្តទៅយ៉ាងល្អក្នុងសុខសន្តិភាព តម្លាភាព និងប្រជាធិបតេយ្យ។

មហាសន្និបាត ប្រគល់ភារកិច្ចជូនគណៈកម្មាធិការកណ្តាល ដើម្បីដឹកនាំអនុវត្តសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសនាពេលនេះ ឲ្យទទួលបានជោគជ័យ បង្កើតឡើងនូវសមិទ្ធផលធំៗថ្មីៗទៀតជូនជាតិ មាតុភូមិ និងប្រជាជនកម្ពុជា។

*ថ្ងៃអាទិត្យ ៥កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១*
*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១៨*





**សូមគោរពឯកឧត្តម លោកជំទាវ និងប្រិយមិត្តអ្នកអានជាទីគោរព**
**សូមចូលមក** Facebook Page : Pracheachun Magazine-**ទស្សនាវដ្ដីប្រជាជន**
**ហើយចុច** Like **និង** Share **ដើម្បីទទួលបានព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ព្រមទាំងផ្តល់ទស្សនៈ ឬ មតិផ្សេងៗ**

# ប្រជាជនកម្ពុជាប្រារព្ធពិធីមីទ្ទិញអបអរសាទរ ខួបអនុស្សាវរីយ៍លើកទី៣៩ ទិវាជ័យជម្នះ ៧ មករា ដោយជោគជ័យ

## ✵ ក្នុងរយៈពេល៣៩ ឆ្នាំ គណបក្សប្រជាជនកម្ពុជាបានដឹកនាំប្រទេសឲ្យមានការផ្លាស់ប្តូរដ៏ធំធេងជាប្រវត្តិសាស្ត្រ






*ប្រជាជនជាង ៥ម៉ឺននាក់ចូលរួមក្នុងពិធីមីទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៩ ទិវាជ័យជម្នះ ៧ មករា (៧.១.១៩៧៩-៧.១. ២០១៨)*

ពិធីមីទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៩ ទិវាជ័យជម្នះ ៧ មករា (៧.១.១៩៧៩-៧.១.២០១៨) បានប្រារព្ធធ្វើឡើងយ៉ាងមហោឡារិកនៅព្រឹកថ្ងៃទី៧មករាឆ្នាំ២០១៨នៅមជ្ឈមណ្ឌលកោះពេជ្ររាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា ប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ប្រធានរដ្ឋសភានិងលោកជំទាវ។សម្តេចឯកឧត្តមលោកជំទាវជាសមាជិកសមាជិកា គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល សមាជិកសមាជិកាព្រឹទ្ធសភា រដ្ឋសភា មន្ត្រីរាជការដឹកនាំគ្រប់ថ្នាក់តាមក្រសួង ស្ថាប័ននានា ភ្ញៀវជាតិអន្តរជាតិ សិស្សានុសិស្ស និងប្រជាពលរដ្ឋប្រមាណជាង ៥០.០០០នាក់ និងតំណាងអង្គទូតនៃប្រទេសជាច្រើនប្រចាំនៅកម្ពុជាក៏មានវត្តមាននៅក្នុងពិធីនេះដែរ។

ថ្លែងទៅកាន់អង្គមីទ្ទិញនាឱកាសនោះ **សម្តេចតេជោ ហ៊ុន សែន** បានរំលឹកឡើងវិញអំពីអត្ថន័យនៃទិវា ៧ មករា ឆ្នាំ១៩៧៩ ជាថ្ងៃជ័យជម្នះជាប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជាក្នុងការវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត បញ្ចប់សម័យកាលដ៏ខ្មៅងងឹតបំផុតនៅកម្ពុជា ដែលបានកាប់សម្លាប់ និងធ្វើឲ្យប្រជាពលរដ្ឋខ្មែរស្លាប់ជិត ៣លាននាក់ ។ ថ្ងៃ ៧ មករា ១៩៧៩ បានបើកឡើងវិញនូវទំព័រសករាជថ្មីនៃឯករាជ្យ សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម។សម្តេចតេជោក៏បានរំឮកផងដែរនូវស្មារតីចងចាំជានិច្ចនូវគុណូបការៈដ៏ឧត្តុង្គឧត្តមរបស់វីរៈកម្មាភិបាល យុទ្ធជន យុទ្ធនារី នៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងវិរៈកងទ័ពស្ម័គ្រចិត្តវៀតណាម ដែលបានធ្វើ ការលះបង់យ៉ាងធំធេងក្នុងការប្រយុទ្ធដើម្បីផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត និងការពារការរស់ឡើងវិញ របស់ប្រជាជនកម្ពុជា ។

**សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា ឆ្លងកាត់រយៈពេល ៣៩ឆ្នាំកន្លងមកនេះ បានបង្ហាញច្បាស់ថា ផ្តើម ពីជ័យជម្នះ ៧ មករា ប្រទេសកម្ពុជាបាន និងកំពុងឈានទៅមុខតាមទិសដៅដ៏ត្រឹមត្រូវដែលស្របតាមបំណងប្រាថ្នា ដ៏ពិសិដ្ឋរបស់ប្រជាជន និងដើរស្របជាមួយនិន្នាការរួមក្នុងតំបន់ក៏ដូចពិភពលោក ទោះបីជាត្រូវជួបនឹងការលំបាក និងភាពបត់បែនយ៉ាងច្រើនក្តី ។ សម្តេចតេជោបានបញ្ជាក់ថា កម្ពុជាពីមុនដែលជាវាលពិឃាត ជាសមរភូមិនៃសង្គ្រាមរ៉ាំរ៉ៃ ជាតំបន់អសន្តិសុខគួរឱ្យខ្លាចរអា ឥឡូវបានក្លាយទៅជាទឹកដីសន្តិភាព និងសេរីភាពដែលប្រជាជនបានរស់នៅយ៉ាងសុខដុមរមនា និង ជាតំបន់ទេសចរណ៍មួយប្រកបដោយភាពទាក់ទាញក្នុងតំបន់ និងពិភពលោក ដែលបានទទួលភ្ញៀវទេសចរដល់ប្រមាណ ៥,៦ លាននាក់ ក្នុងឆ្នាំ២០១៧កន្លងទៅនេះ ។ កម្ពុជាពីមុនដែលធ្លាប់គ្របដណ្តប់ដោយអំណាចផ្តាច់ការរបស់ពួកឃាតករ ប៉ុល ពត និងត្រូវគេប្រមាថមើលងាយ ឥឡូវបានក្លាយទៅជាប្រទេសមួយដែលប្រកាន់ខ្ជាប់នូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស លើកតម្កើងសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្សអនុវត្តន៍យ៉ាងទៀងទាត់នូវការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ជានីតិរដ្ឋដែលគោរពគោលការណ៍ច្បាប់ដោយឥតងាករេ និងជា

រដ្ឋអធិបតេយ្យពេញលេញដែលមិនអាចរំលោភបំពានបាន ។ កម្ពុជាពីមុនដែលជាប្រទេសត្រូវទទួលរងការហ៊ុំព័ទ្ធទាំងខាងសេដ្ឋកិច្ច និងនយោបាយ ឥឡូវនេះបានក្លាយជាប្រទេសមួយដែលកំពុងសមាហរណកម្មខ្លួនយ៉ាងសកម្មទៅក្នុងតំបន់ និងពិភពលោកមានចំណងមិត្តភាព និងសហប្រតិបត្តិការដ៏ល្អប្រសើរ ហើយកំពុងចូលរួមបំពេញតួនាទីយ៉ាងសកម្មដោយស្មើសិទ្ធិ និងស្មើភាពក្នុងគ្រប់កិច្ចការអន្តរជាតិ ទាំងក្នុងក្របខណ្ឌតំបន់ និងពិភពលោក ។ កម្ពុជាពីមុនដែលធ្លាប់ទទួលកងកម្លាំងរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិមកជួយប្រទេសរបស់ខ្លួន តែរយៈពេលជាងមួយទសវត្សកន្លងមកនេះបានបញ្ជូនកងកម្លាំងរក្សាសន្តិភាពរបស់ខ្លួន ទៅចូលរួមក្នុងការរក្សាសន្តិភាពនៅប្រទេសជាច្រើន ក្នុងក្របខ័ណ្ឌប្រតិបត្តិការនៃអង្គការសហប្រជាជាតិ ។ កម្ពុជាពីមុនដែលខឿនសេដ្ឋកិច្ចជាតិត្រូវបំផ្លាញខ្ទេចខ្ទីគ្របដណ្តប់ដោយភាពក្រីក្រ និងខ្វះខាតស្បៀងអាហារយ៉ាងធ្ងន់ធ្ងរ ឥឡូវនេះបានក្លាយជាប្រទេសនាំអង្ករចេញ ហើយស្ថិតក្នុងចំណាត់ថ្នាក់នៃប្រទេស ដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ដោយមានអត្រាកំណើនជាមធ្យម ៧,៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ព្រមទាំងសម្រេចបាននូវវឌ្ឍនភាពដ៏ល្អប្រសើរក្នុងការកាត់បន្ថយភាពក្រីក្រ ។

ទាំងអស់នេះ ជាការផ្លាស់ប្តូរដ៏ធំធេងជាប្រវត្តិសាស្ត្រនៃកម្ពុជាក្នុងរយៈពេលជិត៤ទសវត្សរ៍ចុងក្រោយនេះ ដែលកើតចេញពីការដឹកនាំដ៏ត្រឹមត្រូវរបស់គណបក្សប្រជាជនកម្ពុជា ពីការចូលរួមដោយទឹកចិត្តស្នេហាជាតិដ៏ពុះពោររបស់ប្រជាជនគ្រប់ស្រទាប់ គ្រប់ជនជាតិ គ្រប់ជំនឿសាសនា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កសិករ កម្មករ អាជីវករ ពលករទូទៅ និងមជ្ឈដ្ឋានជឿនលឿននានាក្នុងសង្គម ក្នុងដំណើរការស្តារ កសាង និងការពារមាតុភូមិ ព្រមទាំងការជួយឧបត្ថម្ភ ដ៏ស្មោះសពីសំណាក់បណ្តាប្រទេសជាមិត្តជិត ឆ្ងាយ និងសហគមន៍អន្តរជាតិ ។

**សម្តេចតេជោ ហ៊ុន សែន** បានថ្លែងបន្តទៀតថា កម្ពុជាបានសម្រេចនូវបង្គោលចលករដ៏សំខាន់មួយនៅ ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន គឺបានប្រែក្លាយពីប្រទេសមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយកំពុងបន្តដំណើរឈានទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ។ សម្តេចតេជោបានបន្ថែម ទៀតថា ទាំងនេះជាការផ្លាស់ប្តូរដ៏ធំធេងជាប្រវត្តិសាស្ត្រនៃកម្ពុជាក្នុងរយៈពេលជិត ៤ទសវត្សរ៍ចុងក្រោយនេះ ដែលកើតចេញពីការដឹកនាំដ៏ត្រឹមត្រូវរបស់គណបក្សប្រជាជនកម្ពុជា ពីការចូលរួមដោយទឹកចិត្តស្នេហាជាតិដ៏ពុះពោរ របស់ប្រជាជនគ្រប់ស្រទាប់ គ្រប់ជនជាតិ គ្រប់ជំនឿសាសនា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កសិករ កម្មករ អាជីវករ ពលករទូទៅ និងមជ្ឈដ្ឋានជឿនលឿននានាក្នុងសង្គម ក្នុងដំណើរការស្តារកសាង និងការពារមាតុភូមិ ព្រមទាំងការជួយឧបត្ថម្ភដ៏ស្មោះសពីសំណាក់បណ្តាប្រទេសជាមិត្តជិតឆ្ងាយ និងសហគមន៍អន្តរជាតិ ។

សម្តេចតេជោបានបញ្ជាក់ទៀតថា ៣៩ឆ្នាំកន្លងទៅនេះ គឺ ៣៩ឆ្នាំនៃសាមគ្គីភាព វីរៈភាព និងជ័យជម្នះ ។ ការខិតខំពុះពាររបស់យើងក្នុងរយៈពេល ៣៩ឆ្នាំមកនេះ បានកែប្រែមាតុភូមិយើងពីគំនរផេះផង់ឲ្យរស់ឡើងវិញ និងរីកចម្រើនលូតលាស់ប្រកបដោយមោទនភាពបំផុត ដែលបានពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ឲ្យយើងឈានទៅសម្រេចនូវគោលដៅដ៏ឧត្តុង្គឧត្តមគឺ "**កម្ពុជាមួយឯករាជ្យ សន្តិភាព សេរីភាព អព្យាក្រឹត ប្រជាធិបតេយ្យ និងវឌ្ឍនភាព**" ។ ពិតណាស់ថា ផ្លូវទៅមុខទៀតយើងនៅតែមានឧបសគ្គ ប៉ុន្តែគ្មានឧបសគ្គណាអាចមករារាំងមិនឲ្យយើងសម្រេច បំណងប្រាថ្នាបានឡើយឲ្យតែប្រជាជាតិយើងមានការឯកភាព រួបរួមសាមគ្គីគ្នា បន្តធ្វើដំណើរទៅមុខលើផ្លូវដ៏ត្រឹមត្រូវនេះ ។ សម្តេចតេជោបានបញ្ជាក់យ៉ាងច្បាស់ថា ពិតមែនតែអង្គការចាត់តាំងបដិវត្តន៍ពណ៌ត្រូវបានរំលាយហើយក្តី ប៉ុន្តែឧបាយកលដ៏ពិសពុលនៃមជ្ឈដ្ឋានអគតិខាងក្រៅ ដែលបញ្ជាពីក្រោយខ្នងរបស់ចលនាបដិវត្តន៍ពណ៌នៅកម្ពុជាមិនទាន់ផុតរលត់នៅឡើយ ។ ពួកគេបានប្រើវោហាស័ព្ទនានាដ៏ពិរោះ អំពីប្រជាធិបតេយ្យ សេរីភាព នីតិរដ្ឋ និងមនុស្សធម៌ ប៉ុន្តែសកម្មភាពពិតរបស់គេ គឺបានរាំងខ្ទប់ លទ្ធិប្រជាធិបតេយ្យ សេរីភាព និងនីតិរដ្ឋពិតប្រាកដមិនឱ្យរីកចម្រើន ដោយជ្រើសរើសយកបុគ្គលមួយចំនួន ដែលប្រឆាំងនឹងរាជរដ្ឋាភិបាលលើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធព័ត៌មានមួយចំនួនដែលបានបំពានច្បាប់ ។ ផ្ទុយទៅវិញគេបោះបង់ប្រជាជនកម្ពុជា និងយកប្រជាជនកម្ពុជាធ្វើជាចំណាប់ខ្មាំងនៃនយោបាយរបស់ខ្លួន ។ សកម្មភាពបែបនេះក៏មិនមែនជាចំណុចថ្មីដែរ គឺជាអ្វីដែលគេធ្លាប់បានធ្វើក្នុងទសវត្សរ៍ ៨០កន្លងមក ដោយប៉ុនប៉ងសម្លាប់អតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា ទាំងតាមផ្លូវយោធា សេដ្ឋកិច្ច និងនយោបាយ ។ មជ្ឈដ្ឋានបរទេសទាំងនោះដែលធ្វើជាមើលមិនឃើញ តថភាពនៅកម្ពុជាកំពុងព្យាយាមបិទបាំងការបរាជ័យរបស់ខ្លួន បន្តរកវិធីដាក់ការកៀបសង្កត់មកលើរាជរដ្ឋាភិបាលកម្ពុជា ឱ្យធ្វើតាមឆន្ទៈរបស់ខ្លួននៅក្រោមលេសប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស និងតាមរយៈការគំរាមការកាត់ផ្តាច់ជំនួយ និងវិធានការរឹតបន្តឹងផ្សេងៗ ដែលជាការជ្រៀតជ្រែកយ៉ាងកម្រោលមកលើដែនសមត្ថកិច្ចរបស់រដ្ឋ - អធិបតេយ្យមួយ ។

**សម្តេចតេជោ ហ៊ុន សែន** បានថ្លែងសង្កត់ធ្ងន់ថា ក្នុងនាមជារដ្ឋអធិបតេយ្យ កម្ពុជាមិនឱនក្បាលទទួល យកការកៀបសង្កត់ណាមួយពីខាងក្រៅបានឡើយ ជាពិសេសមិនទុកឱ្យការប៉ុនប៉ងផ្លាស់ប្តូរតាមរយៈបដិវត្តន៍ពណ៌ កើតមានជាដាច់ខាត ដែលនយោបាយបែបនេះបាននិងកំពុងបង្កនូវជម្លោះផ្ទៃក្នុងអស្ថិរភាពអសន្តិសុខសង្គ្រាម ទុក្ខវេទនា ការរត់ភៀសខ្លួន និងការបាត់បង់ជីវិតប្រជាជនស្លូតត្រង់រាប់សែននាក់យ៉ាងអយុត្តិធម៌បំផុតនៅប្រទេសមួយចំនួន ។ កម្ពុជាមានមេរៀនគ្រប់គ្រាន់ហើយ ដើម្បីធានានូវដំណើរទៅមុខទៀតរបស់ខ្លួន ដោយឈរលើមូលដ្ឋានការពារឯករាជ្យ អធិបតេយ្យ និងក្តាប់ជាប់សិទ្ធិសម្រេចលើជោគវាសនារបស់ខ្លួន ។ សម្តេចតេជោសង្ឃឹមថា មជ្ឈដ្ឋានទាំងនោះនឹងមើលឃើញការពិត ទទួលយក

ការពិត ហើយនៅជាមួយប្រជាជនកម្ពុជា និងឈប់បង្កើតឧបសគ្គចំពោះមាតុភូមិកម្ពុជាដ៏អភ័ព្វនេះតទៅទៀត ។ **សម្ដេចតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជាបានអះអាងថា ប្រជាធិបតេយ្យពិតប្រាកដនៅកម្ពុជាមិនដើរថយក្រោយ ឬធ្លាក់ចុះឡើយ ផ្ទុយទៅវិញកំពុងត្រូវបានថែរក្សា និងពង្រឹងឱ្យកាន់តែរឹងមាំឡើង ដើរស្របតាមគោលការណ៍នីតិរដ្ឋនៅក្នុងផលប្រយោជន៍របស់ជាតិ និងប្រជាជនកម្ពុជា ។ គឺមានតែប្រជាធិបតេយ្យក្លែងក្លាយទេ ដែលត្រូវលុបបំបាត់ ។ គណបក្សប្រជាជនកម្ពុជាបន្តប្រកាន់ខ្ជាប់នូវរបបនយោបាយប្រជាធិបតេយ្យ សេរី ពហុបក្ស ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ជាតិ ។ គណបក្សនឹងចូលរួមប្រកួតប្រជែងដោយសេរី និងស្មើភាពជាមួយបណ្ដាគណបក្សនយោបាយដែលធ្វើសកម្មភាពស្របច្បាប់នៅកម្ពុជា ក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ ។

**សម្ដេចតេជោ ហ៊ុន សែន** បានថ្លែងបញ្ជាក់ទៀតថា ពេលនេះយើងបានឈានចូលឆ្នាំ២០១៨ ហើយ ដែលជាឆ្នាំទី៥ នៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥ នៃរដ្ឋសភា បន្ទាប់ពីយើងបានសម្រេចនូវសមិទ្ធផលថ្មីៗទៀត យ៉ាងច្រើនក្នុងឆ្នាំកន្លងទៅ៖ ខឿនការពារជាតិរបស់ប្រជាជន និងខឿនសន្តិសុខជាតិត្រូវបានពង្រឹងកាន់តែរឹងមាំ ធានាដល់កិច្ចការពារបូរណភាពទឹកដី ការពារសន្តិភាព ស្ថិរភាពនយោបាយ និងភាពសុខដុមរមនានៃសង្គមជាតិ ។ ជាពិសេសឧបាយកលបដិវត្តន៍ពណ៌របស់គណបក្សប្រឆាំងដែលឃុបឃិតជាមួយបរទេស ប៉ុនប៉ងផ្ដួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ត្រូវបានទប់ស្កាត់ដោយជោគជ័យតាមរយៈវិធានការច្បាប់ដ៏មឺុងម៉ាត់ ។ ក្បាលម៉ាស៊ីនអង្គការចាត់តាំងបដិវត្តន៍ពណ៌នៅកម្ពុជាដែលបានបោកប្រាស និងក្បត់ឆន្ទៈរបស់ប្រជាជនត្រូវបានរំលាយបុគ្គលមួយចំនួន ដែលជាប់ពាក់ព័ន្ធក៏ត្រូវបានតុលាការវិនិច្ឆ័យទោសតាមច្បាប់ជាធរមាន ។ លើមូលដ្ឋាននេះកម្ពុជាបានការពារយ៉ាងរឹងមាំនូវសន្តិភាព ឯករាជ្យ និងអធិបតេយ្យភាពរបស់ខ្លួនបញ្ចៀសគ្រោះមហន្តរាយជាថ្មីសម្រាប់ជាតិ និងធានាដល់ការបន្តលូតលាស់នៃលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋនៅកម្ពុជាតាមគន្លងដ៏ត្រឹមត្រូវ ។ ដំណើរកែទម្រង់រដ្ឋដ៏ស៊ីជម្រៅនៅគ្រប់ថ្នាក់គ្រប់ផ្នែក ត្រូវបានបន្តជំរុញអនុវត្តដោយឆន្ទៈមុតស្រួច និងកាន់តែមានប្រសិទ្ធភាព ដែលបានជះឥទ្ធិពលល្អដល់ការលើកកម្ពស់អភិបាលកិច្ចនៃស្ថាប័នរដ្ឋ ការពង្រឹងយុត្តិធម៌ សមធម៌ក្នុងសង្គម និងការអភិវឌ្ឍប្រទេសជាតិ ព្រមទាំងទទួលបាននូវការសាទរពីប្រជាជន ។ការរក្សាបានសន្តិភាព ស្ថិរភាពនយោបាយនិងសន្តិសុខដ៏រឹងមាំ បានធានាឲ្យកម្ពុជាបន្តសម្រេចបានសមិទ្ធផលធំៗថ្មីៗទៀត ក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងកែលម្អជីវភាពរស់នៅរបស់ប្រជាជន ។ សេដ្ឋកិច្ចកម្ពុជាបាន សម្រេចកំណើន ៦,៩%



*តំណាងអង្គមីទ្ទិញឡើងធ្វើការប្ដេជ្ញាចិត្តចំពោះមុខគណៈអធិបតី*

ក្នុងឆ្នាំ២០១៧ ។ កំណើនដ៏រឹងមាំនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការរីកចម្រើននៃវិស័យឧស្សាហកម្ម កម្មន្តសាល សំណង់ កសិកម្ម និងសេវាកម្មដូចជា ទេសចរណ៍ និងអចលនទ្រព្យជាដើម ។ គួរកត់សម្គាល់ថា កម្ពុជាកំពុងតែផ្លាស់ប្ដូររចនាសម្ព័ន្ធសេដ្ឋកិច្ចពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកលើវិស័យឧស្សាហកម្ម និងសេវាកម្ម ។ កម្ពុជាបានអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រកបដោយភាពប្រុងប្រយ័ត្ន និងធ្វើឲ្យសេដ្ឋកិច្ចមានស្ថិរភាព ហើយបានជំរុញ និងលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ច ភាពប្រកួតប្រជែងព្រមទាំងការផលិត និងការប្រើប្រាស់ក្នុងស្រុក ។ អត្រាប្ដូរប្រាក់មានស្ថិរភាព អត្រាអតិផរណាស្ថិតក្នុងកម្រិតទាប និងអាចគ្រប់គ្រងបានទុនបម្រុងអន្តរជាតិបានកើនជារៀងរាល់ឆ្នាំ អាស្រ័យដោយវិនិយោគផ្ទាល់ពីបរទេសមានកំណើនល្អ ជាមួយគ្នានេះតុល្យភាពជញ្ជីងទូទាត់ក៏មានភាពកាន់តែប្រសើរឡើងដែរ ។ កម្រិតជីវភាពរបស់ប្រជាជនកាន់តែមានភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈសូចនាករសង្គម ជាពិសេសការកើនឡើងនៃ ផ.ស.ស ជាមធ្យមសម្រាប់មនុស្សម្នាក់ពី ១.០៤២ ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៣ ដល់ប្រមាណ ១.៤៣៥ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ ។ អត្រាភាពក្រីក្រមានការធ្លាក់ចុះយ៉ាងខ្លាំងពី ៥៣,៥% ក្នុងឆ្នាំ២០០៤ មកត្រឹម ១៣,៥% ក្នុងឆ្នាំ២០១៤ និងបន្តធ្លាក់ចុះថែមទៀត ហើយជាមួយគ្នានេះគម្លាតនៃប្រាក់ចំណូលរបស់ប្រជាជនក៏មានការធ្លាក់ចុះជាលំដាប់ផងដែរ ។ សម្ដេចតេជោបានអះអាងយ៉ាងម៉ឺងម៉ាត់ថា គណបក្សប្រជាជនកម្ពុជានឹងបន្តធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីសេចក្ដីសុខនិងសុភមង្គលរបស់ជាតិ និងប្រជាជន ។

ពិធីមីទ្ទិញបានបញ្ចប់ប្រកបដោយជោគជ័យ ក្នុងបរិយាកាសសប្បាយរីករាយ ភាតរភាព និងសាមគ្គីភាព យ៉ាងកក់ក្ដៅបន្ទាប់ពីមានការជូនបាច់ផ្កាដល់សម្ដេចអគ្គមហាទាំងពីរ ជាថ្នាក់ដឹកនាំកំពូលរបស់គណបក្សប្រជាជនកម្ពុជា និងជាអគ្គមគ្គុទេសក៍ដ៏ឆ្នើមនៃប្រជាជនកម្ពុជា ពីសំណាក់តំណាងអង្គទូតតំណាងគណបក្សនយោបាយ និងតំណាងក្រសួងស្ថាប័ននានា ៕

# «ទន្លេរបស់យើង ដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព» ជាប្រធានបទនៃកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាងលើកទី២






*ថ្នាក់ដឹកនាំទាំង៦ ប្រទេសអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការ មេគង្គ-ឡានឆាង (Mekong-Lancang) លើកទី២ ក្រោមមូលបទ **"ទន្លេរបស់យើង ដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយ ចីរភាព"***

ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាសហ-ប្រធាន បានអញ្ជើញបើកកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការ មេគង្គ-ឡានឆាង (Mekong-Lancang) លើកទី២ ក្រោមមូលបទ **"ទន្លេរបស់យើង ដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព"** ។ កិច្ចប្រជុំកំពូលនេះមានការអញ្ជើញចូលរួមពីបណ្តាមេដឹកនាំនៃប្រទេសតាមទន្លេមេគង្គ គឺ១-ឯកឧត្តម Li Keqiang នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន ជាសហប្រធាន ២-ឯកឧត្តម Thongloun Sisolith នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ៣-ឯកឧត្តម Myint Swe អនុប្រធានាធិបតីនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ៤-ឯកឧត្តម Prayut Chan-o-cha នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ និង ៥-ឯកឧត្តម Nguyen Xuan Phuc នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ព្រមទាំងគណៈប្រតិភូជាច្រើនរូបទៀត ។

**សម្តេចតេជោ ហ៊ុន សែន** បានសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះថ្នាក់ដឹកនាំប្រទេសទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការ មេគង្គ-ឡានឆាង លើកទី២ ។ សម្តេចតេជោបានមានប្រសាសន៍រំលឹកអំពីកិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការ មេគង្គ-ឡានឆាង លើកទី១ដែលបានធ្វើឡើងនៅទីក្រុងសាន់យ៉ាប្រទេសចិន កាលពីឆ្នាំ២០១៦កន្លងទៅ ។ ក្នុងនោះប្រទេសទាំងអស់បានអនុវត្តនូវរបៀបវារៈជាច្រើនដែលប្រទេសទាំង៦ បានសន្យាថា នឹងខិតខំធ្វើឲ្យយន្តការអនុវត្តតំបន់ទន្លេមេគង្គកាន់តែមានភាពល្អប្រសើរ ជាពិសេសនឹងធ្វើឲ្យមានកិច្ចសហ-ប្រតិបត្តិការពេញលេញដែលនាំមកនូវសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព និងវិបុលភាពសម្រាប់តំបន់មេគង្គទាំងមូល ។ សម្តេចតេជោបានបន្តថា ទន្លេមេគង្គ គឺជាទន្លេដែលមានសារៈសំខាន់បំផុត ដែលបានជួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរាប់លាននាក់ ដែលកំពុងរស់នៅតាមបណ្តោយទន្លេមេគង្គ ។ ទន្លេនេះបានឲ្យយើងបង្កើតវាសនារួមគ្នា ប្រកបដោយភាពជាមិត្តជិតខាង ។ កត្តាទាំងនេះបានជំរុញឲ្យប្រទេសយើងទាំងអស់គ្នា អនុវត្តតាមការសន្យាកន្លងមក ដើម្បីឲ្យក្លាយជាការពិត ហើយថ្ងៃនេះកម្ពុជាពិតជាមានមោទនៈភាព និងមានក្តីរីករាយក្នុងការទទួលស្វាគមន៍ និងរៀបចំកិច្ចប្រជុំកំពូលនេះឡើង ។ សម្តេចតេជោបានបន្ថែមទៀតថា កិច្ចប្រជុំនេះមានន័យជ្រាលជ្រៅណាស់ ដែលមិនមែនជារឿងចៃដន្យទេ ។ យើងបានជ្រើសរើសយកប្រធានបទ **«ទន្លេរបស់យើងដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព»** ដែលបានផ្តល់នូវសារៈសំខាន់ សម្រាប់កិច្ចសហប្រតិ-បត្តិការនៃប្រទេសក្នុងតំបន់មេគង្គ ។ សម្តេចតេជោក៏បានរំលឹកពីការជ្រៀតជ្រែកផ្ទៃក្នុងពីសំណាក់បរទេសកន្លងមក ដែលបានធ្វើឲ្យកម្ពុជាជួបនូវគ្រោះមហន្តរាយអស់រយៈពេលជាច្រើនទសវត្សរ៍ ដែលបានបំផ្លាញអ្វីៗស្ទើរតែទាំងស្រុង ក្នុងនោះ គឺបំផ្លាញស្ថេរភាព និងសន្តិភាពរបស់កម្ពុជា ហើយបានរារាំងដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសជាតិអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ។ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីបានមានប្រសាសន៍បញ្ជាក់អំពីបទពិសោធន៍កន្លងមក ដែលធ្វើអោយយើងសម្រេចបាននូវសន្តិភាពពេញលេញ គឺតាមរយៈការចេះអត់អោនឲ្យគ្នាទៅវិញទៅមក មានការគោរពចំពោះបូរណភាពដែនដី និងអធិបតេយ្យភាពរបស់ផងគ្នា ហើយមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់គ្នាទៅវិញទៅមក ។

បន្ទាប់មកថ្នាក់ដឹកនាំប្រទេសទាំង៦ នៃកិច្ចសហប្រតិបត្តិការ មេគង្គ-ឡានឆាង បានធ្វើការពិភាក្សាលើបញ្ហាសំខាន់ៗដើម្បីជំរុញការអភិវឌ្ឍអនុតំបន់ទន្លេមេគង្គ ដោយផ្តោតជាសំខាន់ទៅលើការ

តាំងចិត្តក្នុងការរក្សាសន្តិភាព ស្ថិរភាព ការអភិវឌ្ឍប្រកបដោយចីរភាព និងវិបុលភាពដែលនាំមកនូវផលប្រយោជន៍សម្រាប់ប្រជាជាតិទាំងអស់ ។ កិច្ចប្រជុំកំពូលនេះក៏បានផ្ដល់សារៈសំខាន់ដល់កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច-សង្គម របស់ប្រទេសអនុតំបន់ ការធ្វើឱ្យប្រសើរឡើងសុខមាលភាពប្រជាជន ការបង្រួញគម្លាតអភិវឌ្ឍន៍ នៅក្នុងចំណោមប្រទេសដើម្បីគាំទ្រដល់សហគមន៍អាស៊ាន និងការជំរុញកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ដើម្បីរួមចំណែកបន្ថែមទៀតដល់ការអនុវត្តរបៀបវារៈឆ្នាំ២០៣០របស់អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ។ កិច្ចប្រជុំឈានដល់ការសម្រេចបានកុងសង់ស៊ីស និងអនុម័តនូវឯកសារសំខាន់ៗចំនួនពីរ គឺ១-សេចក្ដីថ្លែងការណ៍ទីក្រុងភ្នំពេញនៃកិច្ចប្រជុំថ្នាក់ដឹកនាំនៃកិច្ចសហប្រតិបត្តិការ មេគង្គ-ឡានឆាង លើកទី២ និងទី២-ផែនការសកម្មភាព ៥ឆ្នាំ នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ២០១៨-២០២២ ។

មុនបញ្ចប់កិច្ចប្រជុំកំពូលសហប្រតិបត្តិការ មេគង្គ-ឡានឆាង (Mekong-Lancang) លើកទី២ **សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីបានអញ្ជើញចូលរួមក្នុងពិធីផ្ទេរតំណែងម្ចាស់ផ្ទះ និងសហប្រធាននៃកិច្ចសហប្រតិបត្តិការ មេគង្គ-ឡានឆាង សំរាប់ឆ្នាំបន្ទាប់ដែលប្រទេសឡាវជាអ្នកទទួលធ្វើបន្ត ។ **សម្ដេចតេជោ ហ៊ុន សែន** បានមានប្រសាសន៍ថា កម្ពុជាពិតជាមានកិត្តិយសណាស់ដែលបានទទួលធ្វើជាសហប្រធាននិងជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការ មេគង្គ-ឡានឆាង (Mekong-Lancang) លើកទី២ ថ្ងៃនេះជាមួយឯកឧត្ដមនាយករដ្ឋមន្ត្រីចិន **លី ខឺឈាង** ។ ក្នុងអំឡុងពេលនៃការកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការអនុតំបន់មួយនេះ ការលំបាកជាងគេគឺនៅពេលចាប់ផ្ដើម ។ ប៉ុន្តែយើងមិនដែលមានអារម្មណ៍ថាយើងធ្វើកិច្ចការនេះតែម្នាក់ឯងនោះឡើយ យើងតែងតែទទួលបាននូវការឧបត្ថម្ភគាំទ្រ និងភាពជាដៃគូឥតងាករេពីប្រទេសសហប្រធាន ពោលគឺសាធារណរដ្ឋប្រជាមានិតចិន ជាមួយនឹងការចូលរួមចំណែកយ៉ាងសកម្មពីសមាជិកប្រទេសទន្លេ មេគង្គ-ឡានឆាង ទាំងអស់ ។ ជោគជ័យនៃកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការ មេគង្គ-ឡានឆាង លើកទី២នេះ មិនមែនជាជោគជ័យរបស់កម្ពុជាតែម្នាក់ឯងនោះទេ វាគឺជាជោគជ័យរួមរបស់បណ្ដាប្រទេស មេគង្គ-ឡានឆាង ក៏ដូចជាជោគជ័យនៃយន្តការនៃកិច្ចសហប្រតិបត្តិការ មេគង្គ-ឡានឆាង ទាំងមូល ។ សម្ដេចតេជោបានសំដែងនូវសេចក្ដីរីករាយក្នុងការប្រគល់តួនាទី និងភារកិច្ច "សហប្រធាន" ជូនឯកឧត្ដម Thongloun Sisolith នាយករដ្ឋមន្ត្រីឡាវ ។ ក្នុងនាមជាប្រទេសនៅតាមដងទន្លេមេគង្គយើង បានសម្រេចប្រើច្រវ៉ាទុកជានិមិត្តរូបនៃសហប្រធាន នៃកិច្ចសហប្រតិបត្តិការ មេគង្គ-ឡានឆាងនេះ ។ គ្រប់ប្រទេស និងប្រជាពលរដ្ឋនៅតាមដងទន្លេមេគង្គសុទ្ធតែប្រើប្រាស់ច្រវ៉ានេះដូចៗគ្នា, ច្រវ៉ា គឺជានិមិត្តរូបនៃការប្ដេជ្ញាចិត្តរបស់យើងដើម្បីធ្វើដំណើរឆ្ពោះទៅមុខ តាមបណ្ដោយដងទន្លេមេគង្គ ។ ច្រវ៉ានេះដើម្បីអុំទូកកិច្ចប្រតិបត្តិការ មេគង្គ-ឡានឆាង ហើយមានដំណើរទៅមុខកាន់តែលឿនខ្លាំងឡើងថែមទៀត ។ បន្ទាប់មក**សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីបានប្រគល់ច្រវ៉ាទូកជូនទៅឯកឧត្ដម Thongloun Sisolith នាយករដ្ឋមន្ត្រីឡាវ ដើម្បីបន្តវេនរៀបចំកិច្ចប្រជុំនេះនៅឆ្នាំ២០២០ ។ ឯកឧត្ដម Thongloun Sisolith នាយករដ្ឋមន្ត្រីឡាវបានប្ដេជ្ញាចិត្តគាំទ្រចំពោះកិច្ចប្រជុំនេះ និងយល់ព្រមទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំនៅឆ្នាំ ២០២០ ។



*បណ្ដាមេដឹកនាំនៃប្រទេសតាមទន្លេមេគង្គក្នុងកិច្ចប្រជុំកំពូលសហប្រតិបត្តិការ មេគង្គ-ឡានឆាង អញ្ជើញទស្សនាពិពណ៌*

ដោយឡែកនៅក្រៅកិច្ចប្រជុំកំពូលនេះ ក៏មានជំនួបពិភាក្សារវាង **សម្ដេចតេជោ ហ៊ុន សែន** ជាមួយប្រមុខដឹកនាំរដ្ឋាភិបាល ដែលអញ្ជើញចូលរួមផងដែរ ។ ឯកឧត្ដម **ង្វៀន ស៊ុនហ្វ៊ុក** នាយករដ្ឋមន្ត្រីវៀតណាមបានជួបជាមួយ**សម្ដេចតេជោ ហ៊ុន សែន** ដោយមេដឹកនាំទាំងពីរបានកត់សម្គាល់ឃើញរួមគ្នានូវកំណើនសេដ្ឋកិច្ចនៃប្រទេសទាំងពីរកម្ពុជា-វៀតណាម ដែលឆ្នាំ២០១៧ នេះមានចំនួន ៣.៨០០លានដុល្លារអាមេរិក ធៀបនឹងឆ្នាំ២០១៦ កើនឡើង ២៦% ។ ឆ្នាំនេះវៀតណាមបាននាំចូលផលិតផលកសិកម្មពីប្រទេសកម្ពុជាប្រមាណ ១០០០លានដុល្លារអាមេរិក ។ ក្នុងជំនួបដោយឡែកជាមួយលោកឧត្ដមសេនីយ៍ **ប្រាយុទ្ធ ចាន់អូចា** នាយករដ្ឋមន្ត្រីថៃ មេដឹកនាំទាំងពីរបានកត់សម្គាល់ឃើញអំពីទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរ កម្ពុជា-ថៃ ឆ្នាំ២០១៧មាន ៥.៥០០លានដុល្លារ កើនឡើងប្រមាណ ១០% បើធៀបឆ្នាំ២០១៦ ។ ក្នុងជំនួបជាមួយឯកឧត្ដម **ថងលួន ស៊ីសូលីត** មេដឹកនាំទាំងពីរបានសន្យាជំរុញធ្វើយ៉ាងណាឲ្យកិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរមានការរីកបន្ទឹងបន្ថែមទៀត ដើម្បីចំណងមិត្តភាព សាមគ្គីភាព ក្នុងនាមជាប្រទេសភូមិផងរបងជាមួយគ្នា ។

ជោគជ័យនៃកិច្ចប្រជុំកំពូល មេគង្គ-ឡានឆាង កាន់តែជួយលើកកម្ពស់កិត្តិយស និងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជាឲ្យកាន់តែល្បីល្បាញថែមទៀតនៅលើឆាកអន្តរជាតិ ៕

# ទស្សនកិច្ចរបស់ឯកឧត្តម លី ខឺឈាង កាន់តែជំរុញខ្លាំងក្លាថែមទៀត កិច្ចសហប្រតិបត្តិការភាពជាដៃគូជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ រវាងប្រទេសទាំងពីរ កម្ពុជា-ចិន





*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្វាគមន៍យ៉ាងកក់ក្ដៅដំណើរទស្សនកិច្ចរបស់ ឯកឧត្តម លី ខឺឈាង នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋនៃប្រជាមានិតចិន នៅព្រះរាជាណាចក្រកម្ពុជា*

តបតាមការអញ្ជើញរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម **លី ខឺឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋនៃប្រជាមានិតចិន បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី១០-១១ ខែមករា ឆ្នាំ២០១៨ ។ ក្នុងដំណើរទស្សនកិច្ចនេះ ឯកឧត្តម **លី ខឺឈាង** បានចូលក្រាបបង្គំគាល់**ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃកម្ពុជា** និងបានជួបពិភាក្សាជាមួយ**សម្តេចតេជោ ហ៊ុន សែន** ផងដែរ ។

ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈគ្នាយ៉ាងស៊ីជម្រៅលើទំនាក់ទំនងទ្វេភាគី និងបញ្ហាតំបន់ និងអន្តរជាតិ ដែលជាកង្វល់រួមហើយបានឯកភាពមតិគ្នាយ៉ាងទូលំទូលាយ ។ ភាគីទាំងពីរបានឯកភាពមតិគ្នាថា ការលើកកម្ពស់កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ និងការអភិវឌ្ឍទំនាក់ទំនង កម្ពុជា-ចិន ឲ្យកាន់តែធំធេង និងស៊ីជម្រៅ គឺស្របទៅតាមបំណងប្រាថ្នារួម និងផលប្រយោជន៍ស្នូលរបស់ប្រជាជនទាំងពីរ ហើយបង្កបរិយាកាសអំណោយផលដល់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍនៅក្នុងតំបន់ ។ ភាគីទាំងពីរនឹងបន្តរក្សាប្រពៃណីកន្លងមកនិងឆ្លៀតយកឱកាសខួបអនុស្សាវរីយ៍លើកទី៦០ នៃការបង្កើតទំនាក់ទំនងការទូត ដើម្បីពង្រឹងសហគមន៍វាសនារួមកម្ពុជា-ចិន ដែលមានសារៈសំខាន់ជាយុទ្ធសាស្ត្រ ។ ឯកឧត្តម **លី ខឺឈាង** បានថ្លែងអំណរអរគុណជាខ្លាំងចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានទទួលស្វាគមន៍ចំពោះរូបឯកឧត្តម និងប្រតិភូយ៉ាងកក់ក្ដៅជាទីបំផុតហើយក៏បានសំដែងនូវសេចក្តីអបអរសាទរចំពោះការដឹកនាំ ក្នុងនាមជាសហប្រធាននៃកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង លើកទី២ ទទួលបានជោគជ័យយ៉ាងធំធេង ។ ឯកឧត្តមនាយករដ្ឋមន្ត្រីបានបន្តថានេះជាខួបទី៦០ឆ្នាំ នៃទំនាក់ទំនងការទូតរវាងកម្ពុជា និងចិន ហើយដំណើរទស្សនកិច្ចរបស់ឯកឧត្តមមកកាន់កម្ពុជាពេលនេះ គឺដើម្បីជំរុញទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ឲ្យបានកាន់តែរឹងមាំនិងខ្លាំងខ្លាឡើងថែមទៀត ។ ប្រទេសចិននឹងបន្តជួយកម្ពុជាថែមទៀត ដើម្បីជំរុញសេដ្ឋកិច្ចកម្ពុជាឲ្យកាន់តែមានការរីកចម្រើន ។ សម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍ថា ឆ្នាំនេះជាឆ្នាំដ៏ពិសេសមួយជាឆ្នាំខួបទី៦០ នៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ។ ជាការចាប់ផ្តើមជាមួយដំណើរទស្សនកិច្ចរបស់ឯកឧត្តមនាយករដ្ឋមន្ត្រី **លី ខឺឈាង** ផង ហើយក៏ជាការចូលរួមធ្វើជាសហប្រធានកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងផងដែរ ទាំងនេះបានឆ្លុះបញ្ចាំងឲ្យឃើញនូវភាពជាដៃគូជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជា-ចិន ។ សម្តេចតេជោបានបន្តថា ប្រទេសចិនកំពុងតែនាំមុខការវិនិយោគនៅកម្ពុជារាប់ទាំងគម្រោងវិនិយោគ ដែលបានចុះហត្ថលេខានៅពេលនេះផងដែរ ។ ចំណែកវិស័យទេសចរណ៍ភ្ញៀវទេសចរចិនក៏កំពុងនាំមុខគេ។ ក្នុងករណីនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏បានស្នើសុំឲ្យឯកឧត្តមនាយករដ្ឋមន្ត្រីចិនជួយជំរុញទេសចរចិនឱ្យមកកម្ពុជាកាន់តែច្រើនឡើងផង និងជួយពិចារណានាំស្ករអំពៅចេញពីកម្ពុជាផង ។ ជាការ




***សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ដ្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្ដមនាយករដ្ឋមន្ដ្រីចិន **លី ខឺឈាង** បានអញ្ជើញជាអធិបតី នៅក្នុងពិធីចុះហត្ថលេខា លើឯកសារសំខាន់ៗ ចំនួន១៩*

ឆ្លើយតប ឯកឧត្ដមនាយករដ្ឋមន្ដ្រីចិនបានស្នើឱ្យរដ្ឋមន្ដ្រីក្រសួងពាណិជ្ជកម្មចិន និងកម្ពុជាបន្ដធ្វើការពិភាក្សាគ្នាលើការនាំស្ករអំពៅចេញ ។ ចំពោះវិស័យទេសចរណ៍ឯកឧត្ដមមានប្រសាសន៍ថា ប្រជាជនចិនមានលទ្ធភាពចេញធ្វើទេសចរណ៍ទៅក្រៅប្រទេសបានប្រមាណ ២០០លាននាក់ ក្នុងមួយឆ្នាំ ។ ដូច្នេះត្រឹម ១% នៃទេសចរចិនចេញមកកម្ពុជាក៏បានចំនួនពីរលាននាក់ដែរ ។ ភាគីចិនសន្យាបន្ដជួយកម្ពុជាក្នុងការអភិវឌ្ឍវិស័យនានាដូចជា ការដឹកជញ្ជូន ការសន្សំទឹក ការបោសសម្អាតមីន សេវាអប់រំ និងវេជ្ជសាស្ដ្រ ជំរុញយ៉ាងសកម្មលើការសាងសង់ ពហុកីឡាដ្ឋានមរតកតេជោ និងអគារមន្ទីរពេទ្យមិត្ដភាពកម្ពុជា-ចិន នៅភ្នំពេញ និងមន្ទីរពេទ្យខេត្តត្បូងឃ្មុំ និងគម្រោងផ្សេងៗទៀតដែលពាក់ព័ន្ធជីវភាពរស់នៅរបស់ប្រជាជន ។ភាគីទាំងពីរនឹងជំរុញការអនុវត្តអនុស្សារណៈយោគយល់គ្នាស្ដីពីការពង្រឹងកិច្ចសហប្រតិបត្ដិការ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្រុមហ៊ុន ដែលមានសមត្ថភាពខ្ពស់ និងជឿទុកចិត្តបានក្នុងការពង្រឹងកិច្ចសហប្រតិបត្ដិការលើវិស័យសំខាន់ៗដូចជា ហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ធនធានទឹក និងថាម ពលទូរគមនាគមន៍ ឧស្សាហកម្ម និងទេសចរណ៍ ជំរុញការសាងសង់ និងប្រតិបត្ដិការនៃតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងចូលរួមយ៉ាងសកម្មក្នុងការសាងសង់គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ និងអាកាសយានដ្ឋានថ្មីក្នុងខេត្តសៀមរាប ។

បន្ទាប់ពីកិច្ចប្រជុំចង្អៀត និងកិច្ចប្រជុំទ្វេភាគីរួចហើយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ដ្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្ដមនាយករដ្ឋមន្ដ្រីចិន **លី ខឺឈាង** បានអញ្ជើញជាអធិបតី នៅក្នុងពិធីចុះហត្ថលេខាលើឯកសារសំខាន់ៗ ចំនួន១៩ គឺ:១-អនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីការលើកកម្ពស់បន្ថែមការអភិវឌ្ឍមជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យាកម្ពុជា-ចិន ២-អនុស្សរណៈនៃការយោគយល់គ្នាសម្រាប់កិច្ចការប្រតិបត្ដិការលើការលើកកម្ពស់គុណភាពផលិតផល ៣-កិច្ចព្រមព្រៀងស្ដីពីកិច្ចសហប្រតិបត្ដិការសេដ្ឋកិច្ច និងបច្ចេកទេស ៤-លិខិតប្ដូរសារស្ដីពីគម្រោងជួសជុលរាជវាំងនៅអង្គរ ៥-លិខិតប្ដូរសារស្ដីពីការផ្ដល់ជូនបរិក្ខារមួយកញ្ចប់ ៦-អនុស្សារណៈនៃការយោគយល់គ្នាស្ដីពីគម្រោងដំណើរនៃក្ដីស្រឡាញ់ពីបេះដូងនៅកម្ពុជា ៧-អនុស្សារណៈនៃការយោគយល់គ្នាស្ដីពីការរៀបចំផែនការរួម លើការអភិវឌ្ឍកសិកម្មទំនើបនៅកម្ពុជា ៨-អនុស្សារណៈនៃការយោគយល់គ្នាស្ដីពីកិច្ចសហប្រតិបត្ដិការអង្គការស្រាវជ្រាវដំណាំស្រូវ ៩-កិច្ចព្រមព្រៀងស្ដីពីការអនុវត្តគម្រោងការបង្កើតមជ្ឈមណ្ឌលបង្កាត់និងអភិរក្សពូជឈើមានតម្លៃខ្ពស់នៅកម្ពុជា ១០-កិច្ចព្រមព្រៀងឥណទានសម្បទានសម្រាប់គម្រោងសាងសង់ខ្សែអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលដំណាក់កាលទី២, ១១-កិច្ចព្រមព្រៀងឥណទានសម្បទានសម្រាប់គម្រោងពង្រីក និងលើកកម្រិតផ្លូវជាតិលេខ៣ (ចោមចៅបែកគូសក្រុងកំពត), ១២-អនុស្សារណៈនៃការយោគយល់គ្នាស្ដីពីកិច្ចសហប្រត្តិការទៅវិញទៅមក, ១៣-កិច្ចព្រមព្រៀងសម្បទានសម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿន ភ្នំពេញ-ខេត្តព្រះសីហនុ, ១៤-កិច្ចព្រមព្រៀងស្ដីពីវិស័យអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ, ១៥-អនុស្សរណៈនៃការយោគយល់គ្នាស្ដីពីពាណិជ្ជកម្មអង្ករ, ១៦-កិច្ចសន្យាសម្រាប់គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនី 500kv ជាឆ្អឹងខ្នងសម្រាប់បណ្ដាញជាតិ និងភ្ជាប់អនុតំបន់, ១៧-កិច្ចព្រមព្រៀងក្របខណ្ឌស្ដីពីកិច្ចសហប្រតិបត្ដិការហិរញ្ញប្បទាន សម្រាប់គម្រោងអាកាសយានដ្ឋានភ្នំពេញ(ថ្មី) ប្រទេសកម្ពុជា, ១៨-កិច្ចព្រមព្រៀងក្របខណ្ឌស្ដីពីគម្រោងបាញ់បង្ហោះផ្កាយរណបតេជោ១ និង១៩-កិច្ចព្រមព្រៀងស្ដីពីគម្រោងវិនិយោគលើការសាងសង់ និងប្រតិបត្ដិការកំពង់ផែស្ទឹងហាវ ។ បន្ទាប់ពីពិធីចុះហត្ថលេខា និងប្ដូរសាររួមគ្នារួចមក គឺមានការប្រកាសជាផ្លូវការនូវគម្រោងអភិវឌ្ឍន៍មួយចំនួនដែលកម្ពុជាបានសំរេចជាមួយភាគីចិន ដែលក្នុងនោះគឺមានគម្រោង ១-«ដំណើរនៃក្ដីស្រឡាញ់ពីបេះដូង» នៅកម្ពុជាដែលភាគីចិននឹងផ្ដល់ការវះកាត់ជួយកុមារកម្ពុជា ដែលមានបញ្ហាជំងឺបេះដូងចំនួន ១០០នាក់ មានរយៈពេល ៣ឆ្នាំ ២-គម្រោងសាងសង់អគារមន្ទីរពេទ្យមិត្ដភាពកម្ពុជា-ចិន (ក្នុងបរិវេណមន្ទីរពេទ្យព្រះកុសុមៈ) និងមន្ទីរពេទ្យព្យាបាលជំងឺទូទៅនៅខេត្តត្បូងឃ្មុំ ៣-គម្រោងប្លង់ស្ថាបត្យកម្មអាកាសយានដ្ឋានអន្ដរជាតិសៀមរាបអង្គរ ។

ទស្សនកិច្ចរបស់ឯកឧត្ដម **លី ខឺឈាង** នៅព្រះរាជាណាចក្រកម្ពុជាទទួលបានជោគជ័យយ៉ាងពេញលេញ និងបានជំរុញឲ្យកាន់តែខ្លាំងក្លាថែមទៀត នូវកិច្ចសហប្រតិបត្ដិការភាពជាដៃគូជាយុទ្ធសាស្ដ្រគ្រប់ជ្រុងជ្រោយរវាងប្រទេសទាំងពីរ កម្ពុជា-ចិន ៕

# សម្ដេចតេជោ ហ៊ុន សែន នឹងបន្តធ្វើជានាយករដ្ឋមន្ត្រី រយៈពេល ២អាណត្តិទៀត

## ❋ គ្រូពេទ្យទាំងអស់ត្រូវធ្វើការងារប្រកបដោយវិជ្ជាជីវៈ និងមានក្រមសីលធម៌ខ្ពស់

## ❋ អ្នកសារព័ត៌មានមិនត្រូវធ្វើជាចៅក្រមកាត់សេចក្ដីទេ



***សម្ដេចតេជោ ហ៊ុន សែន*** *អញ្ជើញជួបជាមួយកម្មករ កម្មការិនី មកពី រោងចក្រចំនួន១៣ ស្ថិតនៅរោងចក្រតំបន់ទួលសង្កែ ក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ*



***សម្ដេចតេជោ ហ៊ុន សែន*** *អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីសម្ពោធអគារព្យាបាលជំងឺថ្មីមួយទៀត ស្ថិតនៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត*

ក្នុងខែមករា ឆ្នាំ២០១៨ នេះ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញបន្តចុះជួបជាមួយកម្មករ កម្មការិនី អ្នកធាក់ស៊ីក្លូ អ្នករត់ម៉ូតូឌុប និងសម្ពោធនូវសមិទ្ធិធំៗមួយចំនួន ។ ទន្ទឹមនេះសម្ដេចតេជោក៏មានជាសារនយោបាយដ៏មានអត្ថន័យមួយចំនួនផងដែរ ។

❋ ព្រឹកថ្ងៃទី ៣ ខែ មករា **សម្ដេចតេជោ ហ៊ុន សែន** បានអញ្ជើញជួបជាមួយកម្មករ កម្មការិនី ចំនួន ១៣.៥៤៦ នាក់ មកពីរោងចក្រចំនួន១៣ ស្ថិតនៅរោងចក្រតំបន់ទួលសង្កែ ក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ក្នុងពិធីនេះ សម្ដេចតេជោបានស្នើឲ្យស្ថាប័នពាក់ព័ន្ធបន្តយកចិត្តទុកដាក់អនុវត្តនូវអនុសាសន៍៨ចំណុចរបស់សម្ដេច ដែលក្នុងនោះរួមមានទី១.ត្រូវអនុវត្តន៍ប្រាក់ខែអប្បបរិមា ១៧០ដុល្លារចាប់ពីថ្ងៃ១ខែមករាឆ្នាំ២០១៨តទៅ ទី២.ត្រូវអនុវត្តន៍ការចុះពិនិត្យនៅតាមមន្ទីពេទ្យរដ្ឋ ចំពោះការពិនិត្យសុខភាព និងការព្យាបាល កម្មករ កម្មការិនីរោងចក្ររួមទាំង កីឡាករ កីឡាការិនី ក្រុមប្រឹក្សាភូមិ ឃុំ ដោយមិនគិតថ្លៃ បូករួមទាំងកម្មករធាក់ស៊ីក្លូផងដែរ ក៏ត្រូវបានអនុវត្តដូចគ្នា ជាពិសេសរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួងការងារត្រូវធ្វើឲ្យបានម៉តចត់ ទី៣.ត្រូវអនុវត្តន៍ចំពោះស្ត្រីមានផ្ទៃពោះសម្រាលកូន នឹងទទួលបានពេលវេលាឈប់សម្រាកពីការងាររយៈពេល៣ខែហើយទទួលបានប្រាក់ខែ១២០% (៥០% ដោយក្រុមហ៊ុន និង ៧០%ដោយបេឡាជាតិ) ទី៤.ត្រូវអនុវត្តន៍ចំពោះកម្មការិនីសម្រាលបានកូនម្នាក់ ទទួលថវិកា ៤០ម៉ឺនរៀល និងពិនិត្យផ្ទៃពោះដោយឥតគិតថ្លៃ។ បើសម្រាលបានកូនភ្លោះពីរ គឺទទួលបានថវិកា ៨០ម៉ឺនរៀល បើសម្រាលបានកូនបី គឺទទួលបានថវិកា ១លាន ២សែនរៀល ហើយបូកប្រាក់ឧបត្ថម្ភចំនួន៥លានរៀលទៀតពី សម្ដេចតេជោ និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ទី៥.ត្រូវអនុវត្តន៍ការបង់ប្រាក់ធានាសុខភាព ដោយចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០១៨ តទៅកម្មករកម្មការិនីមិនចាំបាច់បង់ទៀតទេ គឺម្ចាស់ក្រុមហ៊ុនជាអ្នកបង់ជំនួស ១០០% ទី៦.អនុវត្តន៍តាមដានមើលបញ្ហា ទឹក ភ្លើង គឺត្រូវខិតខំបន្ត តទឹកតភ្លើងដល់ផ្ទះរបស់កម្មករនៅឆ្ងាយ ដែលមិនទាន់ទៅដល់ឲ្យបានគ្រប់គ្រាន់ឯតម្លៃផ្ទះជួលដល់កម្មករកម្មការិនីកុំឲ្យមានការឡើងថ្លៃក្នុងឆ្នាំ២០១៨ ទី៧.អនុវត្តន៍ប្រាក់សោធននិវត្តន៍ចាប់ពីឆ្នាំ ២០១៩ ទៅកម្មករ កម្មការិនី និងទទួលបានប្រាក់ ចូលនិវត្តន៍ (ប្រាក់រំព្រែត)។ ដូច្នេះក្នុងរយៈពេល ១ឆ្នាំ (២០១៨) ត្រូវត្រៀមរៀបចំឲ្យហើយដើម្បីឲ្យដំណើរការបានល្អនៅក្នុងឆ្នាំ២០១៩ នូវរបបសោធននិវត្តន៍នេះ និងទី៨.ចូលរួមបន្តការយកចិត្តទុកដាក់ និងដោះស្រាយបញ្ហាផ្សេងៗដល់ពលករនៅក្រៅប្រទេស ។ ជួយសម្រួលនូវបែបបទលិខិតបទដ្ឋានផ្លូវច្បាប់នានា និងដើម្បីទទួលបាននូវលក្ខខណ្ឌការងារល្អប្រសើរ ។

❋ ថ្ងៃទី៤ ខែមករា សម្ដេចតេជោបានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីសម្ពោធអគារព្យាបាលជំងឺថ្មីមួយទៀតស្ថិតនៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលមានកម្ពស់ ៦ជាន់ស្មើនឹង៧៨បន្ទប់មានតម្លៃប្រមាណ ៣លានដុល្លារអាមេរិក។ អគារព្យាបាល



*សម្ដេចតេជោ ហ៊ុន សែន ជួបសំណេះសំណាល ជាមួយបងប្អូនអ្នកធាក់ស៊ីក្លូ*

ជំងឺថ្មីនេះមានឈ្មោះថា «**អគារសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**» ។ ក្នុងឱកាសនេះ សម្ដេចតេជោមានប្រសាសន៍ថា នេះជាសមិទ្ធផលថ្មីមួយទៀតនៅក្នុងវិស័យសុខាភិបាល ដែលបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពរបស់កម្ពុជា ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ។ មានកិច្ចការច្រើនណាស់ដែលជាវឌ្ឍនភាពតែក៏មានកិច្ចការច្រើនដែរដែលជាបញ្ហាប្រឈម។ ឥឡូវនេះ ហេដ្ឋារចនាសម្ព័ន្ធចាំបាច់សម្រាប់បម្រើឲ្យការដោះស្រាយនូវសុខមាលភាព របស់ប្រជាជនត្រូវបានបង្កើតឡើងជាតំណាក់ៗ ដែលមានការអភិវឌ្ឍជាបង្គួរ ។ ទោះបីថាមានការខ្វះខាតដោយអន្លើ ក៏ប៉ុន្តែសម្ដេចនៅតែសុំអរគុណចំពោះមន្ត្រីសុខាភិបាល គ្រប់ជាន់ថ្នាក់ បុគ្គលិកសុខាភិបាលគ្រប់ផ្នែក គ្រប់ថ្នាក់ទាំងអស់និងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងព្យាបាលជំងឺដល់ប្រជាពលរដ្ឋរបស់យើង ។

សម្ដេចប្រមុខរាជរដ្ឋាភិបាលបានបន្តលើកទឹកចិត្តផង និងអំពាវនាវផងដល់បណ្ដាគ្រូពេទ្យទាំងអស់ឲ្យធ្វើខ្លួនជាគ្រូពេទ្យប្រកបដោយវិជ្ជាជីវៈ និងមានក្រមសីលធម៌ខ្ពស់ចំពោះអ្នកជំងឺ។

✵ ព្រឹកថ្ងៃ ទី១៣ ខែមករា សម្ដេចតេជោនាយករដ្ឋមន្ត្រីកម្ពុជាបានអញ្ជើញជួបសំណេះសំណាល ព្រមទាំងពិសាអាហារជាមួយបងប្អូនអ្នកធាក់ស៊ីក្លូ ក្នុងរាជធានីភ្នំពេញចំនួន ៣០៨ នាក់ នៅមជ្ឈមណ្ឌលកោះពេជ្រ។ ក្នុងព្រឹត្តិការណ៍នេះសម្ដេចតេជោបានប្រកាសបង្កើតសមាគមមូលនិធិត្រីចក្រយាន។

នៅក្នុងឱកាសប្រកាសបើកជាផ្លូវការនូវ "សមាគមមូលនិធិត្រីចក្រយាន (ស៊ីក្លូ)" នេះ **សម្ដេចតេជោ ហ៊ុន សែន** បានមានប្រសាសន៍ថា ថ្ងៃនេះ គឺជាថ្ងៃចាប់ផ្ដើមដំបូង មិនមែនគ្រាន់តែជាថ្ងៃនៃការប្រកាស ដើម្បីដាក់ឲ្យដំណើរការ ឬក៏ការបង្កើតនូវមូលនិធិនោះទេ ក៏ប៉ុន្តែជាថ្ងៃចាប់ផ្ដើមនៃសកម្មភាពមូលនិធិតែម្ដង ។ គោលបំណងសំខាន់នៃការបង្កើតសមាគមមូលនិធិនេះឡើង គឺដើម្បីជួយដល់អ្នកប្រកបរបរធាក់ស៊ីក្លូពិតប្រាកដ ។

សម្ដេចតេជោ ក៏បានពន្យល់អំពីអត្ថប្រយោជន៍នៃការចូលជាសមាជិកសមាគមមូលនិធិត្រីចក្រយាន។ អ្នកធាក់ស៊ីក្លូ ត្រូវបានទទួលនូវអត្ថប្រយោជន៍មួយចំនួន ទី១. ចូលទៅក្រោមមូលនិធិសមធម៌ដើម្បីទទួលបាននូវការពិនិត្យព្យាបាលជំងឺដោយឥតគិតថ្លៃនៅតាមមន្ទីពេទ្យរដ្ឋទាំងអស់។ ប័ណ្ណសមាជិកនេះ ត្រូវយកទៅចុះបញ្ជីជាមួយបេឡាជាតិសន្តិសុខសង្គមរបស់ក្រសួងការងារ ដើម្បីផ្ដល់ទៅឱ្យការពិនិត្យព្យាបាល ដោយមិនគិតថ្លៃនៅតាមមន្ទីរពេទ្យរដ្ឋ ក្រោមមូលនិធិសមធម៌ ទី២.ទទួលបានប័ណ្ណមូលនិធិនេះ គឺទទួលប្រាក់ប្រចាំថ្ងៃ ៧ពាន់រៀល ក្នុងមួយថ្ងៃ មានន័យថា មូលនិធិនឹងផ្ដល់ជូននូវតម្លៃ ដែលខ្លួនធ្លាប់ជួលស៊ីក្លូដែលយើងស៊ើបដឹងតម្លៃជួលស៊ីក្លូនោះ គឺចន្លោះពី ១.៧០០ ទៅ ២.០០០រៀល ។ ដូច្នេះយើងនឹងផ្ដល់ ២.០០០ រៀល តែម្ដង បើទោះបីជាអ្នកនោះមានស៊ីក្លូខ្លួនឯងក៏ដោយ ក៏យើងចាត់ទុកថា ២.០០០ រៀលនេះ គឺជាប្រាក់ ដើម្បីគាត់ថែទាំស៊ីក្លូ។ ក្រៅពីនោះយើងផ្ដល់ ៥ពាន់រៀលសម្រាប់ម្នាក់ គឺជាតម្លៃសម្រាប់ទទួលទាន ឬហៅថា ប្រាក់បាយប្រចាំថ្ងៃ ។ សម្ដេចតេជោបានបន្តថា ក្រៅពីផលប្រយោជន៍ខាងលើ សមាគមនឹងពិចារណាក្នុងការផ្ដល់ការឧបត្ថម្ភបន្ថែម ជូនបងប្អូនអ្នកធាក់ស៊ីក្លូ ដូចជាក្នុងរដូវបុណ្យទាន (ចូលឆ្នាំ និងភ្ជុំបិណ្ឌ មរណភាពជាដើម) ។

សម្ដេចតេជោ ក៏បានស្នើសុំឱ្យបងប្អូនអ្នកធាក់ស៊ីក្លូ គោរពច្បាប់ចរាចរណ៍ កុំប្រើប្រាស់គ្រឿងស្រវឹង ដើម្បីចៀសវាងគ្រោះថ្នាក់ផ្សេងៗ និងសូមឲ្យក្រុមហ៊ុនទេសចរណ៍ ជួយទាក់ទាញទេសចរបរទេស ឱ្យចូលរួមប្រើប្រាស់ស៊ីក្លូ។ ចូលរួមជិះស៊ីក្លូ ដើម្បីជួយលើកស្ទួយជីវភាពបងប្អូនស៊ីក្លូ។ ស៊ីក្លូគឺកាត់បន្ថយការបំពុលបរិស្ថានក្នុងទីក្រុង ។

✵ ព្រឹកថ្ងៃទី១៥ ខែមករា **សម្ដេចតេជោ ហ៊ុន សែន** បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ពោធដាក់ឲ្យប្រើប្រាស់អគារព្យាបាលជំងឺមហារីក និងសម្ភពនៅក្នុងមន្ទីរពេទ្យកាល់ម៉ែត្រ ។ អគារនេះត្រូវបានប្រសិទ្ធនាម «**អគារតេជោសន្តិភាព**»។

សម្ដេចតេជោមានប្រសាសន៍ថា ឆ្នាំ ២០១៨ ត្រូវតែជាឆ្នាំដែលមានការអភិវឌ្ឍល្អ ព្រោះជាឆ្នាំដំណាក់កាលចុងក្រោយនៃនីតិកាលទី៥ ដើម្បីឈានឆ្ពោះទៅនីតិកាលទី៦ ។ សម្ដេចតេជោក៏បានថ្លែងថា ការឈរឈ្មោះជានាយករដ្ឋមន្ត្រីរបស់សម្ដេចដែលអាចបញ្ចប់នៅក្នុងឆ្នាំ ២០២៨ គឺបានន័យថា សម្ដេចនឹងបន្តធ្វើជានាយករដ្ឋមន្ត្រីរយៈពេល ២អាណត្តិ ទៀត។ សម្ដេចតេជោបញ្ជាក់ថា អាណត្តិនាយករដ្ឋមន្ត្រីគ្មានការកំណត់ទេ ព្រោះនាយករដ្ឋមន្ត្រីគឺប្រជាពលរដ្ឋជាអ្នកបោះឆ្នោតឲ្យរដ្ឋសភា។ វាខុសពីប្រធានាធិបតីដែលបោះឆ្នោតដោយផ្ទាល់។ សម្ដេចតេជោបានកាន់តំណែងជានាយករដ្ឋមន្ត្រី ៣៣ ឆ្នាំហើយ ។ ដូចនេះ បើថែម១០ឆ្នាំទៀត ក៏មិនទាន់ចាស់ទៅណាដែរ។ **សម្ដេចតេជោហ៊ុនសែន**បានពន្យល់ថា៖ «ខ្ញុំបន្តកាន់តំណែងរយៈពេល ១០ ឆ្នាំទៀត គឺក្នុងគោលបំណងអមដំណើរជាមួយប្រជាជនកម្ពុជា ដើម្បីចូលទៅឲ្យកៀកជាមួយនឹងប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ បើគិតពីអាណត្តិ នៃសភា ២អាណត្តិ គឺឆ្នាំ២០២៨ ទើបខ្ញុំដកខ្លួនចេញ ។ ដូចនេះវាកៀកទៅពេលវេលាមួយដែលប្រទេសកម្ពុជានឹង

ក្លាយជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ ហើយមហិច្ឆតារបស់យើង គឺក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ សម្តេចតេជោជឿជាក់ថា កម្ពុជាធ្វើបានតែសំខាន់បំផុតត្រូវរក្សាឲ្យបាននូវសន្តិភាព និងស្ថិរភាពនយោបាយ ។

សម្តេចតេជោបានលើកឡើងថា សម្តេចបានដឹកនាំប្រទេសកម្ពុជា អស់រយៈពេល ៣៣ ឆ្នាំកន្លងមកនេះ មិនមែនធ្វើឡើងតាមរយៈការប្រើអាវុធឬអំណាចផ្តាច់ការដូចរបបមុនៗនោះឡើយ។ **សម្តេចតេជោ ហ៊ុន សែន** សង្កត់ធ្ងន់ថា «រយៈពេល ៣៣ឆ្នាំ មិនមែនរស់ដោយសារចុងកាណុង ហើយក៏មិនមែនរស់ដោយអំពើផ្តាច់ការដែរ។ ផ្តាច់ការពិតប្រាកដគឺ ប៉ុល ពត ប៉ុន្តែ ប៉ុល ពត ក៏រស់បានត្រឹមតែរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ។ លន់ នល់ ក៏ផ្តាច់ការដោយមានការគាំទ្ររបស់កងទ័ពអាមេរិកទៀតផង ប៉ុន្តែគេរស់ត្រឹម ៥ឆ្នាំ។ សម្រាប់ខ្ញុំឆ្លងកាត់នូវពេលវេលាដ៏ លំបាក ដែលចាប់ផ្តើមពីការយកជីវិតធ្វើដើមទុន» ។

❋ ព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨នេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវឯកសារ "ក្របខណ្ឌគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ឆ្នាំ ២០១៧-២០៣០" នៅវិមានសន្តិភាព។

សម្តេចប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ថា នេះជាកិច្ចការថ្មីមួយដែលកម្ពុជា ចាំបាច់ត្រូវគិតគូរយកចិត្តទុកដាក់ខ្ពស់ បើទោះបីជាកន្លងមកបញ្ហាមនុស្សចាស់ មិនដែលបង្កផលលំបាកជាបន្ទុកធ្ងន់ធ្ងរដល់រាជរដ្ឋាភិបាល ហើយក្នុងសង្គមខ្មែរមនុស្សចាស់ ត្រូវបានថែទាំក្នុងគ្រួសារ។ មនុស្សចាស់មានវត្តអារាមជាទីពឹង ដែលប្រការទាំងនេះបានកើតមានរាប់សិបជំនាន់មកហើយក្តី ។ នេះជាការគិតគូបន្ថែមលើតថភាពនៃសង្គមខ្មែរយើង ខណៈដែលប្រជាជនខ្មែរ តែងឱ្យតម្លៃខ្ពស់ ចំពោះកតញ្ញូតា ពិសេសរវាងកូនចៅ និងឪពុកម្តាយ, ជីដូនជីតា, សិស្ស និងគ្រូជាដើម ។ ក្នុងសង្គមខ្មែរយើង កូនចៅមានកាតព្វកិច្ចជាប្រពៃណីត្រូវធ្វើកិច្ចតបស្នងសងគុណចំពោះអ្នកមានគុណ ពិសេសឪពុកម្តាយ ដែលតែងមានព្រហ្មវិហារធម៌ ចំពោះកូនចៅពេលកូនចៅ នៅក្នុងបន្ទុករបស់ខ្លួន ។ ក្នុងនោះដែរ សង្គមខ្មែរដែលកាន់ព្រះពុទ្ធសាសនា តែងបង្កឱកាសឱ្យប្រជាជន ពិសេសអ្នកមានវ័យចំណាស់អាចជ្រកកោន, ស្នាក់អាស្រ័យ, សមាទានសីលជាដើម ក្នុងវត្តអារាមដោយវត្តអារាមតែងបានផ្តល់ជាជម្រកដ៏ស្ងប់និងភាពសុខសាន្តសម្រាប់មនុស្សចាស់។

សម្តេចតេជោបន្តថា ក្នុងស្មារតីនៃកំណើនសេដ្ឋកិច្ចខ្ពស់, ការអភិវឌ្ឍនៃសង្គមជាតិ, កត្តាសុខសន្តិភាពបានធ្វើឱ្យរាជរដ្ឋាភិបាលកាន់តែមានឱកាស និងលទ្ធភាពខ្ពស់ចាប់ផ្តើមគិតគូបន្ថែមលើការងារលើកកម្ពស់សុខុមាលភាពសង្គម ពិសេសការងារថែទាំមនុស្សចាស់ ដើម្បីធ្វើឱ្យសង្គមខ្មែរកាន់តែមានយន្តការពេញលេញ, ប្រទាក់ក្រឡានិងមានប្រព័ន្ធគាំពារសង្គមកាន់តែរឹងមាំ ដើម្បីរួមចំណែកធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងបរិយាប័ន្ន ព្រមទាំងស័ក្តិសមជាសង្គមមួយ ដែលឱ្យតម្លៃលើកតញ្ញូតាផងដែរ ។



***សម្តេចតេជោ ហ៊ុន សែន** អញ្ជើញជួបជាមួយអ្នកសារព័ត៌មានក្នុងស្រុក និងមន្ត្រីក្រសួងព័ត៌មានក្នុងជំនួបប្រចាំឆ្នាំជាលើកទី២*

❋ រាត្រីថ្ងៃទី២១ ខែមករា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់នៅក្នុងជំនួបជាមួយអ្នកសារព័ត៌មានក្នុងស្រុកនិងមន្ត្រីក្រសួងព័ត៌មានជាង ៣.៤០០ នាក់ ដែលនេះជាជំនួបប្រចាំឆ្នាំលើកទី ២ ។ សម្តេចតេជោបានលើកឡើងថាអ្នកសារព័ត៌មានមិនត្រូវប្រកាន់ស្តាំពេកឬឆ្វេងពេកនោះទេ ហើយត្រូវជ្រើសរើសយកភាពជាកណ្តាល ដែលគេអាចទទួលយកបានគ្រប់ៗគ្នា ។អ្នកកាសែតក៏មិនត្រូវធ្វើជាចៅក្រមកាត់សេចក្តីដែរ ។ សម្តេចតេជោបន្តថា មានសារព័ត៌មានបីប្រភេទដែលមិនត្រូវឲ្យមានបន្តទៅទៀតនៅកម្ពុជានោះទេ ក្នុងនោះ ទី១.សារព័ត៌មាន ដែលជាប្រភេទម៉ាហ្វីយ៉ាគឺ ដើរគំរាមទារលុយ ។ សារព័ត៌មានបែបនេះ ត្រូវបញ្ឈប់ជាបន្ទាន់ហើយត្រូវលប់បំបាត់ឲ្យបាន។ ប្រភេទទី២. សារព័ត៌មានអត់ច្បាប់ មិនគោរពច្បាប់ មិនចុះបញ្ជី និងរត់គេចវេសមិនបង់ពន្ធ។ នៅពេលមានបញ្ហា គេបានដើរតួជាអ្នករងគ្រោះ ខាងនយោបាយបោករដ្ឋាភិបាលរបស់គេទៅវិញ។ ក្រសួងព័ត៌មានត្រូវទទួលខុសត្រូវបញ្ហានេះ មិនត្រូវទុកឲ្យមានទៀតទេ ។ ប្រភេទទី៣. សារព័ត៌មានដែលមានតែឈ្មោះតែគ្មានសកម្មភាព។

សម្តេចតេជោ ក៏បានសំណូមពរដល់ស្ថាប័នសារព័ត៌មានទាំងអស់ត្រូវដើរតួនាទីជាស្ថាប័នព័ត៌មានពិត គឺជាកញ្ចក់ឆ្លុះបញ្ចាំងពីសង្គមជាតិពិតប្រាកដ ។ សូមកុំឲ្យកញ្ចក់នោះជាកញ្ចក់ដែលបែកឆ្លុះផ្សាយព័ត៌មានមិនពិតពីសង្គម។ស្ថាប័នព័ត៌មានរដ្ឋ និងឯកជនត្រូវផ្សព្វផ្សាយព័ត៌មានពិតជាមួយនឹងការពន្យល់ច្បាស់លាស់ទៅប្រជាពលរដ្ឋឲ្យបានយល់ជ្រួតជ្រាបអំពីទិសដៅ និងគោលបំណងរបស់រាជរដ្ឋាភិបាល។សារព័ត៌មានត្រូវចេះចូលរួមជួយរិះគន់ដើម្បីស្ថាបនារាល់កំហុសឆ្គងនិងផែនការដែលបានដាក់ចេញនៃក្រសួងស្ថាប័ននានាដើម្បីធ្វើការកែលំអរ មិនមែនរិះគន់ដើម្បីតែជាន់ពន្លិចនោះទេ៕

# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស





នាព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០១៨ ឯកឧត្តមបណ្ឌិត **ខួន ញឹល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី២ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមការងារគណបក្សថ្នាក់កណ្ដាលចុះជួយខេត្តកំពង់ធំ បានអនុញ្ញាតឱ្យលោក **ម៉ង់ រដ្ឋា** និងភរិយា ព្រមទាំងកូនតូចៗចំនួន ៥នាក់ រស់នៅភូមិសែនសិរីមង្គល ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលរងគ្រោះដោយភ្លើងឆេះផ្ទះទាំងស្រុង ចូលជួបសំណេះសំណាលសួរសុខទុក្ខ ព្រមទាំងប្រគល់ផ្ទះសាងសង់រួចមួយខ្នង ទំហំ ៥m x ៦m ម៉ូតូហុងដាទ្រីមសង់ឆ្នាំ២០១៨ ១គ្រឿង ថវិកា សម្ភារៈ ស្បៀងអាហារជាច្រើន តាមការស្នើសុំរបស់សាមីខ្លួន។



ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៨ លោកជំទាវ **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីក្នុងពិធីសំពះគ្រូ និងសម្ពោធពិព័រណ៍ពិសេស ស្ដីពីគ្រឿងអលង្ការ និងគ្រឿងលំអខ្មែរសម័យបុរាណ ៖ សមុច្ច័យវត្ថុពិចិត្រអំពីមាស និងប្រាក់នៃសារមន្ទីរជាតិកម្ពុជា ដែលមានរយៈពេល១ខែ គឺចាប់ពីថ្ងៃទី៤ ខែមករា ដល់ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៨ពិធីនេះបានរៀបចំឡើងនៅសារមន្ទីរជាតិកម្ពុជា រាជធានីភ្នំពេញ។ លោកជំទាវក៏បានមានប្រសាសន៍ថា ការដាក់តាំងបង្ហាញពីវប្បធម៌ និងអរិយធម៌ ក៏ដូចជាសិល្បៈរបស់កម្ពុជាជូនដល់ភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ ដើម្បីទាក់ទាញឲ្យភ្ញៀវទេសចរណ៍បានចូលទស្សនាកម្ពុជាឲ្យបានកាន់តែច្រើន។ លោកជំទាវក៏បានស្នើដល់អាជ្ញាធរពាក់ព័ន្ធទាំងអស់ សូមមេត្តាថែរក្សា និងការពារវត្ថុបុរាណដ៏មានតម្លៃដែលតាំងនៅទីនេះ ក៏ដូចជាវត្ថុបុរាណជាតិទាំងអស់ឱ្យបានគង់វង្ស ព្រោះវត្ថុទាំងនេះសុទ្ធតែមានប្រវត្តិដ៏យូរលង់ និងមានបារមីសក្តិសិទ្ធជួយប្រោះព្រំព្រះរាជាណាចក្រកម្ពុជាយើង ឱ្យបានសុខក្សេមក្សាន្ត ត្រជាក់ត្រជុំ និងមានការអភិវឌ្ឍរៀងទៅ។



ថ្ងៃទី ៤ ខែមករា ឆ្នាំ២០១៨ **សម្ដេចពិជ័យសេនា ទៀ បាញ់** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានដឹកនាំគណៈប្រតិភូចុះសួរសុខទុក្ខនាយទាហាន នាយទាហានរង និងពលទាហាននៅកងឯកភាពយោធភូមិ ភាគទី ១ កំពុងឈរជើងតាមតំបន់ព្រំដែនកម្ពុជា-ឡាវ ទិសអូរតាង៉ាវ និងអូរអាឡៃ ខេត្តស្ទឹងត្រែង។

ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៨ **សម្ដេចចៅហ្វាវាំង គង់ សំអុល** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីព្រះបរមរាជវាំង អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា រួមជាមួយឯកឧត្តម លោកជំទាវ សមាជិករាជរដ្ឋាភិបាល តំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង និងអាជ្ញាធរខេត្តកំពង់ឆ្នាំងបានចែកអំណោយជូនជនពិការចំនួន១០០នាក់ នៅក្នុងសាលាខេត្តកំពង់ឆ្នាំង ។



# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី១៣ខែមករាឆ្នាំ២០១៨ឯកឧត្តម **អ៊ឹម ឈុនលឹម** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ បានផ្ដល់រទេះរុញចំនួន១៨ និងថ្នាំផ្លាសាយមួយកេះធំដល់សាខាកាកបាទក្រហមកម្ពុជាខេត្តមណ្ឌលគិរី ដើម្បីអោយសាខាចែកបន្តដល់ជនពិការនៅក្នុងមូលដ្ឋាន ។



ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៨ ឯកឧត្តម **ទេព ងន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី ២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញសម្ពោធស្រះទឹកស្ដាររួច និងជណ្ដើរថ្មីចំនួន២ នៅឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្ដាល។ ស្រះទឹកដែលសម្ពោធដាក់ឲ្យប្រើប្រាស់ មានបណ្ដោយប្រវែង ១០០ម៉ែត្រ ទទឹង១០០ ម៉ែត្រនិងជម្រៅ ៧ ម៉ែត្រ ដែលជាអំណោយរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣។



ថ្ងៃទី៨ ខែ មករា ឆ្នាំ២០១៨ ឯកឧត្តមនាយឧត្តមសេនីយ៍ **មាស សុភា** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោកបានអញ្ជើញសម្ពោធដាក់ឲ្យប្រើប្រាស់ អគារទីបញ្ជាការកងពលតូចថ្មើរជើងលេខ៤១ យោធភូមិភាគទី៤ កងទ័ពជើងគោក។



ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៨ ឯកឧត្តម **ស៊ុយ សែម** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជារដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានខេត្តពោធិ៍សាត់ បានអញ្ជើញប្រគល់ និងបំពាក់ឯកសណ្ឋានថ្មី ជូនប្រជាការពារចំនួន ២ ២៤៩នាក់មកពីឃុំទាំង ១០ក្នុងស្រុកបាកាន ខេត្តពោធិសាត់។



ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៨ ឯកឧត្តម **ប្រាក់ សុខុន** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានអញ្ជើញចុះពិនិត្យផ្លូវលំមួយខ្សែប្រវែង ៤២៦ម៉ែត្រ និងចែកអំណោយដល់ប្រជាជនដែលមានជីវភាពលំបាក នៅក្នុងភូមិលេខ២ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល ។

# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៨ ឯកឧត្តម **វេង សាខុន** សមាជិកគណៈកម្មាធិការកណ្ដាល គណបក្សប្រជាជនកម្ពុជារដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានអញ្ជើញសួរសុខទុក្ខសមាជិកសហគមន៍ព្រៃឈើង្ហាវក្រាច់ នៅភូមិ ពូលូង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី ។



ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៨ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានស្ដីទីគណៈកម្មការទី ១០ព្រឹទ្ធសភា បានជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុក មេឃុំភូមិប៉ុស្ដិ៍រដ្ឋបាល កងរាជអាវុធហត្ថឃុំ ប្រជាការពារភូមិ និងប្រជាពលរដ្ឋសរុបចំនួន ៤៥០នាក់ នៅឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។ ឯកឧត្តមបញ្ជាក់ថា ថ្ងៃ០៧ ខែមករា ឆ្នាំ១៩៧៩ គឺជាថ្ងៃជ័យជម្នះជាប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជា ដែលបានវាយផ្ដួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត និងបានបញ្ចប់សម័យកាលដ៏ខ្មៅងងឹតបំផុតនៃកម្ពុជា បើកឡើងវិញនូវទំព័រសករាជថ្មីគឺ ឯករាជ្យ សេរីភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍សង្គម។ ជ័យជម្នះ៧មករា ផ្ដល់កំណើតទីពីរដល់ជនកម្ពុជា និងបានផ្ដល់សេចក្ដីសង្ឃឹមចំពោះអនាគតរបស់ប្រទេសជាតិ នេះជាសច្ចធម៌ប្រវត្តិសាស្ត្រដែលគ្មានកម្លាំងណាអាចមកបំភ្លៃបំផ្លើស និងបំផ្លាញបានឡើយ។



ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ លោកជំទាវ **បាន ស្រីមុំ** អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន និងជាប្រធានសាខាកាកបាទក្រហមកម្ពុជាខេត្តប៉ៃលិន បានដឹកនាំក្រុមការងារនាំយកអំណោយសង្គ្រោះបន្ទាន់ និងសម្ភារៈផ្ទះបាយមួយចំនួនជូនដល់គ្រួសាររងគ្រោះភ្លើងឆេះផ្ទះ នៅភូមិដីក្រហម សង្កាត់អូរតាវ៉ៅ ក្រុងប៉ៃលិន ។



ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៨ លោកជំទាវ **មិថុនា ភូថង** អភិបាលនៃគណៈអភិបាលខេត្តកោះកុង បានចុះសួរសុខទុក្ខ លោកគ្រូអ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងប្រជាពលរដ្ឋ នៅក្នុង ភូមិកោះកុងក្នុងឃុំត្រពាំងរូងស្រុកកោះកុងនិងបានផ្ដល់អំណោយទូកនិងម៉ាស៊ីនចំនួន ០១ គ្រឿង ជូនដល់សាលាបឋមសិក្សាកោះកុងក្នុង សម្រាប់ដឹកជញ្ជូនសិស្សានុសិស្សផងដែរ ។



ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ឯកឧត្តម **ជាវ តាយ** សមាជិកគណៈកម្មាធិការកណ្ដាល គណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តកំពតបានទទួលថវិកាពីសប្បុរសជនមកពីបណ្ដាសហគ្រាសឯកជន និងថ្នាក់ដឹកនាំមួយចំនួនរបស់គណបក្សប្រជាជនកម្ពុជាចំនួន ១៣២.៣០០ដុល្លារ ក្នុងនោះជាការឧបត្ថម្ភផ្ទាល់ពីឯកឧត្តមចំនួន ១០០.០០០ដុល្លារ ជូនគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តកំពត ដើម្បីរួមចំណែកក្នុងកិច្ចការងារបម្រើប្រជាពលរដ្ឋ។

# សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស



*ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ក្រុមការងារយុវជនគណបក្ស ខេត្តព្រៃវែង បានប្រារព្ធពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ ក្រោមអធិបតីភាព ឯកឧត្តម **ស សុខា** តំណាងរាស្ត្រមណ្ឌលព្រៃវែង ឯកឧត្តម **ស្បោង សារ៉ាត** ប្រធានគណៈកម្មាធិការគណបក្សខេត្ត និងឯកឧត្តម **កែ ម៉ុនខៀន** ប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល សមាសភាពចូលរួមសន្និបាតសរុបបាន ៤៦៥រូប ។*



ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ក្រុមគ្រូឧទ្ទេសនាមរបស់ក្រុមការងារ យុវជនគណបក្សថ្នាក់កណ្តាល ដឹកនាំដោយឯកឧត្តម **យស ផានីត្តា** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល បានសហការជាមួយក្រុមការងារគណបក្សថ្នាក់កណ្តាលចុះជួយស្រុកខ្សាច់កណ្តាលដែលមានឯកឧត្តមបណ្ឌិត **អួន ពន្ធ័មុនីរត្ន័** ជាប្រធាន និងក្រុមការងារយុវជនគណបក្សស្រុកខ្សាច់កណ្តាល បានរៀបចំបើកវគ្គបណ្តុះបណ្តាលដល់សកម្មជនយុវជនគណបក្សស្រុកខ្សាច់កណ្តាលចំនួន ១៤៦ នាក់ ស្រី៩៤នាក់ មកពី៩៣ភូមិ និង១៨ឃុំ ។



*ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ឯកឧត្តម **កែ ម៉ុនខៀន** ប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល បានទទួលជួបពិភាក្សាការងារ ជាមួយគណៈប្រតិភូមជ្ឈិមបក្សកុម្មុយនីស្តគុយបា ដឹកនាំដោយឯកឧត្តម Juan Carlos Marsan Aguileras នៅទីស្នាក់កណ្តាលរបស់គណបក្ស។*



នាថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ កិច្ចប្រជុំបូកសរុបការងាររបស់ក្រុមសកម្មជនយុវជនគណបក្សក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ ក្រោម អធិបតីភាពឯកឧត្តម **ហួត ហាក់** សមាជិកក្រុមការយុវជនគណបក្សថ្នាក់កណ្តាល ។



*នៅទី២៤ ខែធ្នូ ឆ្នាំ២០១៧ គណៈកម្មាធិការគណបក្សស្រុកល្វាឯម ខេត្តកណ្តាល បានរៀបចំវគ្គបណ្តុះបណ្តាលអប់រំនយោបាយ និងផ្សព្វផ្សាយសភាពការណ៍ថ្មីៗនៅកម្ពុជា ដល់ក្រុមសកម្មជនយុវជនគណបក្សស្រុកល្វាឯមក្រោមអធិបតីភាពឯ.ឧ **កៅ ថាច** អនុប្រធាន គណៈពង្រឹងស្រុកល្វាឯម ទទួលបន្ទុកការងារយុវជនស្រុក តំណាង ឯ.ឧ បណ្ឌិតសភាចារ្យ **អួនព័ន្ធមុនីរ័ត្ន** ប្រធានគណៈពង្រឹងស្រុកល្វាឯមមានសិក្ខាកាមចូលរួមសរុប១១៩ នាក់ ដែលជាក្បាលម៉ាស៊ីនយុវជន និងក្រុមសកម្មជនយុវជនគណបក្សមកពី ៨ឃុំ ដោយមានការចូលរួមធ្វើបទឧទ្ទេសនាមដោយក្រុមគ្រូឧទ្ទេស របស់ក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល។*



ល្ងាចថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ឯកឧត្តម **សុខ ឥសាន** អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា បានអនុញ្ញាតឱ្យក្រុមគ្រូឧទ្ទេស របស់ក្រុមការងារយុវជនថ្នាក់កណ្តាល ដឹកនាំដោយឯកឧត្តម **យស ផានីត្តា** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល បានចូលជួបសម្តែងការគួរសម និងផ្លាស់ប្តូរបទពិសោធន៍ ដែលបានធ្វើឡើងនៅទីស្នាក់ការកណ្តាលគណបក្សប្រជាជនកម្ពុជា (គ៨៥) ។

# សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស



*ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ឯកឧត្តម* ***ជាម ច័ន្ទសោភ័ណ*** *សមាជិកគណៈកម្មាធិការកណ្តាល និងជាប្រធានក្រុមទទួលបន្ទុកតំបន់៣ នៃក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល និងក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល បានប្រជុំផ្លាស់ប្តូរបទពិសោធន៍ ជាមួយក្រុមការងារយុវជនគណបក្សខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងបន្ទាយមានជ័យ។*

ក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្ស នៅក្រៅប្រទេស បានរៀបចំពិធីមីទិញអបអរសាទរខួបលើកទី ៣៩ នៃ ទិវាជ័យជំម្នះ ៧ មករា ដែលបានប្រារព្ធធ្វើឡើងជាមួយបងប្អូនខ្មែរយើងដែលទៅរស់នៅក្រៅប្រទេស ជាមួយនឹងក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សនៅទ្វីបអឺរ៉ុប សហរដ្ឋអាមេរិក អូស្ត្រាលី-ណូវ៉ែលហ្សេឡង់ ដោយមានភាពស្និទ្ធស្នាលជាទីបំផុត ។






*កាលពីព្រឹកថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ នៅឃុំកោះកែវ បានរៀបចំពិធីអបអរសាទរខួបទី៣៩ នៃ ទិវាជ័យជម្នះ ៧ មករា ១៩៧៩-៧ មករា ២០១៨ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត* ***ជ្រុន ថៅវ៉ាវ៉ាត*** *សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្តាល និងជាអនុប្រធានគណៈពង្រឹងស្រុកល្វាឯម និងជាប្រធានគណៈពង្រឹងឃុំកោះកែវ ដោយមានការចូលរួមពីថ្នាក់ដឹកនាំស្រុកល្វាឯម, លោកស្រីមេឃុំកោះកែវ ,ប្រធានភូមិ ,ប្រជាការពារ និងប្រជាពលរដ្ឋ សរុបចំនួន ៦៥០ នាក់ ។*

រសៀលថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ក្រុមការងារយុវជនគណបក្សខេត្តព្រៃវែង បានប្រារព្ធពិធីប្រកាសចូលជាសមាជិកយុវជនគណបក្សរបស់ស្រុកបាភ្នំចំនួន ១៧៥នាក់ ក្រោយពីទទួលបានការសិក្សា បណ្តុះបណ្តាលវគ្គអប់រំគោលការណ៍គោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជារួចមក ។





*កំពត ៖ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ នេះក្រុមការងារយុវជនស្រុកដងទង់ បានប្រជុំក្បាលម៉ាស៊ីនដឹកនាំយុវជនស្រុក ក្រោមអធិបតីភាព លោក* ***កង ផល្លា*** *អនុប្រធានក្រុមការងារយុវជនគណបក្សខេត្ត និងលោក* ***ឈុក ថាន*** *ប្រធានក្រុមការងារយុវជនគណបក្សស្រុក ។*

នាព្រឹកថ្ងៃ ទី៣០ ខែធ្នូ ឆ្នាំ២០១៧ ឯកឧត្តមបណ្ឌិត **ខិន ចាណាល់** ប្រធានក្រុមការងារយុវជន គណបក្សខេត្តព្រៃវែង បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធិបើកវគ្គបណ្តុះបណ្តាលអប់រំបញ្ជ្រាបគោលការណ៍ គោលនយោបាយរបស់គណបក្សដល់យុវជនស្រុកពាមជរ ចំនួន២០៧នាក់ ៕



# សមិទ្ធផលសំខាន់ៗមួយចំនួននៃវិស័យសេដ្ឋកិច្ច



- ក្នុងឆ្នាំ២០១៧ កន្លងទៅនេះ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិចំនួន ៥,៦លាននាក់ កើនឡើង ១១,៦% បើធៀបនឹងឆ្នាំ២០១៦ ខណៈទេសចរចិនមានរហូតដល់ទៅ ១,២លាននាក់ កើនឡើង ៤៦% ឈរនៅលំដាប់លេខ១ ។ វិស័យទេសចរណ៍បានបង្កើតការងារដោយផ្ទាល់ដល់ប្រជាពលរដ្ឋកម្ពុជាប្រមាណ៦២ម៉ឺននាក់ និងដោយប្រយោលប្រមាណជាង ១លាននាក់ ។ ចំណូលពីវិស័យទេសចរណ៍បានកើនដល់ ៣.៨០០លានដុល្លារ មានកំណើន ១៧% ។

- បច្ចុប្បន្ននៅប្រទេសកម្ពុជាមានក្រុមហ៊ុនអាកាសចរណ៍ចំនួន ១៥ក្រុមហ៊ុន (កម្ពុជាមាន៣ក្រុមហ៊ុន និងចិន មាន១២ក្រុមហ៊ុន) ដែលបានធ្វើប្រតិបត្តិការហោះហើរទៀងទាត់ (Scheduled Flight) ភ្ជាប់រវាងកម្ពុជា-ចិន មាន ចំនួន ១៥៥ជើង ក្នុង១សប្ដាហ៍ និងជើងហោះហើរពិសេស Charter Flight មានប្រមាណ ៥០ជើង ក្នុងមួយសប្ដាហ៍ ។ ក្រុមហ៊ុនអាកាសចរណ៍ដែលបានចុះបញ្ជីជាក្រុមហ៊ុនដឹកអ្នកដំណើរនៅក្នុងប្រទេសកម្ពុជាមានចំនួន៩ ដោយក្នុងនោះមានក្រុមហ៊ុនឧទ្ធម្ភាគចក្រចំនួន២ និងក្រុមហ៊ុនយន្តហោះស្លាប (Fixed Wing) ចំនួន៧ក្រុមហ៊ុន ។

- ចំណូលសុទ្ធ (Net revenue) នៃពន្ធគយសម្រេច បានជាង ៧.៦៦២ប៊ីលានរៀល ស្មើនឹងជាង ១.៩០១លានដុល្លារ អាមេរិក ត្រូវជាប្រមាណ ១០៤,៥% នៃផែនការដែលកំណត់ដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០១៧ ។ តួលេខ នេះបង្ហាញពីកំណើនប្រមាណ ១០,៤% ធៀបនឹងលទ្ធផលចំណូលឆ្នាំ២០១៦ ។

- ចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន សរុបចំនួន ៧.៧៥៤,៨១ ពាន់លានរៀល (ប្រមាណជា១.៩៣៨,៧១ លានដុល្លារអាមេរិក) ស្មើនឹង១១៣%នៃផែនការ និងបានបំពេញបែបបទសលាកបត្របង់ចូលថវិកាជាតិបានចំនួន ៧.៦៨៦,៨៦ ពាន់លានរៀល (ប្រមាណ១.៩២១,៧១លានដុល្លារអាមេរិក) ស្មើនឹង១១២% នៃផែនការ ។ ប្រសិនបើធៀបនឹងឆ្នាំ២០១៦ ឃើញថាការប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៧ មានការកើនឡើងចំនួន ១.៦៧៦,៣៦ ពាន់លានរៀល (ប្រមាណ៤១៩,០៩ លានដុល្លារ) ស្មើនឹង២៧.៨៩%។

- ឆ្នាំ២០១៧ ចំណូលដែលទទួលបានពីការលក់ប័ណ្ណទស្សនារមណីយដ្ឋានអង្គរមានចំនួន១០១.៩៧៦.៤៣៩ដុល្លារ។ចំនួនភ្ញៀវចូលទស្សនាមានចំនួន ២.៤៥៧.០២៣នាក់ កើនឡើងជាងឆ្នាំ២០១៦ ចំនួន១១,៨២% ។ ឧបត្ថម្ភមូលនិធិមន្ទីរពេទ្យគន្ធបុប្ផាក្នុងរយៈពេល១១ខែ មានទឹកប្រាក់ចំនួន ៤.៣៣៩.៩៦៤ដុល្លារ ។ ដោយឡែកក្នុងខែធ្នូ នេះការលក់ប័ណទស្សនារមណីដ្ឋានអង្គរទទួលបានចំណូល ១២.៣១៥.១៩៨ដុល្លារ កើនឡើង ៧១,៩៧% បើធៀបរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះភ្ញៀវចូល ទស្សនាមានចំនួន ២៦៧.២១៩នាក់ ។

- ការងារប្រមូលផលស្រូវរដូវវស្សា រហូតមកដល់ពេលនេះ សម្រេចបានចំនួន ២.៦២៩.៦០៤ហ.ត លើផ្ទៃដីអនុវត្តសរុប ២.៦៥៧.៧៦៨ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៨.០១៧.៨៣៣តោន លើសឆ្នាំមុន ៤៦២. ២៨៤តោន ។ ទិន្នផលគិតជាមធ្យម ៣,០៤៩តោន/ហ.ត លើសឆ្នាំមុន ១០៣គក្រ/ហ.ត ។ ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំង ឆ្នាំ២០១៧-២០១៨ លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ៤៧២.៨៨៥ ហ.ត ក្នុងនោះភ្ជួររាស់ដោយគោក្របីចំនួន ១១.២៩០ហ.ត ស្មើនឹង ២,៣៩% និងដោយគ្រឿងយន្តចំនួន ៤៦១.៥៩៥ហ.ត ស្មើនឹង ៩៧,៦១% តិចជាងឆ្នាំមុន ៣.៩១៦ហ.ត ។ សាបបានសរុបចំនួន ៤៥០ហ.ត តិចជាងឆ្នាំមុនចំនួន ៣០ហ.ត ស្ទូងនិងព្រោះសម្រេចបានចំនួន ៤១៩.៦៧០ហ.ត ស្មើនឹង ៩៤,៦១% នៃផែនការ ៤៤៣.៦០០ហ.ត លើសឆ្នាំមុន ១៣០ហ.ត ។ ល្បឿនការងារប្រមូលផលស្រូវរដូវប្រាំង ឆ្នាំ២០១៧-២០១៨ រហូតមកដល់ពេលនេះ សម្រេចបានចំនួន ២១.៦៣២ហ.ត លើផ្ទៃដីអនុវត្តសរុប ៤១៩.៦៧០ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៩០.៧៨០ តោន លើសឆ្នាំមុន ៥៦.៧២៧តោន ។ ទិន្នផលគិតជាមធ្យម ៤,១៩៧តោន/ហ.ត ។

- ក្នុងឆ្នាំ២០១៧ ទិន្នផលស្រូវកម្ពុជានឹងទទួលបានក្នុងរង្វង់ ១០,២៧លានតោន បើធៀបនឹងឆ្នាំ២០១៦ ទទួលបាន ៩,៨២ លានតោន ។

- ក្នុងឆ្នាំ២០១៧ ការនាំចេញអង្ករបស់កម្ពុជាសម្រេចបានជាង ៦៣,៥ម៉ឺនតោន កើនឡើងជិត ១០ម៉ឺនតោន ស្មើនឹងប្រមាណ ១៧% បើធៀបនឹងឆ្នាំ២០១៦ ដោយបាននាំចេញទៅកាន់ប្រទេសចំនួន៦៣ ក្នុងនោះប្រទេសចិនឈរ លំដាប់លេខ១ ។

- កម្ពុជាបាននាំចេញជ័រកៅស៊ូ ១៨៨.៨៣២តោន ដែលតម្លៃជាមធ្យមក្នុង១តោន ១.៥៨៦ដុល្លារ ទទួលចំណូលសរុបចំនួន ២៩៩.៤៨៧.៥៥២ដុល្លារអាមេរិក ។ បច្ចុប្បន្នប្រទេសកម្ពុជាមាន

ផ្ទៃដីចំការកៅស៊ូសរុបមានជាង៤៣៦.៣៣៩ហិកតាដែលក្នុងនោះ ផ្ទៃដីចៀរជ័រមានចំនួន ១៧០.២៣០ហិកតា ស្មើនឹង ៣៩,០១% និងផ្ទៃដីថែទាំមានចំនួន ២៦៦.១០៩ហិកតា ស្មើនឹង ៦០,៩៨% ។ នៅឆ្នាំ២០១៦ កន្លងទៅ កម្ពុជាបាននាំចេញជ័រកៅស៊ូ បានជាង ១៤ម៉ឺនតោន ទទួលបានទឹកប្រាក់ជាង ១៨០លានដុល្លារ ។ កៅស៊ូកម្ពុជាបាននាំចេញទៅកាន់ប្រទេសចិន វៀតណាម សង្ហបុរី និង ម៉ាឡេស៊ី ។

- ក្នុងឆ្នាំ២០១៧ ការនាំចេញទំនិញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មមានទឹកប្រាក់ ៩.៥៥៩.២៧១.០៦៦ដុល្លារ បើធៀបនឹងឆ្នាំ២០១៦ ដែលមានទឹកប្រាក់សរុបត្រឹមតែ ៨.០១៧.៩៧៧.៣៨១ដុល្លារ មានការកើនឡើង ១៩,២២% ។ ក្រសួងពាណិជ្ជកម្មបានផ្ដល់អាជ្ញាប័ណ្ណនាំចូលមានទឹកប្រាក់ចំនួន ២.០៨៧.៨៤៤,០៨ដុល្លារបើធៀបនឹងឆ្នាំ២០១៦មានទឹកប្រាក់សរុប៤៧៩.៤៤៥,៦៨ដុល្លារ កើនឡើងចំនួន ៣៣៥,៤៧% ។ អាជ្ញាប័ណ្ណនាំចេញមានទឹកប្រាក់សរុប ៩.១២៣.៣៩៧,៧១ដុល្លារ ធៀបនឹងឆ្នាំ២០១៦ ដែលមានទឹកប្រាក់សរុប ៦.៦៤៧.៣៣១.៨៨ដុល្លារ មានការកើនឡើង ៣៧,២៥% ។ ក្នុងឆ្នាំ២០១៧នេះដែរ ក្រសួងពាណិជ្ជកម្មបានខិតខំកៀរគរចំណូលបង់ចូលថវិកាជាតិបានប្រមាណ ២២០.១៦០.៩៩២.០១៨រៀល ស្មើនឹងជាង ៥៤លានដុល្លារ ។

- ក្នុងឆ្នាំ២០១៧ កន្លងទៅ កំពង់ផែស្វ័យតភ្នំពេញមានទំនិញឆ្លងកាត់ជាង ២,៧លានតោន កើតឡើង ១៤% នាវាឆ្លងកាត់ ១.៦៧៦គ្រឿង ថយចុះ ០,១៨% អ្នកដំណើរបរទេស និងទេសចរឆ្លងកាត់មានជាង ២,៦ម៉ឺននាក់ កើនឡើង ៦% កុងតឺន័រឆ្លងកាត់មានជាង ១៨,៤ម៉ឺន TEUs កើនឡើង ២២% ហើយចំណូលសរុបដែលទទួលបានប្រមាណ៧៥ពាន់លានរៀលឬប្រមាណ១៨លានដុល្លារ កើនឡើង ១៤% ធៀបនឹង២០១៦ ។ កំពង់ផែស្វយ័តក្រុងព្រះសីហនុមានទំនិញឆ្លងកាត់សរុបជាង ៤,៣លាន តោន កើនឡើង ៦,៥៥% នាវាឆ្លងកាត់ ១.៣០០គ្រឿង ថយចុះ ១,៦៦% កុងតឺន័រឆ្លងកាត់ជាង ៤៥ម៉ឺន TEUs កើនឡើង ១៤% បើធៀបនឹង២០១៦ រកចំណូលបានជាង ៥២លានដុល្លារ កើនឡើង ១៦,៨០% ធៀបនឹងឆ្នាំ២០១៦ ។

-ការផ្គត់ផ្គង់ថាមពលអគ្គិសនីរបស់កម្ពុជាសម្រេចបាន៦,៥ពាន់ គីឡូវ៉ាត់ម៉ោង ស្មើនឹងប្រហែល ៨០% នៃការផ្គត់ផ្គង់សរុប ។ កំណើននេះទទួលបានយ៉ាងច្រើនពីប្រតិបត្តិការរោងចក្រថាមពលដើរដោយធ្យូងថ្ម និងទំនប់វារីអគ្គិសនី ។ ក្នុងចំណោមប្រភពផ្គត់ផ្គង់សរុបគឺថាមពល ៣៩,៧៣% បានមកពីការដុតធ្យូងថ្ម ៣៣,៧២% បានមក ពីវារីអគ្គិសនី ៥,៣៣% បានមកពីការដុតប្រេង ០,៨០% បានមកពីថាមពលកកើតឡើងវិញ និង០,២% ទៀតបាន មកពីប្រភពផ្ទាល់របស់ឧស្សាហកម្ម និងអ្នកចែកចាយ ។ កម្ពុជាបាននាំចូលថាមពលចំនួន១,៦៥ពាន់លានគីឡូវ៉ាត់ម៉ោងពីប្រទេសថៃ វៀតណាម និងឡាវ ដែលស្មើនឹង ២០% នៃការផ្គត់ផ្គង់សរុប ។ អជ្ញាធរអគ្គិសនីកម្ពុជាបានផ្គត់ ផ្គង់ថាមពលដល់ ១៤.១៦៨ភូមិ ស្មើនឹង ៨១% និង ៣,៣លាន លំនៅដ្ឋាន ស្មើនឹង ៦៨,៥% ។

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានប្រមូលចំណូលចូលថវិកាជាតិសរុបចំនួនជាង ៣៧១ពាន់លានរៀល ស្មើនឹងប្រមាណជាង ៩២លានដុល្លារអាមេរិក ដោយគិតទាំងចំណូលពីការផ្ទេរអចលនទ្រព្យកើនឡើង ២១លានដុល្លារ ធៀបនឹងឆ្នាំ២០១៦ ។ ការអភិវឌ្ឍវិស័យសំណង់ទុនវិនិយោគមានចំនួន ៦.៤០០លានដុល្លារអាមេរិក កើនឡើងជិត ២២% ធៀបនឹងឆ្នាំ២០១៦ផ្ដល់ការងារធ្វើប្រចាំថ្ងៃជូនយុវជនប្រមាណ២០ម៉ឺននាក់។ ប្រកាសតំបន់វិនិច្ឆ័យតាមភូមិនៅទូទាំងប្រទេស ដើម្បីពន្លឿនការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធដែលបច្ចុប្បន្នសម្រេចបាន៦៦,៤% នៃក្បាលដីប៉ាន់ស្មានសរុបចំនួនប្រមាណ ៧លានក្បាលដី ។

-ក្រសួងសាធារណការបានចុះបញ្ជីយានជំនិះសរុបចំនួន៤២៣.៦៥២គ្រឿង ក្នុងនោះទោចក្រយានយន្តមានចំនួន ៣៦៥.៣៤៣ គ្រឿង និងរថយន្តគ្រប់ប្រភេទចំនួន ៥៩.៣០៩គ្រឿង ។ ប័ណ្ណបើកបររថយន្តត្រូវបានផ្ដល់ជាង ៩ម៉ឺនប័ណ្ណ និងពន្យាប័ណ្ណបើកបរបាន ២៣.៨៦៥ប័ណ្ណ ។

### ទំហំពាណិជ្ជកម្មកម្ពុជា-អាមេរិក

តួលេខពីការិយាល័យស្ថិតិនៃក្រសួងការបរទេសអាមេរិក បានឲ្យដឹងថា ពាណិជ្ជកម្មសរុបកម្ពុជានិងអាមេរិកក្នុងរយៈពេល១១ខែ ឆ្នាំ២០១៧ មានទំហំ ៣.១៨៧ លានដុល្លារ គឺមានការកើនឡើងប្រមាណ ០,៣៨ % ធៀបនឹង ៣ ១៧៥ លានដុល្លារដែលប្រទេសទាំងបានសម្រេចបានកាលពីឆ្នាំ២០១៦។ ក្នុងនេះកម្ពុជានាំចេញទៅអាមេរិកនៅក្នុងរយៈពេល១១ខែឆ្នាំ២០១៧មានទំហំ២ ៨២៦ លានដុល្លារកើនឡើង០,៤១%ធៀបនឹងតម្លៃពេញមួយឆ្នាំ២០១៦ ដែលមាន ២ ៨១៤,៣លានដុល្លារ ។ ដោយឡែកទំហំដែលអាមេរិកនាំចេញមកកម្ពុជាវិញ នៅក្នុងរយៈពេលដូចគ្នាមាន តម្លៃ ៣៦១,៣ លានដុល្លារ កើន ០,១៦ % ធៀបនឹង ៣៦០,៧ លានដុល្លារ នៅក្នុងរយៈពេល ១២ ខែ ឆ្នាំ២០១៦ ។

### ទំហំពាណិជ្ជកម្មកម្ពុជា-ជប៉ុន

តួលេខពីការិយាល័យពាណិជ្ជកម្មក្រៅប្រទេសជប៉ុនបានបង្ហាញថា ក្នុងរយៈពេល ១១ ខែឆ្នាំ២០១៧ កម្ពុជានាំចេញទៅជប៉ុនមានតម្លៃប្រមាណ ១ ១៥៨ លានដុល្លារអាមេរិកគឺកើនឡើងប្រមាណ០,២%។ ចំណែកជប៉ុននាំចេញមកកម្ពុជាក្នុងរយៈពេលដូចគ្នាមានទំហំ ៣១៩,២ លានដុល្លារ គឺកើនឡើង ប្រមាណ ០,១ % ៕



# ពង្រឹងយន្តការការងារឲ្យកាន់តែមានប្រសិទ្ធភាព និងស៊ីជម្រៅ ធ្វើឲ្យវិស័យពាណិជ្ជកម្មមានការរីកចម្រើនខ្លាំង



*ឯកឧត្តម **ប៉ាន សូរស័ក្តិ** អញ្ជើញចូលរួមក្នុងវេទិកាស្រូវអង្ករលើកទី៦*

ក្នុងឆ្នាំ២០១៧ កន្លងមកនេះ ក្រោមការដឹកនាំរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឲ្យវិស័យពាណិជ្ជកម្មកាន់តែមានភាពរីកចម្រើនថែមទៀត និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ។ក្រសួងពាណិជ្ជកម្មបានជំរុញការធ្វើកំណែទម្រង់លើច្រើនផ្នែក និងច្រើនវិស័យក្នុងគោលដៅជំរុញការងារគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុសាធារណៈ និងយន្តការការងារឱ្យកាន់តែមានប្រសិទ្ធភាព និងស៊ីជម្រៅ ពង្រឹងរបៀបរបបការងាររបស់មន្ត្រីរាជការក្រោមឱវាទ ចូលរួមអនុវត្តន៍កាតព្វកិច្ច និងផែនការសកម្មភាពច្បាស់លាស់ក្នុងការបំពេញការងារប្រចាំថ្ងៃ ។

មានប្រសាសន៍នៅក្នុងពិធីបិទសន្និបាតបូកសរុបការងារពាណិជ្ជកម្មឆ្នាំ២០១៧ និងទិសដៅអនុវត្តន៍ការងារពាណិជ្ជកម្មឆ្នាំ ២០១៨ កាលពីថ្ងៃទី២៨ ខែធ្នូ កន្លងទៅ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម **ប៉ាន សូរស័ក្តិ** បានបញ្ជាក់ថា៖ ដើម្បីជំរុញការផ្តល់សេវាពាណិជ្ជកម្មជូនវិស័យឯកជនប្រកបដោយតម្លាភាព ក្រសួងបានដាក់ឲ្យដំណើរការនូវការចុះបញ្ជីក្រុមហ៊ុន/សហគ្រាស ការស្នើសុំម៉ាកពាណិជ្ជកម្ម ការចេញវិញ្ញាបនបត្រប្រភពដើមទំនិញ ការទូទាត់កម្រៃសេវាតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងកំពុងតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មទាំងនេះជាមួយស្ថាប័នគយ និងពន្ធដារកម្ពុជា ដើម្បីកាត់បន្ថយការតម្រូវឯកសារជាន់គ្នារវាងក្រសួង-ស្ថាប័នរដ្ឋកាត់បន្ថយពេលវេលា និងការចំណាយមិនផ្លូវការ ។ក្នុងការកសាងបរិយាកាសអាជីវកម្មថ្មីមួយប្រកបដោយសង្គតិភាពនិងបរិយាប័ន្ន ជាពិសេសដើម្បីនាំយកសេវាសាធារណៈឲ្យទៅកៀកនឹងដៃប្រជាជន ក្រសួងពាណិជ្ជកម្មបានធ្វើប្រតិភូកម្ម និងផ្ទេរសិទ្ធិការងារមួយចំនួនជូនមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ដែលជារដ្ឋបាលថ្នាក់ក្រោមជាតិជាដំណាក់ៗ ។ ឯកឧត្តម **ប៉ាន សូរស័ក្តិ** លើកឡើងបន្តថា ក្នុងទិសដៅពង្រឹងទំនាក់ទំនងពាណិជ្ជកម្មជាមួយអន្តរជាតិឲ្យកាន់តែរឹងមាំ ក៏ដូចជាដើម្បីជំរុញការនាំចេញទំនិញពីកម្ពុជា ក្រសួងបានចូលរួម និងរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេសបានជាច្រើនលើកច្រើនសារ ។ ភ្ជាប់ជាមួយព្រឹត្តិការណ៍ពិព័រណ៍ទាំងនោះ ក្រសួងក៏បានរៀបចំវេទិកាពាណិជ្ជកម្ម និងវិនិយោគជាច្រើនផងដែរ ដើម្បីផ្សព្វផ្សាយជូនវិនិយោគិន និងធុរជនបរទេសឲ្យបានយល់ពីគោលនយោបាយពាណិជ្ជកម្ម និងវិនិយោគរបស់កម្ពុជា ។ តាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្មបានឲ្យដឹងថា ការនាំចេញទំនិញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មមានទឹកប្រាក់ចំនួន ៩.៥៥៩.២៧១.០៦៦ដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០១៦ កន្លងទៅ ដែលមានទឹកប្រាក់សរុប ៨.០១៧.៩៧៧.៣៨១ដុល្លារនោះ ឃើញថាមានការកើន ឡើងចំនួន១៩,២២% ។

ក្រសួងក៏បានផ្តល់អាជ្ញាប័ណ្ណនាំចូលមានទឹកប្រាក់សរុបចំនួន ២.០៨៧.៨៤៤,០៨ដុល្លារ បើធៀបនឹងឆ្នាំ២០១៦មានទឹកប្រាក់សរុបចំនួន ៤៧៩.៤៤៥,៦៨ដុល្លារ កើនឡើងចំនួន ៣៣៥,៤៧% ។ អាជ្ញាប័ណ្ណនាំចេញមានទឹកប្រាក់សរុបជិត ៩.១២៣.៣៩៧,៧១ ដុល្លារ ប្រៀបធៀបឆ្នាំកន្លងទៅមានការកើនឡើង ៣៧,២៥% ។ ក្រសួងពាណិជ្ជកម្មក៏បានខិតខំកៀរគរចំណូលបង់ចូលថវិកាជាតិបានប្រមាណ ៥៤លានដុល្លារអាមេរិក ។ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានលើកឡើងថា ក្រសួងបាននឹងកំពុងអនុវត្តន៍យ៉ាងយកចិត្តទុកដាក់ ក្នុងបំណងលើកស្ទួយកំរិតជីវភាពប្រជាជន និងមូលដ្ឋានជំរុញការអភិវឌ្ឍន៍ផលិតផលដែលមានស្រាប់ និងរៀបចំគោលនយោបាយអភិវឌ្ឍន៍ផលិតផលថ្មីៗដូចជា អង្ករដំឡូងមី ម្រេច ជាដើម ដើម្បីធ្វើព្រឹត្តិកម្ម និងជំរុញការនាំចេញផលិតផលសក្តានុពលរួមមាន៖ ស្វាយ ចេក ស្ករស ស្ករត្នោត សូត្រ អំពៅ។ល។ ចំពោះទិសដៅការងារនាំចេញ-នាំចូលពាណិជ្ជកម្មនៅឆ្នាំ២០១៨ ខាងមុខ ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ថា ក្រសួងនឹងបន្តសហការ និងចូលរួមចុះអង្កេតប្រភពដើមទំនិញជាមួយគយក្រុមការងារចុះអង្កេតនានា នៃប្រទេសផ្តល់ភាពអនុគ្រោះពាណិជ្ជកម្ម និងបន្តសហការជាមួយស្ថាប័នពាក់ព័ន្ធរៀបចំតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មវិញ្ញានបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី (D) ទៅក្នុងបញ្ជរតែមួយជាតិ និងឈានទៅការភ្ជាប់បញ្ជរតែមួយអាស៊ាន ក៏ដូចជាបន្តថែទាំកែលម្អប្រព័ន្ធស្វ័យប្រវត្តិកម្មវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញជាដើម ។ ឯកឧត្តម **ប៉ាន សូរស័ក្តិ** បានបន្តទៀតថា ក្រសួងពាណិជ្ជកម្ម បាននិងកំពុងអនុវត្តន៍យ៉ាងយកចិត្តទុកដាក់ចំពោះការជំរុញ ការអនុវត្តគោលនយោបាយ អភិវឌ្ឍន៍ពាណិជ្ជកម្មក្នុងប្រទេស ការអភិវឌ្ឍផលិតផលតាមមុខទំនិញនីមួយៗ ការងារគ្រប់គ្រងគុណភាព និងសុវត្ថិភាពទំនិញ ការងារស្ថិរភាពថ្លៃទំនិញ និងគ្រប់គ្រងអតិផរណាទំនិញនៅលើទីផ្សារ ក្នុងគោលបំណងលើកស្ទួយកម្រិតជីវភាពប្រជាជននៅមូលដ្ឋាន ជាពិសេសអ្នកផលិត និងអ្នកដាំដុះ ។ ក្រៅពីនេះក្រសួងបានខិតខំបំពេញការងារយ៉ាងសកម្មក្នុងការថែរក្សាទីផ្សារដែលមានស្រាប់ និងពង្រីកទីផ្សារថ្មីៗបន្ថែម តាមរយៈលើកទឹកចិត្តដល់វិស័យឯកជនឱ្យ

តទៅទំព័រទី ២៨

# សមិទ្ធផលដ៏សំខាន់ដែលបានមកពីការពង្រឹងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍដោយចីរភាព



*ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ថ្លែងក្នុងអង្គសន្និបាតសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៨ និងទិសដៅការងារឆ្នាំ២០១៨*

នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៅរដ្ឋសភា បានកំណត់ច្បាស់ក្នុងកិច្ចខិតខំ ថែរក្សាការពារបរិស្ថាន ដើម្បីជាប្រយោជន៍ដល់ប្រជាជនទូទៅទាំងក្នុងពេលបច្ចុប្បន្ន និងពេលអនាគតព្រមទាំង ដើម្បីធានាដល់ការលូតលាស់នៃសង្គម-សេដ្ឋកិច្ចសុខមាលភាពសាធារណៈ ។ ជាសេនាធិការឲ្យរាជរដ្ឋា-ភិបាល ក្រសួងបរិស្ថានក៏បានយកចិត្តទុកដាក់ពង្រឹងការអនុវត្តច្បាប់ស្តីពីបរិស្ថាន ថែរក្សាបានតំបន់ការពារធម្មជាតិ ទប់ស្កាត់បានរាល់សកម្មភាពបានបំផ្លាញគុណភាពបរិស្ថាន និងបញ្ចៀសគ្រោះមហន្តរាយនានា ។ ជាក់ស្តែងនៅ ក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំទី៤ នៃការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងបរិស្ថានបានធ្វើឲ្យ សម្រេចនូវជោគជ័យធំៗជាច្រើន ជាពិសេសបានធ្វើឲ្យមានការផ្លាស់ប្តូរនូវឥរិយាបថរបស់សាធារណៈជន លើកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព ។

នៅក្នុងសន្និបាតបូលសរុបការងារបរិស្ថានឆ្នាំ ២០១៧ និងទិសដៅ ការងារឆ្នាំ២០១៨ អង្គសន្និបាតបាន វាយតម្លៃខ្ពស់ចំពោះលទ្ធផលការងារ និងសមិទ្ធផលដែល គួរឲ្យកត់សម្គាល់ដែលក្រសួងបរិស្ថាន និងក្រុមប្រឹក្សា ជាតិអភិវឌ្ឍន៍ដោយចីរភាពសម្រេចបានក្នុងរយៈពេលកន្លងមក ដែលក្នុងនោះរួមមាន : ការធ្វើទំនើបកម្មស្ថាប័ន កិច្ចគាំពារបរិស្ថាន ការងារការពារ និងអភិរក្សធនធានធម្មជាតិ ការអភិវឌ្ឍដោយចីរភាព ការងារអប់រំ និងផ្សព្វ-ផ្សាយព័ត៌មានបរិស្ថានជាដើម ។ តាមសេចក្តីសម្រេចរបស់រាជ-រដ្ឋាភិបាលក្រសួងបរិស្ថានបានធ្វើការផ្ទេរគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច ចំនួន៧៣ ពីក្រសួងបរិស្ថានទៅឲ្យក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងផ្ទេរតំបន់ព្រៃការពារចំនួន១៣កន្លែង និងព្រៃផ្តល់ផលចំនួន៥កន្លែង ពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មកក្រសួងបរិស្ថានវិញ ។ អនុវត្តយ៉ាងម៉ឺងម៉ាត់ និងជាប់ជាប្រចាំក្នុងការពង្រឹងវិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ដោយពង្រឹងបានកិច្ចសហការល្អជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាល ខេត្ត ក្រុង ស្រុក ខណ្ឌ ។ តំបន់ការពារធម្មជាតិត្រូវបានបង្កើនពីចំនួន ២៣កន្លែង ដល់ ៥០កន្លែង ហើយរបៀង អភិរក្សជីវៈចម្រុះ ប្រព័ន្ធតំបន់ការពារធម្មជាតិចំនួន ៣ កន្លែងត្រូវបានបង្កើត ដែលធ្វើឲ្យវិសាលភាពប្រព័ន្ធតំបន់ ការពារធម្មជាតិគ្របដណ្តប់លើផ្ទៃដីប្រមាណ ៧,៥លានហ.ត ស្មើនឹង ៤១% នៃផ្ទៃប្រទេស ។ រៀបចំកំណត់តំបន់គ្រប់គ្រង និងរៀបចំផែនការគ្រប់គ្រងបោះបង្គោលព្រំប្រទល់ តំបន់ការពារធម្មជាតិមួយចំនួនព្រមទាំងបាន សិក្សាប្រមូលទិន្នន័យព័ត៌មានភូមិសាស្ត្រ ដើម្បីធ្វើបច្ចុប្បន្នភាពផែនទីតំបន់ការពារធម្មជាតិឡើងវិញ ។ ការដាំស្តារព្រៃឈើឡើងវិញ ក៏ត្រូវបានធ្វើនៅតាមតំបន់ការពារធម្មជាតិ តំបន់សហគមន៍មូលដ្ឋាន និងទីសាធារណៈនានា ។ ក្រសួងបានធ្វើការសិក្សាវាយតម្លៃសក្តានុពលជីវៈចម្រុះ និងធនធានធម្មជាតិនៅតំបន់មួយចំនួន ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតតំបន់ការពារធម្មជាតិ និងសហគមន៍ការពារធម្មជាតិថ្មីៗបន្ថែមទៀត ។ កិច្ចសហការក្នុងចំណោមក្រសួងស្ថានប័នពាក់ព័ន្ធលើការរៀបចំផែនទីឯកភាពត្រូវបានផ្តួចផ្តើមឡើង ដើម្បីពង្រឹងការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីដូចជា ដីលំនៅដ្ឋាន សម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច តំបន់អភិរក្ស និងតំបន់ការពារធម្មជាតិ ។ ជាមួយគ្នានេះក្រសួងបរិស្ថានបានអនុវត្តគម្រោងរេដបូកនៅ ដែនជម្រកសត្វព្រៃ «កែវសីមា» តាំងពីឆ្នាំ២០១៦ ចំណែកគម្រោងរេដបូកនៅដែនជម្រកសត្វព្រៃ «ព្រៃឡង់» ឧទ្យានជាតិជួរភ្នំក្រវ៉ាញខាងត្បូង និងដែនជម្រកសត្វព្រៃតាតៃក៏កំពុងត្រូវបានសិក្សារៀបចំហើយដែរ ។ សហគមន៍តំបន់ការពារធម្មជាតិត្រូវបានបង្កើនពីចំនួន ១២៣ ដល់ ១៥២ ហើយការបណ្តុះបណ្តាល និងគាំទ្រដល់សហគមន៍លើការលើកកម្ពស់ជីវភាពរស់នៅក៏ត្រូវបានរៀបចំ និងអនុវត្ត ។ ដោយឡែកក្រសួងបរិស្ថាន ក៏បានពង្រឹងការគ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ និងសហគមន៍ទេសចរណ៍ធម្មជាតិស្របតាមនីតិវិធីច្បាប់ ។ ចំណែកតំបន់សក្តានុពលទេសចរណ៍ធម្មជាតិចំនួន ៩៧កន្លែង ក៏កំពុងត្រូវបានសិក្សាដើម្បីរៀបចំបង្កើតរបៀងទេសចរណ៍ធម្មជាតិ ។ ទីតាំងប្រាសាទ និងបុរាណស្ថានចំនួន ៦៥កន្លែង កំពុងត្រូវបានសិក្សា ដោយសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីចងក្រងសៀវភៅ «បញ្ជីសារពើភណ្ឌនៃប្រាសាទបុរាណ និងបុរាណស្ថាន ឆ្នាំ២០១៩» ។

ប៉ុន្តែក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចជា បញ្ហាធនធានមនុស្សធនធានហិរញ្ញវត្ថុមធ្យោបាយនិងសម្ភារៈហេដ្ឋារចនាសម្ព័ន្ធរូបវន្ត លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ មិនទាន់អាចឆ្លើយតបបានទៅនឹងទំហំ និងកំណើនការងារ ។ ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោងវិនិយោគអភិវឌ្ឍន៍មួយចំនួននៅមានភាពខ្វះខាត និងយឺតយ៉ាវ ហើយម្ចាស់គម្រោង

វិនិយោគមួយចំនួនមិនទាន់បានអនុវត្តការបង់មូលនិធិទាយជ្ជទានបរិស្ថាន និងមូលនិធិបរិស្ថាន និងសង្គម ។ បទល្មើសធនធានធម្មជាតិទ្រង់ទ្រាយតូច នៅតែបន្តកើតមានក្នុងតំបន់ការពារធម្មជាតិ និងតំបន់សហគមន៍ ។ តំបន់ការពារធម្មជាតិទាំងអស់នៅមិនទាន់បានចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋ ហើយតំបន់ការពារធម្មជាតិភាគច្រើននៅមិនទាន់មានការកំណត់តំបន់គ្រប់គ្រងការបោះ បង្គោលកំណត់ព្រំប្រទល់ និងការរៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិនៅឡើយ ។ ការតាមដាននិងត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងគម្រោងសម្បទានដីសង្គមកិច្ច ជាពិសេសការអនុញ្ញាតឲ្យឈូសឆាយដី និងការប្រមូល និងដឹកជញ្ជូនផល - អនុផលព្រៃឈើនៅមានភាពខ្វះចន្លោះ ដែលអាចបង្ករឲ្យមានបទល្មើស ។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ក្រសួងបរិស្ថានក៏បានដាក់ចេញនូវទិសដៅមួយចំនួន ដើម្បីអនុវត្តនៅឆ្នាំខាងមុខ ។ ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថានបានថ្លែងថា ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់សហគមន៍ជាចំណុចគន្លឹះ ដើម្បីកាត់បន្ថយសម្ពាធលើការប្រើប្រាស់ធនធានធម្មជាតិ ក៏ដូចជាជំរុញការចូលរួមសហគមន៍ក្នុងការងារគ្រប់គ្រងធនធានធម្មជាតិ រក្សាតម្លៃវប្បធម៌ និងប្រពៃណីរបស់ជនជាតិដើមភាគតិច ។ ការពង្រឹងសមត្ថភាពមន្ត្រីជំនាញ និងមន្ត្រីឧទ្យានុរក្ស ដែលមានតួនាទីជាមន្ត្រីនគរបាលយុត្តិធម៌ និងជាភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិគ្រប់ប្រភេទ ក៏ជាកិច្ចការចាំបាច់ដែរ ។ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថានបានស្នើឲ្យជំរុញការរៀបចំបង្កើតរបៀងទេសចរណ៍ធម្មជាតិ និងបន្តជំរុញលើកទឹកចិត្តដល់វិស័យឯកជន និងសហគមន៍មូលដ្ឋានក្នុងការអភិវឌ្ឍទេសចរណ៍ធម្មជាតិនៅតាមទីតាំងដែលមានសក្តានុពល ក៏ដូចជាបន្តសិក្សាតំបន់ដែលមានសក្តានុពល ដើម្បីបង្កើតជាតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិបន្ថែមទៀត ដោយសហការយ៉ាងជិតស្និទ្ធជាមួយគ្រប់ភាគីពាក់ព័ន្ធ ។ លើសពីនេះទៅទៀត ត្រូវបន្តតាមដានត្រួតពិនិត្យ និងពង្រឹងការអនុវត្តមុខងារគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិ ដែលបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ឯកឧត្តម **សាយ សំអាល់** បានស្នើឲ្យយកចិត្តទុកដាក់លើការអនុវត្តគម្រោងចុះបញ្ជីដីរដ្ឋសាកល្បង សម្រាប់ដែនជម្រកសត្វព្រៃពាមក្រសោប និងដែនជម្រកសត្វព្រៃភ្នំព្រេច ដែលគាំទ្រថវិកាដោយ ADB ដើម្បីដកស្រង់បទពិសោធក្នុងការចុះបញ្ជីដីរដ្ឋ សម្រាប់តំបន់ការពារធម្មជាតិដទៃទៀត (ក្នុងនាមជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ) និងបន្តសិក្សាប្រមូលទិន្នន័យព័ត៌មានភូមិសាស្ត្រ និងបកប្រែទិន្នន័យពីផ្កាយរណប ដើម្បីធ្វើបច្ចុប្បន្នភាពផែនទីតំបន់ការពារធម្មជាតិឡើងវិញ រួមទាំងការយកចិត្តទុកដាក់រៀបចំកំណត់តំបន់ និងរៀបចំផែនការគ្រប់គ្រង ក៏ដូចជាការបោះបង្គោលព្រំប្រទល់ តំបន់ការពារធម្មជាតិឲ្យបានច្បាស់លាស់ ៕

តមកពីទំព័រទី ២៦



*ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ចុះសិក្សាសហគ្រាសផលិតម្សៅដំឡូងមី និងស្វែងយល់អំពី បញ្ហាប្រឈមផ្សេងៗ*

ខិតខំបង្កើតគំនិតច្នៃប្រឌិត ផលិតនូវទំនិញថ្មីៗសម្រាប់បម្រើទីផ្សារទាំងក្នុងប្រទេសនិងជំរុញការនាំចេញ។ ដើម្បីបង្កភាពងាយស្រួលដល់បរិយាកាសអាជីវកម្ម ក្រសួងពាណិជ្ជកម្ម បានដាក់ឱ្យដំណើរការនូវការចុះបញ្ជីក្រុមហ៊ុនសហគ្រាស ការចេញវិញ្ញាបនបត្រប្រភពដើមទំនិញ ការទូទាត់កម្រៃសេវា ការស្នើសុំម៉ាកពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម សំដៅកាត់បន្ថយពេលវេលា និងការចំណាយមិនផ្លូវការផ្សេងៗ ។

ឯកឧត្តម **ប៉ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីបានសម្តែងការស្ងើចសរសើរចំពោះសមិទ្ធផលសំខាន់ៗ ដែលសម្រេចបានដោយមន្ត្រីក្រសួងពាណិជ្ជកម្មគ្រប់លំដាប់ថ្នាក់ក្នុងឆ្នាំ២០១៧នេះលើការងារមួយចំនួនដូចជា ប្រទេសកម្ពុជាបានទទួលភាពអនុគ្រោះពន្ធ និងមិនជាប់កូតាពី បណ្តាប្រទេសសមាជិកអង្គការពាណិជ្ជកម្ម ពិភពលោកជាច្រើន ដែលធ្វើឲ្យផលិតកម្មក្នុងស្រុក និងការនាំចេញមានកំណើនគួរឲ្យកត់សម្គាល់ និងបានចរចាពង្រីកទីផ្សារសម្រាប់ទំនិញចេញក្រោមក្របខ័ណ្ឌអាស៊ាន, អាស៊ានបូកជាមួយដៃគូពាណិជ្ជកម្មសំខាន់ៗ ជាពិសេសបានពង្រីកទីផ្សារនាំចេញអង្ករទៅកាន់សាធារណរដ្ឋប្រជាមានិតចិន សហគមន៍អឺរ៉ុប និងបង់ក្លាដែស។ល។ ជាមួយគ្នានេះ ទន្ទឹមនឹងសមិទ្ធផលយ៉ាងច្រើនដែលក្រសួងពាណិជ្ជកម្មសម្រេចបាននេះ ឯកឧត្តម **ប៉ិន ឈិន** បានពិនិត្យឃើញថា ក្រសួងនៅមានចំណុចខ្វះខាតត្រូវកែលម្អកាលានុវត្តភាព និងផែនការការងារពាណិជ្ជកម្មសំខាន់ៗមួយចំនួន ដែលត្រូវធ្វើបន្តក្នុងឆ្នាំ២០១៨ ខាងមុខ ។ ដើម្បីជាធាតុចូលសម្រាប់ការងារពាណិជ្ជកម្មឆ្នាំខាងមុខ ក្រសួងគួរពិនិត្យលទ្ធភាពធ្វើពិពិធកម្មផលិតផលនាំចេញ និងទីផ្សារថ្មីៗបន្ថែមទៀត ដើម្បីចៀសវាងគំនាបមិនសមហេតុផល ពីបណ្តាប្រទេសនាំចូលមួយចំនួនមកលើកម្ពុជា ក្នុងបរិបទនយោបាយបច្ចុប្បន្ន និងអនាគត ។ ខិតខំសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីតភ្ជាប់ការងារពាណិជ្ជកម្ម និងដឹកជញ្ជូន ជាមួយប្រទេសដៃគូរពាណិជ្ជកម្មសំខាន់ៗក្នុងតំបន់ សំដៅជំរុញការអភិវឌ្ឍសហគ្រាសមីក្រូខ្នាតតូច និងមធ្យម (MSMEs) របស់កម្ពុជាជាដើម៕

# ឃុំមង់រៀវ នារដូវរំហើយ



ផ្លូវលំឆ្លងកាត់ខាត់ខ្វែងក្នុងភូមិសាស្ត្រឃុំមង់រៀវ



មណ្ឌលសុខភាពឃុំមង់រៀវ

ក្នុងរដូវរំហើយនេះ ទេសភាពនៃស្រុកស្រែ ចំការមានលក្ខណៈ ស្រស់ប្លែកមួយបែប បើធៀបទៅនឹងរដូវវស្សា ឬក៏រដូវប្រាំង ហើយទិដ្ឋភាពដ៏ត្រកាលនេះវាធ្វើឲ្យអារម្មណ៍របស់អ្នក ដែលបានឃើញបានទៅដល់ ពិតជាមានមនោសញ្ចេតនាផ្សាភ្ជាប់មិនអាចបំភ្លេចបាន ។ បើទីនោះជាទីកដី ដែលប្រជាជនយើងមានប្រពៃណីធ្វើចំការ ច្បារដំណាំនានាក្រោយពីធ្វើស្រែវស្សារួចហើយនោះធម្មជាតិដ៏ស្រស់បំព្រងខៀវស្រងាត់ប្រាកដជា អណ្ដែតរូបរាងឡើងនៅក្នុងក្រសែភ្នែករបស់យើង នឹងធ្វើឲ្យយើងកាន់តែជក់ចិត្តជិតអារម្មណ៍ ធ្វើឲ្យកាន់តែចង់គយគន់មិនដាក់ភ្នែក ។ ជាក់ស្ដែងឃុំមង់រៀវនារដូវរំហើយនេះ ពិតជាបង្ហាញនូវភាពស្រស់ត្រកាលយ៉ាងក្រៃលែង ជាមួយនឹងចំការ ម្រេច និងចំការដំឡូងរាប់សិបហិចតា ព្រមទាំង ចំការបន្លែ ដែលមួយចំនួនបានផ្ដល់ផលនិងមួយចំនួនទៀត កំពុងដុះលូតលាស់ផ្ដល់ក្ដីសង្ឃឹមយ៉ាងខ្លាំង ដល់ប្រជាកសិករយើងនៅទីនោះ ។

ឃុំមង់រៀវ ជាឃុំមួយស្ថិតក្នុងចំណោមឃុំទាំង១៤ ក្នុងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ចែក ចេញជា១១ភូមិ ។ ឃុំនេះមានប្រជាជនរស់នៅ សរុបចំនួន ១៩៣៤ គ្រួសារ មានមនុស្សសរុប ១០.២៧៩នាក់ ក្នុងនោះស្រីមាន ៥.៣១៧នាក់ ។ ឃុំមង់រៀវស្ថិតនៅទិសអគ្នេយ៍ នៃសាលាស្រុកត្បូងឃ្មុំចម្ងាយ ៥គីឡូម៉ែត្រ ដែលមានព្រំប្រទល់ខាងជើងទល់ចំការកៅស៊ូជប់ ឃុំជប់ ខាងកើត ទល់សង្កាត់សួង ក្រុងសួង ខាងត្បូងទល់ឃុំដីគរ និងខាងលិចទល់ឃុំជប់ ។ ជីវភាពរស់នៅរបស់ប្រជាជនមានការរីក-ចម្រើនជាលំដាប់អាស្រ័យ ដោយបងប្អូនខិតខំធ្វើស្រែចំការបង្កបង្កើនផល និងធ្វើការងារផ្សេងៗទៀត ដើម្បីបង្កើនប្រភពចំណូល ។ ផ្ទះណាក៏មានយានយន្ត ដូចជាម៉ូតូ និងរថយន្តប្រើប្រាស់ ។ និយាយដល់ការរីកចម្រើន នេះ គេក៏មិនភ្លេចនឹងរំឭកទៅដល់ភាពក្រីក្រ តោកយ៉ាក ក្រោយថ្ងៃរំដោះចេញរបប ប៉ុល ពត ដែលនៅពេលនោះ ប្រជាជនត្រូវបានសង្គ្រោះចេញពីរបបប្រល័យពូជសាសន៍ ហើយក៏ត្រូវរស់នៅឆ្លងកាត់ដំណាក់កាលមួយ ដែលប្រទេសជាតិ មានសន្តិភាពផង និងសង្គ្រាមផង ។ លោក **គុយ សេង** ប្រធានគណៈកម្មាធិការគណបក្សឃុំ និងជាមេឃុំមង់រៀវ បានមានប្រសាសន៍ថា សមិទ្ធផលដែលបានកើតឡើងនៅក្នុងឃុំនេះ គឺបានមកដោយការជួយឧបត្ថម្ភគាំទ្រពី ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាតាមរយៈ ក្រុមការងារចុះជួយឃុំ សប្បុរសជននានា និងការរួមចំណែកយ៉ាងធំធេង របស់ប្រជាជននៅក្នុងមូលដ្ឋាននេះតែម្ដង ។ ប៉ុន្តែសំខាន់បំផុតយើងត្រូវនិយាយពីសន្តិភាព ។ គ្មានសន្តិភាព គឺមិនអាចអភិវឌ្ឍន៍មូលដ្ឋាន ភូមិ ឃុំ របស់ខ្លួនបានដូចពេលនេះទេ ។

ឃុំមង់រៀវ មានផ្ទៃដីបង្កបង្កើនផលសរុប ១៤៧០ហ.ត ក្នុងនោះដីស្រែមាន ១៣២០ហ.ត ដីចំការមាន ១៥០ហ.ត ។ ក្នុងរដូវការងារបង្ករ បង្កើនផលឆ្នាំ២០១៧ ប្រជាកសិករយើង ធ្វើស្រែវស្សាបាន ១០២០ហ.ត ធ្វើស្រូវបង្កើនរដូវ បាន ៦៨៥,៥០ហ.ត ដាំដំណាំដំឡូងបាន ១២០ហ.ត ព្រមទាំងដំណាំផ្សេងៗបាន ៣០ ហ.ត ។ ដោយឡែកវិស័យអប់រំសិក្សាធិការឃុំ មង់រៀវមានសាលារៀនចំនួន ៤កន្លែងក្នុងនោះមានអនុវិទ្យាល័យ **ហ៊ុន សែន** ព្រៃកោះ មាន ២ខ្នង ចែកចេញជា ១១បន្ទប់ មានសិស្សានុសិស្សសរុប ២២៣នាក់ (ស្រី ១៥៣នាក់) និងមាន លោកគ្រូអ្នកគ្រូចំនួន ៩នាក់ (ស្រី៤នាក់) ។ សាលាបឋមសិក្សា មានចំនួន ៣កន្លែង គឺសាលា បឋមសិក្សាសំរោងបុរី សាលាបឋមសិក្សាព្រៃកោះ និងសាលាបឋមសិក្សាជ្រោយចង្ហា ដែលសរុបសាលាទាំង ៣នេះមាន ៣១បន្ទប់ មានសិស្ស ១០០៧នាក់ (ស្រី ៥០១នាក់) ។ សាលាមត្តេយ្យសិក្សាមានចំនួន ៣បន្ទប់ សិស្សសរុប ៩៨នាក់ (ស្រី ៥៨នាក់) លោកគ្រូអ្នកគ្រូ សរុប ២៩នាក់ (ស្រី១៦នាក់) ។ ប្រជាជនយើងនៅទីនេះ ដែលជាឪពុកម្ដាយ ជាអាណាព្យាបាល បានយកចិត្តទុកដាក់ខ្លាំងណាស់ ក្នុងការបញ្ជូនកូនឲ្យទៅសិក្សាក្រេបជញ្ជក់យកចំណេះវិជ្ជា ។ គ្រួសារខ្លះ បានបញ្ជូនកូនឲ្យមកសិក្សានៅថ្នាក់ វិទ្យាល័យសាកលវិទ្យាល័យនៅឯរាជធានីភ្នំពេញ ទៀតផង ។ ឃុំនេះក៏មានមណ្ឌលសុខភាពមួយកន្លែង ដែលត្រូវបានកសាងឡើងសម្រាប់ផ្ដល់សេវាសុខភាពជូនប្រជាជន ដោយមិនត្រឹមតែជួយព្យាបាលដល់ប្រជាជនក្នុងឃុំមង់រៀវ ប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីព្យាបាលជូនប្រជាជន ដែលនៅឃុំក្បែរៗនោះដែរ ។ ក្រៅពីនេះការកសាង

ផ្លូវលំជនបទនៅក្នុងមូលដ្ឋាន ឃុំមង់រៀវ ក៏មានសកម្មភាពមមាញឹកណាស់ដែរ ហើយដែលមកដល់បច្ចុប្បន្នផ្លូវជាច្រើន ត្រូវបានស្ថាបនាឡើង តភ្ជាប់សសៃគមនាគមន៍ពីភូមិមួយទៅភូមិមួយ បង្ករលក្ខណៈជូនប្រជាជនធ្វើដំណើរបានងាយស្រួល ឆាប់រហ័ស កាត់បន្ថយបានពេលវេលា កាត់បន្ថយការចំណាយ ប្រាក់ជាពិសេសការដឹកជញ្ជូនផលដំណាំទៅ លក់នៅឯទីផ្សារ ។ គិតចាប់តាំងពីក្រោយថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ខែមិថុនា ឆ្នាំ២០១៧ នៅក្នុងឃុំមង់រៀវ បានធ្វើការជួសជុល និងឈូសឆាយ ផ្លូវបានចំនួន ៥ខ្សែ ប្រវែង ១៤.៥២០ម៉ែត្រ ។ អ្នកស្រី **ជេត លក្ខិណា** អាយុ ៤០ឆ្នាំ រស់នៅភូមិជើងខាល ឃុំមង់រៀវ ស្រុក/ខេត្តត្បូងឃ្មុំ បានសម្ដែងទឹកចិត្តរីករាយយ៉ាងខ្លាំងចំពោះផ្លូវលំជនបទ ដែលតភ្ជាប់ប្រទាក់ក្រឡាគ្នា ងាយស្រួលក្នុងការធ្វើដំណើរ ដែលតាំងពីដើមរៀងមកមិនដែលមានទាល់តែសោះ។អ្នកស្រីបានបញ្ជាក់ថា តើយើងចង់បានអីឲ្យហួសពីនេះទៀត ? ប្រទេសជាតិមានសុខសន្តិភាព ហើយយើងរាល់គ្នាមានសេរីភាពគ្រប់សព្វបែប យ៉ាងហើយ ។ យើងអាចប្រកបមុខរបររកស៊ីបានដោយសេរី ទៅតាមលទ្ធភាពរៀងៗខ្លួន កុំឲ្យតែយើងទៅរកស៊ីខុសច្បាប់ ។ ខ្ញុំសូមទទួល យកដោយពេញចិត្ត នូវការដឹកនាំរបស់សម្ដេច តេជោរបស់គណបក្សប្រជាជនកម្ពុជា ហើយខ្ញុំគាំទ្រសម្ដេច និងគាំទ្រគណបក្សជារៀងរហូត ។ លោកអ៊ុំ **ឈិន រីម** អាយុ៦៦ឆ្នាំ ជាកសិករ រស់នៅភូមិជើងខាល ឃុំមង់រៀវ ស្រុក/ខេត្ត ត្បូងឃ្មុំ ក៏បានមានប្រសាសន៍ដែរថា ភូមិឃុំ ដែលគាត់រស់នៅនេះពីដើមឡើយ មិនដែលមានសមិទ្ធផលច្រើនស្អេកស្កះបែបនេះទេ ។ ផ្លូវក៏លំបាកធ្វើដំណើរចង់ដើរ ពីភូមិមួយទៅភូមិមួយ ត្រូវដើរកាត់ព្រៃ កាត់ថ្លុក ។ គ្មានសាលារៀន គ្មានផ្ទះពេទ្យ ។ ជីវភាពប្រជាជនក្រីក្រលំបាកណាស់ ពិសេសក្រោយរំដោះចេញពីរបប ប៉ុល ពត ភ្លាមៗ ។ ប៉ុន្តែបច្ចុប្បន្ននេះប្រជាពលរដ្ឋនៅក្នុងឃុំមង់រៀវ មានជីវភាពធូរធារ ក្នុងភូមិឃុំមានសន្តិសុខល្អ បង្កើតបាននូវភាពកក់ក្ដៅគ្មានការភ័យខ្លាចណាមួយឡើយ ។ អាជ្ញាធរមូលដ្ឋានក្នុងឃុំមង់រៀវ ក៏តែងតែបានយកចិត្តទុកដាក់ជួយដោះស្រាយនូវរាល់សំណូមពរ និងការលំបាកនានារបស់ប្រជាជន ដោយគ្មានរើសអើង មិនអល់អែកក្នុងកិច្ចការណាមួយឡើយ ។

ពីនេះទៅមុខ តើអាជ្ញាធរឃុំ ក៏ដូចជាគណបក្សប្រជាជនកម្ពុជាឃុំមង់រៀវត្រូវធ្វើអ្វីបន្តទៀត? លោក **គុយ សេង** បានមានប្រសាសន៍ឲ្យដឹងថា ទិសដៅការងារនៅក្នុងឆ្នាំ២០១៨ ដែលជាឆ្នាំបោះឆ្នោតជ្រើសតាំងព្រឹទ្ធសភា ក៏ដូចជាការបោះឆ្នោតជ្រើសរើសរដ្ឋសភានីតិកាលទី៦ គណបក្សឃុំ ក៏បានយកចិត្តទុកដាក់ប្រមូលផ្ដុំទៅលើបញ្ហាមួយចំនួនដែលជាអាទិភាព ដែលក្នុងនោះ រួមមានខិតខំពង្រឹងសន្តិសុខសុវត្ថិភាព សណ្ដាប់ធ្នាប់សាធារណៈ ជូនប្រជាពលរដ្ឋតាមរយៈការអនុវត្តជាប្រចាំដូចក្បៀងរលឹម នូវគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព ។ បង្កើនការយកចិត្តទុកដាក់អំពីបញ្ហាសន្តិសុខស្បៀង គិតគូទៅដល់ សុខទុក្ខរបស់ប្រជាជន ដោះស្រាយបញ្ហាលំបាកជូនប្រជាជន ធ្វើយ៉ាងណាលើកកម្ពស់ជីវភាព ប្រជាជនឲ្យបានកាន់តែល្អប្រសើរ ពីមួយថ្ងៃទៅមួយថ្ងៃ ។ ខិតខំចុះសាកសួរសុខទុក្ខប្រជាជន នៅតាមភូមិឲ្យបានជាប្រចាំ ដើម្បីពន្យល់ណែនាំគាត់ឲ្យយល់បានកាន់តែច្បាស់ អំពីការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា និងគណបក្សប្រជាជនកម្ពុជា និងរួមគ្នាទប់ស្កាត់ឲ្យបានឧបាយកលដ៏អាក្រក់ ជួរជាតិរបស់ពួកប្រឆាំង ដែលកន្លងមកធ្លាប់ធ្វើសកម្មភាពឃោសនាញុះញង់បំបែកបំបាក់ចំណងសាមគ្គីភាព របស់ប្រជាជនក្នុងមូលដ្ឋានភូមិឃុំរបស់យើង ។ បន្តខិតខំជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលខូចទ្រុឌទ្រោម និងដោះស្រាយប្រព័ន្ធធារាសាស្ត្រតាមរយៈការស្ដារការបើកផ្លូវប្រែភពទឹក ដោះស្រាយទឹកជូនប្រជាកសិករសម្រាប់ការងារបង្ករបង្កើនផល ។



លោក **គុយ សេង** ប្រធានគណៈកម្មាធិការគណបក្សឃុំ និងជាមេឃុំមង់រៀវ

ការងារទាំងអស់នេះ ពិតជាមានភាពលំបាកពីព្រោះថា នៅពេលដែលមូលដ្ឋានភូមិឃុំរបស់យើងកាន់តែមានការរីកចម្រើននោះ សំណូមពរ និងសេចក្ដីត្រូវការរបស់ប្រជាជន ក៏កាន់តែរីកធំទៅតាមនោះដែរ ។ ប៉ុន្តែគ្មានសមិទ្ធផលណាដែលកកើតចេញមក ដោយមិនឆ្លងកាត់ភាពលំបាកលំបិននោះទេ ។ លោក **គុយ សេង** បានមានប្រសាសន៍បញ្ជាក់ជាចុងក្រោយថា អាស្រ័យដោយបទពិសោធន៍ក្នុងការងារ ការពង្រឹងបានធ្លុងសាមគ្គីភាពក្នុងការងារដឹកនាំព្រមទាំងមានការជួយឧបត្ថមគាំទ្រពីក្រុមការងារគ្រប់ថ្នាក់ផងនោះ យើងសង្ឃឹមថា ផែនការដែលបានដាក់ចេញនេះ នឹងទទួលបានជោគជ័យនិងទទួលបានការគាំទ្រពីប្រជាជនឃុំមង់រៀវជាមិនខានឡើយ ៕





ក្រៅពីការងារធ្វើស្រែប្រជាកសិករឃុំមង់រៀវមួយចំនួននាំគ្នាធ្វើចំការម្រេច និងដាំបន្លែ ដើម្បីផ្គត់ផ្គង់ជីវភាព

# ជំនោរហេមន្តរដូវ

*(បទពាក្យ៧)*



*១. សូរមាន់កញ្ច្រៀវរងាវកុះ*
*ប៉ូពាំល្អធើតអើតរស្មី*
*ទទះស្លាបចុះចឹកចំណី*
*អរុណោទ័យខ្យល់ត្រជាក់ ។*

*២. សន្សើមរោយស្រក់ដក់ពសុធា*
*មេឃមីរស្រទំជំនោរធ្លាក់*
*នាំធាតុរងាស្ពឹកញ័រញាក់*
*អាកាសត្រជាក់ឆ្លងវស្សា ។*

*៣. បងឈប់រទេះបេះផ្កាស្តៅ*
*ត្រដេវវិចយំគុម្ពព្រឹក្សា*
*ស្តាប់សត្វតៅរ៉ៅស្រែកខ្សៀវខ្វារ*
*ទទាឆ្លេឆ្លាចឹកចំណី ។*

*៤. លលកកុកគ្រួលបួលឆ្លងឆ្លើយ*
*បងបើកអន្លង់ប្រមូលត្រី*
*វាលស្មៅកន្ត្រើយក្បែរល្បាស់ព្រៃ*
*ក្បែរត្រពាំងស្រីក្រោមម្លប់ចារ ។*

*៥. ហេមន្តរដូវស្រូវទុំស្រុះ*
*ម្ទីម្នាប្រមូលភោគផល្លា*
*ប្រជាស្រីប្រុសគ្រប់អាត្មា*
*សប្បាយខ្សៀខ្វារដោយអំណរ ។*

*៦. វស្សាឆ្លងទៅរដូវថ្មី*
*ឆ្នាំនេះផលច្រើនកើនបន្ត*
*នៅក្រោមរស្មីព្រះទិន្នករ*
*ប្រជាត្រេកអរទាំងប្រុសស្រី ។*

*៧. គ្រឿងចក្រត្រាក់ទ័របរច្រូតកាត់*
*គោយន្តដឹកដៀវភ្ជួររាស់ដី*
*បោកបែនមិនស្ទាត់ឥតព្រួយភ័យ*
*ជួសគោក្របីលឿនរហ័ស ។*

*៨. ប្រព័ន្ធប្រឡាយបង្ហូរទឹក*
*ប្រពលវប្បកម្មមិនប្តូរផ្លាស់*
*ប្រើប្រាស់ល្ងាចព្រឹកមានមិនខ្វះ*
*ភ្ជាប់វិទ្យាសាស្ត្រទាន់សម័យ ។*

*៩. មករាដើមខែខ្មែរចងចាំ*
*បានរស់ឡើងវិញលុះសព្វថ្ងៃ*
*យើងផុតគុកកម្មគ្រោះប្រល័យ*
*ឆ្លងយុគសម័យកាប់ប្រហារ ។*

*១០. កាលនោះរដូវស្រូវស្រែទុំ*
*ក្រោយថ្ងៃប្រាំពីរខែមករា*
*យើងបានជួបជុំក្រុមគ្រួសារ*
*យើងមានវាសនារស់ជាថ្មី ។*

*១១. ដោយសារមានបក្សប្រជាជន*
*ផ្តល់សន្តិភាពសិទ្ធិសេរី*
*លោកមានគុណធ្ងន់ប្រោសប្រណី*
*សាងជាតិទឹកដីបានរុងរឿង ៕*

**ដោយលោក. សុខ សុធន**



## មួយហ្នឹងហើយ

អ្នកគ្រូសួរ **តែម** ដែលជាសិស្សជើងល្អ៖

- នែ... ប្អូន **តែម** ស្អែកនេះដល់ពេល ប្រឡងហើយ។ ម៉េចដែរប្រឡងលើកនេះ ប្អូនច្បាស់ក្នុងចិត្តទេ ?

- បាទ.... ប្រឡងលើកនេះ ខ្ញុំច្បាស់ណាស់អ្នកគ្រូ !

- អេហ៍.... ចេះតែនិយាយកម្លាចិត្តខ្លួនឯងទេដឹង ?

- ម៉េចអ្នកគ្រូមានប្រសាសន៍អញ្ចឹង ?

- ព្រោះរៀនរាល់ថ្ងៃ ប្អូនឯងមិនដែលបានពិន្ទុលើសពីមួយផង តើច្បាស់ក្នុងចិត្តយ៉ាងម៉េចទៅ ។

- បាទ...គឺខ្ញុំច្បាស់ក្នុងចិត្តថា ប្រាកដជាបានពិន្ទុ ១ ហ្នឹងទៀតហើយ ។

## ត្រឡប់ចូលផ្ទះ

ព្រឹងមួយ នាយ **ស៊ីស** បានទៅផ្ទះ លោកមេធាវី **សេត** ដើម្បីពឹងពាក់ជួយខ្លួនក្នុងការសុំលែងលះប្រពន្ធ ។

លោក **សេត** សួរ៖

- តើមូលហេតុអ្វី ដែលនាំឲ្យលោកលែងលះប្រពន្ធ ?

- បាទ... មកពីខ្ញុំទ្រាំលែងរួច ។ ប្រពន្ធខ្ញុំមានទម្លាប់មួយខុសគេ គឺភ្លឺឡើង ទើបចាប់ផ្តើមឡើងគ្រែ ដេក ។ ថ្ងៃណាក៏អ៊ីចឹងៗ តើឲ្យខ្ញុំទ្រាំយ៉ាងម៉េចទៅ ?

- ចុះពេលយប់នាងរវល់ធ្វើអ្វី បានជាមិនដេក ?

- គឺរវល់អង្គុយចាំខ្ញុំត្រឡប់ចូលផ្ទះហ្នឹងណា+ ។

## គ្នាជំនួសក៏បាន

ពេលបានជួបគ្នានាយ **សៃត** សួរនាយ **សៃម** ជាមិត្ត:

- អេហ៍ **សៃម** ឯងមានជាប់ប្រាក់មកតាមខ្លួនច្រើនទេ ?

- អើ មានច្រើនគួរសមដែរ តើឯងត្រូវការខ្ចីប៉ុន្មាន ?

- បើអ៊ីចឹង ឲ្យគ្នាខ្ចីបួនម៉ឺនរៀលសិនមក បីថ្ងៃទៀតសងវិញ ។

- តើឯងយកប្រាក់នេះទៅធ្វើស្អី ?

- គឺគ្នាត្រូវការប៉ាវសង្សារ ញ៉ាំគុយទាវមួយពេលហ្នឹងណា៎ ។ ឮដូច្នេះនាយ **សៃត** ទ្រឹងបន្តិចទើបឆ្លើយ:

- ណ្ហើយអ៊ីចេះចុះ។ រឿងហ្នឹងទុកគ្នាធ្វើជំនួសឯងចុះ។ គ្នានាំសង្សាររបស់ឯងទៅញ៉ាំគុយទាវមួយពេល រួចបីថ្ងៃទៀត សឹមឯងយកប្រាក់បួនម៉ឺនរៀលមកសងគ្នាវិញចុះ ៕

បោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 990 935 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ២០០

| | | | | | |
|---|---|---|---|---|---|
| ១- | លោកជំទាវ | ម៉ែន | សំអន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច .... | ៤០០.០០០៛ |
| ២- | ឯ.ឧ | កែ | គឹមយ៉ាន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ | ១០០ ដុល្លារ |
| ៣- | ឯ.ឧ | អ៊ុក | រ៉ាប៊ុន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងអភិវឌ្ឍន៍ជនបទ | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | ជា | ចាន់តូ | ប្រធានគណៈកម្មាធិការនៃគណបក្សធនាគារជាតិ | ៤០០.០០០៛ |
| ៥- | ឯ.ឧ | អូន | ព័ន្ធមុនីរ័ត្ន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២០០ ដុល្លារ |
| ៦- | ឯ.ឧ | វេង | សាខុន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | ១៥០ ដុល្លារ |
| ៧- | ឯ.ឧ | ប៉ាន | សូរស័ក្តិ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងពាណិជ្ជកម្ម | ១៥០ ដុល្លារ |
| ៨- | ឯ.ឧ | ហ៊ុន | ណេង | ប្រធានគណៈកម្មការទី ៤ នៃរដ្ឋសភា | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | ថោង | ខុន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | អ៊ិត | សំហេង | ប្រធានគណៈកម្មាធិការគណបក្សក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | គង់ | វិបុល | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | លន់ | លឹមថៃ | ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | អូស្មាន | ហាសន្ន់ | ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | សរ | ចន្ទ្រា | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | ប៉ា | សុជាតិវង្ស | ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | ម៉ែន | វិបុល | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ | ម៉ម | ប៊ុននាង | អនុប្រធានគណៈកម្មការទី ១០នៃព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៨- | ឯ.ឧ | យូ | តិរម្យ | អនុប្រធានក្រុមការងាររបស់គណៈកម្មាធិការកណ្តាល ចុះជួយរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៩- | គណៈកម្មការ កព១ | | | | ៤០០.០០០ ៛ |
| ២០- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | | ១០០ ដុល្លារ |
| ២១- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | | ១០០ ដុល្លារ |
| ២២- | គណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ | | | | ១០០ ដុល្លារ |
| ២៣- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | | ៥០ ដុល្លារ |
| ២៤- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | | ៥០ ដុល្លារ |
| ២៥- | គណៈកម្មាធិការគណបក្សខេត្តកំពត | | | | ៥០ ដុល្លារ |
| ២៦- | គណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | | | ២០០.០០០ ៛ |
| ២៧- | ឯ.ឧ | លឹម | គានហោ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ២០០.០០០ ៛ |
| ២៨- | ឯ.ឧ | ម៉ម | ប៊ុនហេង | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | ថា | យ៉ាវ | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា | ២១៣.៤៧០៛ |
| ៣០- | ឯ.ឧ | ជូ | យិនស៊ីម | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ៣១- | ឯ.ឧ | ប៉ាវ | ហាមផាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ | ម៉ៅ | ប៊ុនណារិន | សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា | ២០០.០០០៛ |
| ៣៣- | ឯ.ឧ | សូ | ជុងហួរ | សមាជិកក្រុមប្រឹក្សាខេត្តព្រះសីហនុ | ៥០ ដុល្លារ |
| ៣៤- | ឯ.ឧ | ចាយ | បូរិន | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម | ៥០ ដុល្លារ |
| ៣៥- | ឯ.ឧ | សួស | យ៉ារ៉ា | អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ | ៥០ ដុល្លារ |
| ៣៦- | ឯ.ឧ | នរៈ | រតនៈវឌ្ឍនោ | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ២០០.០០០ ៛ |
| ៣៧- | ឯ.ឧ | យួន | រ៉ានីន | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០ ដុល្លារ |
| ៣៨- | ឯ.ឧ. | ស្តើង | សុខុម | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ២០០.០០០៛ |
| ៣៩- | ឯ.ឧ | ឆាយ | ឫទ្ធិសែន | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគូបនីយកម្ម និងសំណង់ | ២០០.០០០៛ |
| ៤០- | ឯ.ឧ. | បូន | លឹមហេង | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៤១- | ឯ.ឧ | សេង | ធៀង | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៤២- | ឯ.ឧ | សុខ | ខេមរិន | អនុប្រធានក្រុមការងារចុះស្រុកកញ្ជ្រៀច និងប្រធានក្រុមការងារចុះឃុំកញ្ជ្រៀច | ៥០ ដុល្លារ |
| ៤៣- | ឯ.ឧ | ហេង | សួរ | អគ្គនាយកនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៥០ ដុល្លារ |
| ៤៤- | ឯ.ឧបណ្ឌិត | ហែម | ថេង | អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | ២០០.០០០៛ |
| ៤៥- | ឯ.ឧ | ម៉ែន | ស៊ីផាន់ | សមាជិកព្រឹទ្ធសភា | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | ណៅ | ធួក | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១០០.០០០៛ |
| ៤៧- | ឯ.ឧ | ប៉ាន | ប៊ុនធឿន | រដ្ឋលេខាធិការក្រសួងផែនការ | ១០០.០០០៛ |
| ៤៨- | លោកជំទាវ | ស៊ឹង | ស៊ីយុត | | ១០០.០០០៛ |
| ៤៩- | ឯ.ឧ | គីម | ធា | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង | ១០០.០០០៛ |
| ៥០- | ឯ.ឧបណ្ឌិត | មាស | ប៉ូ | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០០.០០០៛ |
| ៥១- | លោកជំទាវ | មិត្ស | ច័ន្ទតារីន | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៥២- | ឯ.ឧ | ជ្រួន | ថេរ៉ាវ៉ាត | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៥៣- | ឯ.ឧ | ប៉ែន | ច័ន្ទសុខេមរា | អគ្គាធិការ នៃអគ្គាធិការដ្ឋានក្រសួងរៀបចំដែនដីនគូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៥៤- | លោក | ហ៊ិន | សុទ្ធវុឌ្ឍ | ជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | ១០០.០០០៛ |
| ៥៥- | លោក | គីម | ប៊ុណ្ណា | សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សខេត្តសៀមរាបប្រធានសាខាគណបក្សមន្ទីរសាធារណការ និងដឹកជញ្ជូន ... | ១០០.០០០៛ |
| ៥៦- | ឯ.ឧ. ឧកញ៉ា | សន | កុសល | អនុប្រធានគណបក្សស្រុកកំពង់សិលា | ២០ ដុល្លារ |
| ៥៧- | ឯ.ឧ | ស៊ឹម | ស៊ីថា | អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ៨០.០០០៛ |
| ៥៨- | ឯ.ឧ | អ៊ុន | ឆាលី | សមាជិកក្រុមប្រឹក្សាខេត្តកោះកុង | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ២០០

| | | | | | |
|---|---|---|---|---|---|
| ៥៩- | ឯ.ឧ | ពត | ចាន់នី | សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម | ៥០.០០០៛ |
| ៦០- | ឯ.ឧ | ហេង | វណ្ណា | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦១- | ឯ.ឧ | ស៊ាង | ចាន់ | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦២- | លោកជំទាវ | ស៊ើ | ចំនួថា | | ៥០.០០០៛ |
| ៦៣- | ឯ.ឧ | ជា | វុទ្ធី | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦៤- | ឧកញ៉ា | ឆេព | វិសិដ្ឋ | អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យ នៃគណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦៥- | លោក | អ៊ុំ | រាត្រី | អភិបាលរងខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៦- | លោក | ឆេង | សុភក្រ្ត | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦៧- | លោក | ហូ | ដាវីណា | ប្រធានការិល័យរដ្ឋបាល នៃធនាគារជាតិ | ៥០.០០០៛ |
| ៦៨- | ឯ.ឧ | ថៅ | ជេដ្ឋា | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០ ៛ |
| ៦៩- | **គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម** | | | | ៤០.០០០៛ |
| ៧០- | លោក | លី | សារី | អភិបាលរង ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧១- | លោក | គឹម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧២- | ឯ.ឧ | ស៊ិន | វុទ្ធី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ៣០.០០០៛ |
| ៧៣- | ឯ.ឧ | សាំង | សារ៉ាត | សមាជិកក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៧៤- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខណ្ឌសែនសុខ ភ្នំពេញ | ៣០.០០០៛ |
| ៧៥- | លោក | ចាន់ | ស៊ីណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ៣០.០០០៛ |
| ៧៦- | លោក | ឃុ | ពៅ | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៧៧- | កញ្ញា | កែវ | សុជាតា | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ៣០.០០០៛ |
| ៧៨- | លោក | ហង់ | ប៊ូ | ប្រធានក្រុមការងារចុះ ឃុំវវៀង ស្រុកសំរោង ខេត្តតាកែវ | ២០.០០០៛ |
| ៧៩- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨០- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨១- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨២- | លោក | លឹម | វីរក្សា | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ២០.០០០៛ |
| ៨៣- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៨៤- | លោក | ម៉ី | វុឌ្ឍា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ២០.០០០៛ |
| ៨៥- | លោក | អ៊ុត | សំអាន | អគ្គារធិការរងនៃអធិការដ្ឋានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២០.០០០៛ |
| ៨៦- | លោក | គួច | ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨៧- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ៨៨- | ឯ.ឧ | ប៉ុញ | សច្ចះ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៨៩- | លោក | ខួន | ពេជ្រ | ប្រធាននាយកដ្ឋានទឹកស្អាត ក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩០- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៩១- | លោក | ម៉ម | ប្ញូស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩២- | លោក | សៅ | សម្ផស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៣- | លោក | ប៉ាវ | មុយជុង | អនុប្រធានគណៈកម្មាធិការសាខាបក្សមជ្ឈមណ្ឌលផ្ដល់ឈាមនៃមន្ទីរពេទ្យព្រះអង្គឌួង | ១០.០០០៛ |
| ៩៤- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៩៥- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៩៦- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៩៧- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៩៨- | លោក | សៅ | សម្ភារ | ប្រធានការិយាល័យបណ្ដុះបណ្ដាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៩- | លោក | និត | ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០០- | លោក | សែម | សំណាង | អនុប្រធាននាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០១- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០២- | លោក | សូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៣- | លោក | ហួត | ឆាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៤- | លោក | ទឹម | វុដ្ឋារី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៥- | លោក | ណុប | រៀមណី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៦- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៧- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៨- | លោក | ទូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៩- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១០- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១១- | លោក | កេត | ចាន់សាវុធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១២- | លោក | ជីវ | ស៊ុនហេង | សមាជិកក្រុមការងារចុះខេត្ត កណ្ដាល | ១០.០០០៛ |
| ១១៣- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកពោធិរៀង ខេត្តព្រៃវែង | ១០.០០០៛ |
| ១១៤- | លោក | ឡុង | ចន្ថា | សមាជិកក្រុមការងារចុះស្រុកពោធិរៀង ខេត្តព្រៃវែង | ១០.០០០៛ |
| ១១៥- | លោក | ឡាច | តីវ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១៦- | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |



វិទ្យាល័យ ប៊ុន រ៉ានី
ហ៊ុនសែន ចរិយាវង្ស
ក្នុងភូមិដំណាក់ចំបក់
សង្កាត់អូរក្រួសារ ក្រុងកែប
(សម្ពោធថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៧)

អគារសម្តេចអគ្គមហាសេនា
បតីតេជោ ហ៊ុន សែន
ស្ថិតនៅក្នុងមន្ទីរពេទ្យមិត្តភាព
ខ្មែរ_សូវៀត
(សម្ពោធថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨)





អគារតេជោសន្តិភាព
ស្ថិតនៅក្នុងមន្ទីរពេទ្យ
កាល់ម៉ែត្រ
(សម្ពោធថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨)

ចែកជូនដោយឥតគិតថ្លៃ